**ក្រសួងអប់រំ យុវជន និងកីឡា**

**Ministry of Education**, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅ កម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី។

THE SITUATION OF THE USE OF INFORMATION AND COMMUNICATION TECHNOLOGY FOR MANAGEMENT AND TEACHING AT THE UPPER SECONDARY LEVEL IN RATANAKIRI PROVINCE

**លស់ សាឡន**/LORS SALORN

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅ កម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី។

## THE SITUATION OF THE USE OF INFORMATION AND COMMUNICATION TECHNOLOGY FOR MANAGEMENT AND TEACHING AT THE UPPER SECONDARY LEVEL IN RATANAKIRI PROVINCE

**លស់ សាឡូន**/LORS SALORN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

សាស្ត្រាចារ្យដឹកនាំ៖ លោក ម៉ៅ សារឿន

សាស្ត្រាចារ្យដឹកនាំរង៖ ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម

# សេចក្តី អះអាងរបស់បេក្ខជន

ខ្ញុំបាទសូមអះអាងថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្គប់រំនៅវិទ្យាស្ថានអប់រំ ពិតជាស្នាដៃ របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ខ្ញុំបាទសូមបញ្ជាក់ផងដែរថា គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារណាមួយ ឬការចុះបញ្ជីឯកសារយោងណាមួយ ដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធនោះឡើយ។

ខ្ញុំសូមអះអាងថា និក្ខេបបទស្រាវជ្រាវ នៃប្រធានបទខាងឡើពិតជាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ……………… ខែ ………ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ……………ខែ…………ឆ្នាំ២០២១

**ហត្ថលេខាបេក្ខជន**

**លាស់ សាឡុន**

# លិខិតបញ្ជាក់

**លោកៈ** **ម៉ៅ សារឿន** ជាសាស្ត្រាចារ្យដឹកនាំ
**ឯកឧត្តមបណ្ឌិតៈ** **ម៉ុក សារ៉ុម** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **លាស់ សាឡុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសិក្សាស្រាវជ្រាវ និងបានសរសេរនិក្ខេបបទដែលមានចំណងជើង "**ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី** ពិតប្រាកដមែន។

ថ្ងៃ.......................ខែ...........ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី................ខែ..........ឆ្នាំ២០២១

....................................... ....................................

**លោកៈ ម៉ៅ សារឿន** **ឯកឧត្តមបណ្ឌិតៈ ម៉ុក សារ៉ុម**

សាស្ត្រាចារ្យដឹកនាំ សាស្ត្រាចារ្យដឹកនាំរង

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣២០៥ អយក. ទ ១៥

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំសូមសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក **សោម ឡៀក** និងអ្នកម្តាយ **ជូ ឡុខ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងដល់រូបកូន អោយបានទទួលការសិក្សាអប់រំរហូតដល់រូបកូនមានថ្ងៃនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូន ព្រមទាំងមិត្តភក្តិទាំងអស់ ជាពិសេស ឧត្តមភរិយា **នួន ស្រីណាំ** ដែលបានលះបង់ពេលវេលា កម្លាំងកាយ កម្លាំងចិត្ត លើកទឹកចិត្ត និងតែងតែជួយឧបត្ថមគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ សម្ភារដើម្បីឱ្យខ្ញុំបានបន្តការសិក្សារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ។

ខ្ញុំបាទសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ដែលបានខិតខំប្រឹងប្រែងកសាងប្រទេសជាតិអោយមានសុខសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យអប់រំដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតធនធានមនុស្សសម្រាប់ជាសរសរស្តម្ភនៃប្រទេសជាតិ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ដែលបាន ខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា អោយមានគុណភាពល្អប្រសើរដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ វិទ្យាស្ថានជាតិអប់រំ និងគណគ្រប់គ្រងដែលបានរៀបចំ ថ្នាក់បរិញ្ញាប្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ដែលមានទាំងថ្នាក់បង់ថ្លៃ និងថ្នាក់អាហារូបករណ៍ ដែលផ្តល់ឱកាសអោយខ្ញុំបាទបានប្រឡងជាប់ចូលសិក្សានៅទីនេះ។

ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកសាស្ត្រចារ្យ **ម៉ៅ សារឿន** ជាគ្រូដឹកនាំបង្គោល និង**ឯកឧត្តមបណ្ឌិត ម៉ុក សារុំម** ជាគ្រូដឹកនាំរង ដែលលោកទាំងពីរតែងតែ

ចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ណែនាំនូវគន្លឹះសំខាន់ផ្សេងៗទៅតាមជំហាននិមួយៗ ដល់រូបខ្ញុំបាទ ទើបធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ ប្រកបដោយគុណភាពដែលអាចប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ខ្ញុំសូមឧទ្ទិសនូវស្នាដៃនៃការសិក្សាស្រាវជ្រាវនេះជូនចំពោះដួងវិញ្ញាណក្ខន្ធបុព្វបុរសនៃជូនតខ្មែរគ្រប់សម័យកាលដែលបានតស៊ូលះបង់ដើម្បីជាតិមាតុភូមិ។ ក៏សូមឧទ្ទិសនូវស្នាដៃនេះជូន អ្នកម្ដាយ **ជូ ឡុង** ព្រមទាំងញាតិការប្រាំពីរសណ្ដានដែលបានបែកកាយរំលាយក្ខន្ធទៅកាន់លោកខាងមុខហើយក្ដី ក៏សូមឲ្យលោក ទទួលដឹងនូវលទ្ធផលដែលជាការខិតខំបណ្ដុះបណ្ដាលកូនចៅឱ្យមានថ្ងៃនេះផងដែរ។

ជាទីបញ្ចប់ខ្ញុំសូមបួងសួងដល់ទេវតាដែលឋិតនៅចក្កវាឡទាំងមួយម៉ឺនលោកជាតុ និងសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធក្នុងលោក ជាពិសេសក្នុងទឹកដីសុវណ្ណភូមិ សូមប្រសិទ្ធពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការជូនចំពោះ ឯកឧត្តមបណ្ឌិត លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ មិត្តរួមថ្នាក់ លោកឪពុក ក្រុមគ្រួសារ ភរិយា និងកូនៗខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ក្នុងប៉ុន្មានឆ្នាំថ្មីៗ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍលើគ្រប់វិស័យដែលអាចជួយសម្រួលដល់ការទំនាក់ទំនងផ្សេងៗនៅលើពិភពលោក ដែលស្របតាមបរិបទថ្មីនៃយុគសម័យបដិវត្តឧស្សាហកម្ម ៤.០ ។ ដោយមើលឃើញពីសារសំខាន់នេះ ក្រសួងអប់រំ យុវជន និងកីឡានៃប្រទេសកម្ពុជាបានសម្រេចបញ្ចូលគោលនយោបាយ និងយុទ្ធសាស្រ្តថ្នាក់ជាតិស្តីពី បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ ។ ក្នុងន័យនេះដែរ ដើម្បីរួមចំណែកជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងប្រសិទ្ធភាព និងគុណភាពអប់រំ ការសិក្សាស្រាវជាវមួយនេះក៏ត្រូវបានរៀបចំឡើងដែលសិក្សាស្តីអំពីស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន សារគមនាគមន៍ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅក្នុងខេត្តរតនគិរី ។ ប្រធានបទនេះគឺផ្តោតទៅលើការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន សារគមនាគមន៍ក្នុងការគ្រប់គ្រង និងការបង្រៀន និងបញ្ហាប្រឈមនានា។

តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា "កម្រិតយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT " របស់គណៈគ្រប់គ្រងសាលាគឺក្នុងកម្រិត "ល្អ" ខណៈដែល សូចនាករទទួលបានពីគ្រូគឺក្នុងកម្រិត "មធ្យម" ។ ចំណែកឯ"ស្ថានភាពទូទៅនៃការប្រើប្រាស់ICT ក្នុងសាលារៀន" គណៈគ្រប់គ្រង បានផ្តល់ពិន្ទុក្នុងកម្រិត "ល្អ" ខណៈដែលលោកគ្រូ - អ្នកគ្រូបានផ្តល់ទិន្នន័យជាសរុបក្នុងកម្រិត "មធ្យម" ។

សម្រាប់កម្មវិធីដែលគណៈគ្រប់គ្រងបានប្រើជាញឹកញាប់ជាងគេនោះគឺ Telegram ដែលទទួលបានពិន្ទុក្នុងកម្រិតមធ្យម ខណៈដែលលោកគ្រូ អ្នកគ្រូបានផ្តល់ពិន្ទុទៅលើTelegram ក្នុងកម្រិត"មធ្យម" ។

ក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវបានរកឃើញនូវបញ្ហាប្រឈមជាច្រើន ដែលកើតឡើងលើគ្រូ សិស្ស និងគណៈគ្រប់គ្រងចំពោះការប្រើប្រាស់ ICT ។ អ្នកស្រាវជ្រាវបានសរុបរួមទៅលើ ៤ ចំណុចសំខាន់ដែលបានឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងការប្រើប្រាស់ ICT រួមមាន៖ កត្តាប្រព័ន្ធអ៊ិនធឺណេត កត្តាអាកាសធាតុ កត្តាកង្វះការយល់ដឹងផ្នែកICT កត្តាកង្វះគ្រូបង្គោលផ្នែកICT ។

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងអង្កេតនៅតាមសាលារៀន លើប្រធានបទ "ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្ត រតនគិរី អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានជារួមបានថា ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមសាលាកម្រិត មធ្យមសិក្សា ទុតិយភូមិក្នុងខេត្តរតនគិរី នៅមិនទាន់មានការប្រើប្រាស់ក្នុងកម្រិតមួយដែលអាចមានការប្រកួតប្រជែងនៅក្នុងការគ្រប់គ្រង និងការបង្រៀន នាសតវត្សទី២១នេះទេ។

ដូចនេះ ទាំង គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ ត្រូវពង្រឹងបន្ថែមទៀតទាំង ចំណេះដឹង និងសម្ភារ ICT ជាច្រើនទៀតដើម្បីឲ្យការគ្រប់គ្រង និងការបង្រៀន កាន់តែមានប្រសិទ្ធិភាពដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង។

# Abstract

In recent years, information and communication technology has played an important role in the development of all sectors that can facilitate communication in the world in line with the new context of the Industrial Revolution 4.0 era. Recognizing this importance, the Ministry of Education, Youth and Sports of Cambodia has decided to incorporate national policies and strategies on information and communication technology in the education sector. In this regard, in order to contribute to the Ministry of Education, Youth and Sports in strengthening the efficiency and quality of education, this research study was also organized, which studies the situation of the use of information and communication technology in the management and teaching at the upper secondary level. In Ratanakkiri province. This topic focuses on the use of information and communication technology in management and teaching and challenges.

According to the research results, the "level of understanding of the use of ICT equipment" of the management is at a “good” level, while the indicators received from teachers are at an “average” level.

As for the "general situation of ICT use in schools", the management gave a score of "good" while teachers provided aggregate data at an "average" level. For the program that the management used most often, Telegram scored in the intermediate level, while the teachers rated the Telegram in the "intermediate" level. In the research, the researchers found many challenges that arise to teachers students and management for the use of ICT. The researchers summed up the four main points that reflects the challenges of using ICT, including: Internet factors, weather factors, lack of understanding of ICT, lack of ICT trainers.

After conducting research and surveys in schools on the topic "Status of use of information and communication technology in management and teaching at the upper secondary level in Ratanakkiri province", the researchers can conclude that the use of information and communication technology in high schools in Ratanakkiri province is not yet used to a degree that can be competitive in the management and teaching of the 21st century.

Therefore, both the management and the teachers need to further expand their knowledge and ICT materials to make the management and teaching more effective in response to the policy of the Ministry

# ចំណងជើងតារាង


| តារាង | ចំណងជើង | ទំព័រ |
| --- | --- | --- |
| តារាងទី១៖ | ការកំណត់ភាគសំណាក---------------------------------------------------- | ៣៩ |
| តារាងទី២៖ | ក្រុមគោលដៅនិងអ្នកចូលរួម---------------------------------------------- | ៤១ |
| តារាងទី៣៖ | ព័ត៌មានទូទៅពីគណៈគ្រប់គ្រង ---------------------------------------- | ៤៧ |
| តារាងទី៤ ៖ | ព័ត៏មានទូទៅពីគ្រូ ----------------------------------------------------- | ៥១ |
| តារាងទី ៥៖ | ព័ត៏មានទូទៅពីសិស្ស---------------------------------------------------- | ៥៥ |
| តារាងទី៦ ៖ | កម្រិតយល់ដឹងលើការប្រើប្រាស់ឧបករណ៍ICT----------------------------- | ៦០ |
| តារាងទី៧៖ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT-------------------------------------- | ៦២ |
| តារាងទី៨៖ | ការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា --------------------------------- | ៦៥ |
| តារាងទី៩៖ | កម្រិតយល់ដឹងរបស់គ្រូបង្រៀនលើការប្រើប្រាស់ឧបករណ៍ICT -------- | ៦៧ |
| តារាងទី១០៖ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT ------------------------------------- | ៦៩ |
| តារាងទី១១៖ | ការប្រើប្រាស់កម្មវិធីICTក្នុងការបង្រៀន --------------------------------- | ៧៣ |
| តារាងទី១២៖ | កម្រិតយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT ------------------------ | ៧៥ |
| តារាងទី១៣៖ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន ------------------- | ៧៧ |
| តារាងទី១៤៖ | ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការគ្រប់គ្រង ----------------- | ៨០ |
| តារាងទី១៥៖ | កត្តាប្រឈមរបស់សិស្សលើការប្រើប្រាស់ ICT------------------------- | ៨២ |
| តារាងទី១៦៖ | កត្តាប្រឈមរបស់គ្រូលើការប្រើប្រាស់ ICT---------------------------- | ៨៤ |
| តារាងទី១៧៖ | កត្តាប្រឈមរបស់គណៈគ្រប់គ្រង--------------------------------------- | ៨៦ |
| តារាងទី១៨៖ | កត្តាប្រឈមរបស់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ ----------------- | ៨៧ |

# មាតិកា


**សេចក្តី អះអាងរបស់បេក្ខជន** ........................................ i

**លិខិតបញ្ជាក់** ........................................ ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........................................ iv

**សេចក្តីថ្លែងអំណរគុណ** ........................................ v

**មូលន័យសង្ខេប** ........................................ viiii

Abstract ........................................ viiiii

**ចំណងជើងតារាង** ........................................ ix

## ជំពូកទី១

## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ 7

១.៤ សំណួរស្រាវជ្រាវ ........................................ 7

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 8

១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ 7

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 9

## ជំពូកទី២

## រំឭកទ្រឹស្តី

២.១សេខក្តីផ្តើម ........................................ 11

២.២ និយមន័យ ........................................ 12

២.៣.ការប្រើប្រាស់បច្ចេកវិទ្យាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងកាគ្រប់គ្រងនិងការបង្រៀន ........................................ 14

២.៣.១.ប្រសិទ្ធភាពនៃបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍លើតួនាទីគ្រូបង្រៀន . 14

២.៣.២ ប្រសិទ្ធភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើតួនាទីរបស់នាយក ..... 16

២.៣.៣ ការបកស្រាយផ្សេងៗពីប្រសិទ្ធភាពនៃការប្រើប្រាស់ ICT ក្នុងការបង្រៀន ...... 16

២.៣.៤. ការ អភិវឌ្ឍន៍ ផ្នែក បច្ចេកវិទ្យាព័ត៌មាន និងសារ គមនាគមន៍ ក្នុង ការ បណ្តុះបណ្តាល គ្រូបង្រៀន ........ 23
២.៣.៥ ការបកស្រាយផ្សេងៗពីប្រសិទ្ធភាពនៃការប្រើប្រាស់ ICT ក្នុងការគ្រប់គ្រងសាលា ........ 24
២.៤. ការជះឥទ្ធិពលនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ទៅលើមុខវិជ្ជាសិក្សា ........ 27
២.៥. សារៈសំខាន់ជាអន្តរជាតិនៃគោលនយោបាយច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ........ 28
២.៦. បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងប្រទេសកម្ពុជា ........ 30
២.៧. គោលនយោបាយ និង យុទ្ធសាស្រ្ត ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា ........ 32

## ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

៣.១ ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ ........ 36
៣.២ ក្រុមគោលដៅ ........ 37
៣.៣. ទំហំសំណាក ........ 38
៣.៤. ឧបករណ៍ស្រាវជ្រាវ ........ 39
៣.៤.១. កម្រងសំណួរសម្រាប់សិស្ស ........ 40
៣.៤.២ កម្រងសំណួរសម្រាប់គ្រូ ........ 40
៣.៤.៣ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ........ 41
៣.៥. វិធីសាស្ត្រប្រមូលទិន្នន័យ ........ 41
៣.៦. ដំណើការក្នុងការប្រមូលទិន្នន័យ ........ 41
៣.៧. ការវិភាគទិន្នន័យ ........ 42
៣.៨ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ........ 42
៣.៩. ព្រំដែននៃការសិក្សាស្រាវជ្រាវ ........ 43
៣.១០ ព័ត៌មានទូទៅរបស់អ្នកចូលរួម ........ 43
៣.១០.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម ........ 43
៣.១០.១.១ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង ........ 44

៣.១០.១.២. ព័ត៌មានទូទៅពីគ្រូបង្រៀនតាមមុខវិជ្ជា .......... 47
៣.១០.១.៣. ព័ត៌មានទូទៅពីសិស្ស .......... 51

# ជំពូកទី៤

# លទ្ធផលនិងការពិភាក្សា

៤.១. លទ្ធផល .......... 56
៤.១.១. ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់សិស្ស .......... 57
៤.១.១.១. កម្រិតនៃការយល់ដឹងរបស់សិស្សក្នុងការប្រើប្រាស់ឧបករណ៍ ICT .......... 57
៤.១.១.២. ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការសិក្សារបស់សិស្ស .......... 59
៤.១.១.៣. ស្ថានភាពនៃការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា .......... 62
៤.១.២. ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់គ្រូ .. 64
៤.១.២.១. កម្រិតនៃការយល់ដឹងរបស់គ្រូបង្រៀនលើការប្រើប្រាស់ICT .......... 64
៤.១.២.២ ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន។ .......... 66
៤.១.២.៣ ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការបង្រៀន។ .......... 70
៤.១.៣ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នាយក .......... 72
៤.១.៣.១.កម្រិតការយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT .......... 72
៤.១.៣.២.ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន .......... 74
៤.១.៣.៣.ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការគ្រប់គ្រង .......... 77
៤.២. បញ្ហាប្រឈមនៃការប្រើប្រាស់ ICT .......... 79
៤.២.១ កត្តាប្រឈមរបស់សិស្សលើការប្រើប្រាស់ ICT .......... 79
៤.២.២ កត្តាប្រឈមរបស់គ្រូលើការប្រើប្រាស់ ICT .......... 80
៤.២.៣ កត្តាប្រឈមរបស់របស់គណៈគ្រប់គ្រង .......... 82
៤.៣. ការពិភាក្សា .......... 84

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១. សេចក្តីសន្និដ្ឋាន ........................................ 89
៥.២. សំណូមពរ ........................................ 91
៥.២.១. ក្រសួងអប់រំ យុវជន និងកីឡា ........................................ 91
៥.២.២.មន្ទីអប់រំ យុវជន និងកីឡា ........................................ 91
៥.២.៣. នាយកសាលា និងប្រធានក្រុមបច្ចេកទេស ........................................ 92
៥.២.៤. គ្រូបង្រៀន ........................................ 92
៥.២.៥. សិស្សានុសិស្ស ........................................ 92
**ឯកសារយោង** ........................................ 93
**ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្រាវជ្រាវ** ........................................ 95

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នបច្ចេកវិទ្យានៅលើពិភពលោកមានការអភិវឌ្ឍន៍គួរអោយកត់សម្គាល់ជាមួយកាប្រកួតប្រជែងលើគ្រប់ផ្នែកគ្រប់វិស័យ ។ ការជឿនលឿនផ្នែកបច្ចេកវិទ្យាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំជាមួយសកលភាវូបនីយកម្ម។ យុគសម័យព័ត៌មានបានបង្កើនអត្រានៃសាកលភាវូបនីយកម្មមិនដែលមានពីមុនមក ដោយសារការពង្រីកអ៊ិនធឺណែតយ៉ាងឆាប់រហ័សបង្កើតពិភពលោកដែលមានបណ្តាញតភ្ជាប់គ្នា។ ការទទួលយកបច្ចេកវិទ្យាដោយប្រទេសកំពុងអភិវឌ្ឍន៍បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ពួកគេ ដូចជាការកាត់បន្ថយថ្លៃដើមផលិតកម្ម ផលិតកម្មបង្កើតស្តង់ដារសម្រាប់គុណភាព និងអនុញ្ញាតឱ្យបុគ្គលប្រាស្រ័យទាក់ទង ពីចម្ងាយលឿនជាងមុនងាយស្រួលជាងមុន ។ ដើម្បីចូលរួមក្នុងទីផ្សារបច្ចេកវិទ្យាខ្ពស់ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវការបុគ្គលដែលមានជំនាញបច្ចេកទេសផ្នែកបច្ចេកវិទ្យាច្បាស់លាស់ផងដែរ។ ក្នុងនោះវិស័យអប់រំ គឺជាវិស័យអាទិភាព ក្នុងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ដែលជួយឲ្យមានការលើកស្ទួយយ៉ាងខ្លាំងបំផុតដល់សេដ្ឋកិច្ចជាតិ ដើម្បីមានការប្រកួតប្រជែងលើទីផ្សារការងារនៅក្នុងតំបន់ក៏ដូច ជាសកលលោកទាំងមូល។

វិស័យអប់រំត្រូវបានផ្សារភ្ជាប់យ៉ាងពេញទំហឹងទៅលើបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ Information and communication Technology ( ICT ) ដើម្បីឲ្យគ្រូ សិស្ស និងគណៈគ្រប់គ្រងមានភាពប្រកដប្រជាលើការប្រើប្រាស់បច្ចេកវិទ្យាក្នុងការងារពេលបច្ចុប្បន្ន និងអនាគត។

ដោយមើលឃើញពីការចាំបាច់ និងសក្តានុពលនៃការប្រើប្រាស់បច្ចេកវិទ្យា លើវិស័យនានាក្នុងតំបន់ក៏ដូចជាពិភពលោកទាំងមូល ។ ក្រសួងអប់រំ យុវជន និងកីឡាបានចេញគោលនយោបាយ និងយុទ្ធសាស្រ្តស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ICT នៅក្នុងថ្នាក់រៀននៃវិទ្យាល័យ រហូតដល់សកលវិទ្យាល័យ។

យោងទៅលើការបង្ហាញរបស់ក្រសួងអប់រំ យុវជន និងកិឡា ស្តីអំពីគោលនយោបាយនិងយុទ្ធសាស្ត្រនៃ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០១៨ បានលើកឡើងថា "ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ថា សមត្ថភាពធនធានមនុស្សខាងផ្នែកបំណិននៃសតវត្សទី២១ ជាពិសេសការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (បពស) ជាកត្តាជំរុញ ឧត្តមភាព ប្រគួតប្រជែងរបស់ប្រទេស ។ សមត្ថភាពទាំងនេះនឹងជួយឲ្យប្រជាជនបង្កើតចំណេះដឹងថ្មីៗ និងប្រែក្លាយចំណេះដឹងទាំងនេះទៅជាការអនុវត្តថ្មីដើម្បីគាំទ្រដល់ការធ្វើអន្តរកម្ម សេដ្ឋកិច្ចរបស់ប្រទេសពីការធ្វើពាណិជ្ជកម្ម ផលិតផល និងសេវាកម្ម ដែលប្រើប្រាស់ចំណេះដឹងកម្រិតខ្ពស់ ។ ក្រសួង ក៏បានបន្ថែមទៀតថាៈ "បពស" គឺជា កត្តាដ៏ចម្បងមួយក្នុង ការលើកម្ពស់ការអភិវឌ្ឍធនធានមនុស្សសម្រាប់សេដ្ឋកិច្ច សតវត្សរ៍ទី២១ ដែលតម្រូវឲ្យវិស័យអប់រំចាំបាច់រៀបចំផែកការ បពស ដើម្បីធានានូវ ប្រសិទ្ធភាពនិងនិរន្តភាពងាកចេញពីស្ថានភាពបច្ចុប្បន្ន"។

ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរថាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នឹងក្លាយជាឧបករណ៍ដ៏សំខាន់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មរបស់ប្រទេស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយផ្អែកលើចំណុច ដែលមានសារៈសំខាន់ និងប្រកបដោយសត្តានុពល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គឺជា ចំណេះដឹង ដែលមិនអាចខ្វះបាន ក្នុងវិស័យអប់រំ ដែលជាវិស័យបានផលិតនូវ ធនធានមនុស្សដែលបម្រើឲ្យគ្រប់វិស័យ ក៏ដូចជាការបង្កើតឲ្យសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើននៅក្នុង សង្គមទំនើបនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំមានការអភិវឌ្ឍទៅមុខឥតឈប់ឈរយ៉ាងណាក៏ដោយ ក៏យើងសង្កេតឃើញដែរថានៅតាមស្ថាប័នអប់រំមួយចំនួនដូចជា សាកលវិទ្យាល័យ វិទ្យាស្ថាន សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សាលាគរុកោសល្យ មជ្ឈមណ្ឌល វិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា បានជួបប្រទះនូវបញ្ហា អត្ថរកម្មនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក៏ដូចជាការអភិវឌ្ឍនូវបច្ចេកវិទ្យានោះ ដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃនៅមានភាពមិនទាន់សម័យកាល និងមានភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរប្រព័ន្ធប្រើប្រាស់ទៀតផង ដែលជាមូលហេតុធ្វើឲ្យរាំងស្ទះដល់ការងារអប់រំនៃស្ថាប័ននោះ ។ ម៉្យាងវិញទៀតនៅតាមវិទ្យាល័យសព្វថ្ងៃនេះ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាដៃគូមួយចំនួន បានសហការគ្នាដាក់ឲ្យប្រើប្រាស់ជាមួយ ឧបករណ៍បច្ចេកវិទ្យា អាយ ស៊ី ធី ក្នុងការអប់រំសម្រាប់គ្រូ និងសិស្ស ដើម្បីធ្វើឲ្យការអប់រំនៅវិទ្យាល័យនោះមានភាពទាន់សម័យ និងអភិវឌ្ឍឥតឈប់ឈរ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការអប់រំឲ្យកាន់តែប្រសើរឡើង។

អ្នកវិទ្យាសាស្ត្រដូចជាអ្នកស្រាវជ្រាវបានអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗជាច្រើនដែលត្រូវបានជះឥទ្ធិពលយ៉ាងធំធេងទៅនឹងការដាក់បញ្ចូលកម្មវិធីថ្មីៗក្នុងវិស័យអប់រំ ។ ការសិក្សាជាច្រើនត្រូវបានគាំទ្រទៅនឹងអត្ថប្រយោជន៍ នៃការចែកចាយ និងទំនាក់ទំនងនៃការអប់រំ ដែលធ្វើឲ្យ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) អាចជួយឲ្យរីកចម្រើនដល់ វិធីសាស្ត្រនៃការបង្រៀន និងរៀន ព្រមទាំងជះឥទ្ធិពលដល់អ្នកសិក្សាយ៉ាងមានប្រសិទ្ធភាព (Kennewell, &Beauchamp,2007)។

បច្ចេកវិទ្យាកុំព្យូទ័រ និងទិដ្ឋភាពផ្សេងទៀតនៃវប្បធម៌ឌីជីថល បានផ្លាស់ប្តូររបៀបរស់នៅរបស់មនុស្ស ការធ្វើការ និងរៀនដែលជះឥទ្ធិពលដល់ការស្ថាបនា និងចែកចាយចំណេះដឹងនិងអំណាចនៅជុំវិញពិភពលោក។ (Deuze, M. 2006)

នៅក្នុងបរិបទនៃភាពប្រែប្រួលលើវិស័យបច្ចេកវិទ្យាប្រទេសកម្ពុជាមានការប្រែប្រួលគួរឲ្យកត់សម្គាល់ចំពោះការបង្រៀន រៀនតាមបែបបច្ចេកវិទ្យា ជាពិសេសការសិក្សាត្រូវបានចាប់ផ្តើមឡើងតាំង ពីថ្នាក់វិទ្យាល័យ។ នៅក្នុងនោះក៏មានការផ្លាស់ប្តូរយ៉ាងខ្លាំងផងដែរ សម្រាប់គ្រូបង្រៀន និងសិស្ស ដែលបានយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) សម្រាប់ជំនួយដល់ការបង្រៀន និងរៀនរបស់ពួកគាត់ នៅប៉ុន្មានឆ្នាំកន្លងមកនេះ។

នៅក្នុងការប្រែប្រួលនេះ ទាំងគ្រូ និងសិស្ស មានការផ្លាស់ប្តូរ និង ប្រឈមទៅនឹងកត្តាជាច្រើនដើម្បីប្រើប្រាស់ និងដើរឲ្យទាន់បច្ចេកវិទ្យាថ្មីៗ ក្នុងប្រទេស និងសាកល។ ជាក់ស្តែងដូចជាក្នុងពេលបច្ចុប្បន្ន វិបត្តិពិភពលោកទៅលើការីករាលដាលនៃបញ្ហាវីរុសកូវីត១៩ វិស័យអប់រំមិនថាក្នុងតំបន់ឬពិភពលោក ទទួលរងយ៉ាងធ្ងន់ធ្ងរដែលជំរុញឲ្យសាលាទាំងអស់បានបិទទ្វារហើយបង្រៀនតាមរយៈអនឡាញ ។

វិធីសាស្ត្រសិក្សាថ្មីៗដែលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងប្រទេសកម្ពុជា ត្រូវបានយកមកប្រើប្រាស់ដូចជាការសិក្សាតាម Google Crassroom, Google meet, Zoom Telegram Messenger ជាដើម ។ គ្រូបង្រៀនត្រូវការឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈជាក់លាក់ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការវាយតំលៃការរៀនសូត្រការបង្រៀនជាលក្ខណៈបុគ្គលការទទួលបានធនធានតាមអ៊ិនធឺណេត និងសម្រាប់ការជំរុញអន្តរកម្មនិងការសហការគ្នារបស់សិស្ស។ (Dunleavy, M., Dextert, S. and Heinecke, W.F. 2007) យ៉ាងណាក៏ដោយ ដើម្បីអោយដំណើរការ បង្រៀន មានប្រសិទ្ធភាព និងភាពងាយស្រួល នាយកសាលាក៏ដូចជាអ្នកដឹកនាំសាលាក៏មានការទទួលខុសត្រូវខ្ពស់ផងដែរសម្រាប់ការផ្តួចផ្តើម និងអនុវត្តការផ្លាស់ប្តូរសាលារៀនតាមរយៈការប្រើប្រាស់ព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍(ICT) នឹងអាចជួយសម្រួលដល់ការសម្រេចចិត្តដ៏ស្មុគស្មាញដើម្បីបញ្ចូលវាទៅក្នុងការសិក្សការបង្រៀន និងរដ្ឋបាលសាលា។ តួនាទីជាអ្នកដឹកនាំគឺជាកត្តាសំខាន់តែមួយគត់ដែលជះឥទ្ធិពលដល់ការធ្វើសមាហរណកម្មបច្ចេកវិទ្យា ប្រកបដោយជោគជ័យ (Byrom & Bingham, ២០០១) ។

នាយកសាលាមានការទទួលខុសត្រូវដ៏សំខាន់សម្រាប់ការផ្តួចផ្តើមគំនិតនិងអនុវត្តការផ្លាស់ប្តូរសាលារៀនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ។ នាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជោគជ័យការផ្លាស់ប្តូរសាលារៀន (Schiller, ២០០៣)។ ដូចដែលបានបញ្ជាក់ខាងលើនាយកសាលាមានតួនាទីសំខាន់ក្នុងការធ្វើសមាហរណកម្មបច្ចេកវិទ្យា (Wilmore & Betz, 2000) ។ តួនាទីនេះមានសារៈសំខាន់ណាស់ក្នុងការជួយគ្រូបង្កើតបរិយាកាសរៀនសូត្រ ដ៏ល្អសម្រាប់សិស្សានុសិស្សនាពេលបច្ចុប្បន្ននេះ។ ស្របតាមគំនិតនេះ(Wilmore & Betz ,2000) បានថ្លែងថា បច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានអនុវត្តដោយជោគជ័យនៅក្នុងសាលារៀនតែប៉ុណ្ណោះប្រសិនបើនាយកសាលាគាំទ្រវាយ៉ាងសកម្មក៏ដូចជាផ្តល់ការអភិវឌ្ឍ និងការគាំទ្រជំនាញគ្រប់គ្រាន់ដល់បុគ្គលិករបស់គាត់កំពុងស្ថិតក្នុងដំណើរការផ្លាស់ប្តូរ ។ ហេតុដូច្នេះហើយនាយកសាលាគឺជាអ្នកដឹកនាំ ដ៏សំខាន់ម្នាក់នៃការផ្លាស់ប្តូរនៅឯកម្រិតសាលា ។

ដោយផ្អែកទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ដែលបានចេញផ្សាយនៅក្នុងឆ្នាំ ២០០៤ បានលើកឡើងថា៖ "នៅ ក្នុង ការ អប់រំ របស់ ក្រសួង អប់រំ យុវជន និងកីឡាផ្តោតការយកចិត្តទុកដាក់ចំពោះផែនសំខាន់ៗ ចំនួន៤" ៖

**ផែនទី១** ៖ បង្កលក្ខណៈឲ្យគ្រូ និងសិស្សគ្រប់រូប ទាំងអស់ជាពិសេសនៅកម្រិត មធ្យមសិក្សា បានប្រាស្រ័យប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដោយធានា អះអាងថា បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ពិតជាត្រូវបានប្រើប្រាស់ជាយានជួយកាត់បន្ថយ គំលាតឌីហ្សីថល រវាងសាលារៀនកម្ពុជា ជាមួយនឹង សាលារៀន ផ្សេងៗ ទៀត នៅប្រទេស ជិតខាង ។

**ផែនទី២** ៖ សង្កត់ធ្ងន់ទៅលើតួនាទី និង មុខងាររបស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជាឧបករណ៍សម្រាប់រៀន និងបង្រៀនទៅតាមមុខវិជ្ជាផ្សេងៗ ក៏ជាមុខវិជ្ជាដោយឡែកផងដែរ ។

ការ ទទួល ព័ត៌មាន តាម អ៊ិ ន ធឺ ណែ ត បណ្តាញ ព័ត៌មាន អន្តរជាតិ និងការ ប្រាស្រ័យ ទាក់ទង គ្នាដែលកាន់តែ សកម្ម តាម រយៈ អ៊ីមែល (សារ អេ ឡិច ត្រូ និ ច ) រវាង សាលារៀន ជាមួយ សាលារៀន និងរវាង បុគ្គលជាមួយ បុគ្គល នោះ អាច បំពេញមុខ នាទី យ៉ាងសំខាន់ នៅ ក្នុង ការ អភិវឌ្ឍន៍ អាជីព ជូន អ្នក អប់រំ ។ ក្រៅពី វិទ្យុ និង ទូរទស្សន៍ ដែល ជា ឧបករណ៍ សម្រាប់ រៀន និងបង្រៀន ដែរនោះគោលនយោបាយ នេះ

ក៏ បាន សង្កត់ធ្ងន់ ទៅ លើ ការ ប្រើប្រាស់ កុំព្យូទ័រ សម្រាប់ ទទួលយក ព័ត៌មាន បង្កើន ពុទ្ធិ និង ជំនាញ ផ្សេងៗ សម្រាប់ ប្រាស្រ័យ ទាក់ទង គ្នា ដើម្បី ផ្លាស់ ប្ដូរ ព័ត៌មាន ផងដែរ ។

**ផែនទី៣** ៖ លើក កម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នាតាមរយៈការអប់រំពីចម្ងាយ និងស្វ័យសិក្សា ជាពិសេសគឺនៅក្នុងចំណោមក្រុមកុមារ ក្រុមជំទង់ និងក្រុមជនពេញវ័យជួបការលំបាកដែលបាត់បង់ ឱកាស ចូល សិក្សា នៅ កម្រិត គោលនយោបាយ និងយុទ្ធសាស្ត្រ ប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ ក្នុង ការ អប់រំ នៅ កម្ពុជា អប់រំ មូលដ្ឋាន រួម មាន អក្ខរកម្ម និង បណ្ដុះបណ្ដាល បំ ណិ ន ដោយ មិន គិត ពី អាយុ ភេទ ជនជាតិភាគតិច ពិការ ភាព ឬ ទីកន្លែងដោយ គួបផ្សំ ជាមួយ នឹងវិទ្យុទូរទស្សន៍ ឯកសារបោះពុម្ព និងប្រព័ន្ធ ផ្សព្វផ្សាយ ព័ត៌មានចំរុះ ។

**ផែនទី ៤** ៖ សង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើម្បី លើកកម្ពស់ ផលិតភាព ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពការគ្រប់គ្រងអប់រំ ។ តាម រយៈ ការ ប្រើប្រាស់ ប្រព័ន្ធព័ត៌មាន គ្រប់គ្រង នេះ នឹងត្រូវ បានប្រើប្រាស់ កាន់តែច្រើន ដើម្បីធ្វើអោយការងារមានល្បឿនលឿនជាងមុនរួម មានការកត់ត្រាលទ្ធផលបំពេញមុខងាររបស់គ្រូ និងសិស្សការប្រាស្រ័យទាក់ទង ព័ត៌មាន រវាងរដ្ឋាភិបាល ជាមួយនឹង សាលារៀន កិច្ច តែង ការ បង្រៀន ការ វាយតម្លៃ ការ ធ្វើ តែ ស ការ គ្រប់គ្រង ហិរញ្ញវត្ថុ និង ការ ថែរក្សា បញ្ជី សារពើពន្ធ ។

យ៉ាងណាមិញ បើយោងតាមសៀវភៅគោលនយោបាយ និងយុទ្ធសាស្ត្រស្ដីពីបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចេញផ្សាយនៅក្នុងឆ្នាំ ២០១៨ បានកំណត់គោលដៅយុទ្ធសាស្ត្រសំខាន់ចំនួនពីរៈ

**គោលដៅទីមួយៈ** ផ្តោតទៅលើការគ្រប់គ្រង និងបែបបទការងារថ្មី ដើម្បីធ្វើទំនើបកម្មការអនុវត្ត ការងារ និងបង្កើនប្រសិទ្ធភាព តម្លាភាព ភាពស័ក្តិសិទ្ធិនៃអភិបាលកិច្ច និងការពិនិត្យតាមដានលទ្ធផល ការងារក្នុងវិស័យអប់រំ។

**គោលដៅទីពីរៈ** គឺផ្តោតទៅលើការបញ្ជ្រាបបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឱ្យក្លាយជា ឧបករណ៍សម្រាប់ការបង្រៀននិងរៀននិងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំទាំងមូលសំដៅបំប៉នសិស្ស និស្សិតនូវចំណេះដឹង និងបំណិនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីធ្វើអន្តរកាលទៅរកពិភព ការងារក្នុងសតវត្សទី២១។

យោងតាម(Reynolds et al,2003) បានបង្ហាញថា បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) បានជួយអភិវឌ្ឍជំនាញការគិតរបស់គ្រូ និងសិស្ស និងបានធ្វើឲ្យបរិយាកាសថ្នាក់រៀនកាន់តែគួរឲ្យចង់សិក្សា និងទាក់ទាញ។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) បានជួយឲ្យគ្រូ និងសិស្សនូវការផ្ទេរពីភាពលំបាក់នៃការសិក្សាទៅជាភាពងាយស្រួល និងរហ័សក្នុងការចេះវិនិច្ឆ័យ ត្រិះរិះ និងជំនាញស្រាវជ្រាវទៀតផង។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក៏បានជួយសិស្សក្នុងការជំរុញឲ្យកាន់តែចូលចិត្តសិក្សាតាមរយៈកម្មវិធីសប្បាយៗ ងាយៗជាច្រើនទៀត នៅក្នុងបរិយាកាសនៃការសិក្សា។

អ្នកស្រាវជ្រាវនឹងលើកភស្តុតាង ក៏ដូចជាទ្រឹស្តីមួយចំនួនបន្ថែមទៀត សម្រាប់បង្ហាញអំពីការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងការបង្រៀន និងរៀនក្នុងជំពូកទី២។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងដូចខាងក្រោម៖

១. ស្វែងយល់ពីស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់គណៈគ្រប់គ្រង និងគ្រូបង្រៀនក្នុងការគ្រប់គ្រង និងការបង្រៀន។

២. រកឲ្យឃើញពីបញ្ហាប្រឈមផ្សេងៗនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ក្នុងការបង្រៀន និងការគ្រប់គ្រងនៅតាមវិទ្យាល័យនានាក្នុងខេត្តរតនគិរី។

## ១.៤ សំណួរស្រាវជ្រាវ

ការសិក្សានេះត្រូវធ្វើឡើងនៅតាមសាលាកម្រិតមធ្យមសិក្សាទុតិយភូមិដើម្បីឆ្លើយនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. តើគណៈគ្រប់គ្រង និងគ្រូបង្រៀនបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងការគ្រប់គ្រង និងការបង្រៀនយ៉ាងដូចម្តេច?

២. តើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រងរបស់នាយក និងការបង្រៀនមានជាបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសន្និដ្ឋានបានសង្កេតឃើញថាការសិក្សាស្រាវជ្រាវទៅលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) គឺជាកត្តាសំខាន់និងចម្បងមួយសម្រាប់ ជួយដល់ស្ថាប័ណ្ណពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡាក្នុងការរៀបចំឲ្យកាន់តែមានប្រសិទ្ធភាពលើគោលនយោបាយនោះ។

១. ការស្រាវជ្រាវនឹងជួយឲ្យអ្នកស្រាវជ្រាវស្វែងយល់ឲ្យកាន់តែច្បាស់ទៅលើវិសាលភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិសារគមនាគមន៍ (ICT) នៅតាមសាលារៀនសាធារណៈនៅខេត្តរតនគិរី ជាពិសេសអ្នករៀបចំគោលនយោបាយទៅលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ។

២. ការស្រាវជ្រាវ និងជួយទៅដល់អ្នកធ្វើកម្មវិធីសិក្សា អ្នកធ្វើគោនយោបាយនៃក្រសួងអប់រំក្នុងប្រទេសកម្ពុជា គ្រូបង្រៀន និងសិស្សផងដែរ សម្រាប់ការអភិវឌ្ឍបច្ចេកទេសព័ត៌មាន និងសារគមនាគមន៍នៅតាមសាលារៀន។

៣. ការស្រាវជ្រាវនេះផងដែរ និងជួយដល់សិស្ស គ្រូ និងអ្នកបង្កើតនយោបាយ បានជា ឱកាសក្នុងការប្រៀបធៀបអំពីទស្សនៈទៅលើ បច្ចេកទេសព័ត៌មានវិទ្យា និងសារគមនាគមន៍ នៅតាម សាលារៀនក្នុងខេត្តផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ។

៤. ការស្រាវជ្រាវនឹងផ្តល់ឲ្យអ្នកគ្រប់គ្រង់ និងអ្នបង្កើតគោលនយោបាយអបរំ កាន់តែមានវិធីសាស្រ្តដ៏សមស្របក្នុងការផ្លាស់ប្តូរឲ្យកាន់តែរីកចម្រើនក្នុងប្រព័ន្ធអប់រំ ក្នុងខេត្តរតនគិរីក៏ដូចជាប្រទេសកម្ពុជាទាំងមូល ។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការសិក្សាស្រាវជ្រាវដំណើរការទៅបានល្អ និងមានប្រសិទ្ធភាពព្រមទាំងមានការវិភាគគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ "ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍(ICT)ក្នុងការបង្រៀន និងការគ្រប់គ្រងនៅតាមវិទ្យាល័យនៃខេត្តរតនគិរី អ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យ

ចំនួន ០៨ ក្នុងខេត្តរតនគិរី យកមកសិក្សា ។

ការស្រាវជ្រាវនេះនឹងធ្វើការជួបផ្ទាល់ជាមួយនាយកសាលាទាំង ០៨ គ្រូបង្រៀនតាមមុខវិជ្ជាចំនួន ៩៦ នាក់ និងសិស្សានុសសិស្ស ៩៦នាក់សម្រាប់ថ្នាក់ទី១០ ១១ និង ១២ក្នុងសាលានីមួយៗនៃខេត្តរតនគិរី ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានចែកចេញជា ៥ ជំពូកដូចខាងក្រោមៈ

**ជំពូកទី១ៈសេចក្តីផ្តើមៈ** ជំពូកនេះនឹងពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ៈ រំឭកទ្រឹស្តីៈ** ធ្វើការបង្ហាញ និងពន្យល់យ៉ាងលម្អិតទៅលើទ្រឹស្តីទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)។

**ជំពូកទី៣ៈ វិធីសាស្ត្រនៃការស្រាវជ្រាវៈ** ជំពូកនេះនឹងលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រងនៃការវិភាគ ការកំណត់ពេលវេលា និងទីកន្លែងដែលត្រូវសិក្សា ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគសំណាក ការប្រើប្រាស់ឧបករណ៍ស្រង់ស្ថិតិ និងការប្រើរូបមន្តសម្រាប់គណនា។

**ជំពូកទី៤ៈ លទ្ធផលនិងការពិភាក្សាៈ** ជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគយ៉ាងលម្អិតទៅលើកម្រងសំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែង ដើម្បីរកឲ្យឃើញពីកម្រិតនៃស្ថានភាពប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដូចគ្នាទៅនិងបញ្ហាប្រឈមនានាក្នុងការបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី។

**ជំពូកទី៥ៈសេចក្តីសន្និដ្ឋាននិងសមណូមពរៈ** អ្នកសស្រាវជ្រាវនិងធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់ជាយោបល់ទៅលើចំណុចត្រូវកែលម្អ ឬ ចំណុចខ្វះខាត។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

យោងទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំបានលើកឡើងថាៈ ភាពចាំបាច់ក្នុងការបង្កើនការប្រើប្រាស់ ICT ក្នុងការងារគ្រប់គ្រង និងអភិបាលកិច្ចជា ប្រចាំរបស់ក្រសួងក្នុងការបង្រៀន និងរៀន តម្រូវឲ្យមានការពង្រឹងសមត្ថភាពគាំទ្រផ្នែក ICT ក្នុងក្រសួងអប់រំយុវជន និងកីឡាទាំងមូល ។ ការគាំទ្រនេះគឺចាំបាច់ណាស់សម្រាប់គ្រប់គ្រងស្ថានការណ៍ វិវឌ្ឍន៍ផ្នែក ICT ដែលមានការប្រែប្រួលគួរឱ្យកត់សម្គាល់នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងដើម្បី ពង្រីកការប្រើប្រាស់ ICT ក្នុងក្របខ័ណ្ឌ ក្រសួងអប់រំ យុវជន និងកីឡា។

ដោយមើលឃើញពីការប្រែប្រួលយ៉ាងឆាប់រហ័សក្នុងវិស័យអប់រំនៅកម្ពុជាអ្នកស្រាវជ្រាវ និងសិក្សាស្រាវជ្រាវទៅលើស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) នៅតាមវិទ្យាល័យនីមួយៗក្នុងខេត្តរតនគិរីនៅភាគឦសាននៃប្រទេសកម្ពុជា ។ ការសិក្សានេះផ្តោតទៅលើដំណើរការនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT)ក្នុងការគ្រប់គ្រងរបស់នាយក និងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវ នឹងលើកឡើងទាក់ទងទៅនឹងកាប្រើប្រាស់និងកត្តាប្រឈមផ្សេងៗទៅលើការ បង្រៀន និងការគ្រប់គ្រងនៅ តាមវិទ្យាល័យនៃខេត្តរតនគិរី ។

នៅក្នុងចំណុចចាប់ផ្តើមដំបូងអ្នកស្រាជ្រាវនិងលើកឡើងនូវនិយមន័យនៃពាក្យគន្លឹះមួយចំនួនដែលទាក់ទងនឹងប្រធាបទខាងលើ ។ ការរៀបរាប់នេះ និងបង្ហាញអំពីសារៈសំខាន់ជាច្រើនទៀតដែលនឹងសរសេររៀបរាប់បន្ថែមទៅតាមចំណុចដែលបានបែងចែកក្នុងជំពូកនេះ។

នៅក្នុងចំណុចនិយមន័យអ្នកស្រាវជ្រាវ នឹងបង្ហាញយ៉ាងច្បាស់នៃទ្រឹស្តី ដែលនឹងរៀបរាប់ អំពី បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដែលជាទូទៅត្រូវបានបែងចែកវា ជាបីផ្នែកធំៗ។

## ២.២ និយមន័យ

នៅក្នុងបរិបទនៃបំរែបំរួលសង្គម បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យអប់រំ ក្នុងនោះ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ក៏ដូចជាគណៈគ្រប់គ្រងក៏ត្រូវមានការផ្លាស់ប្តូរវិធីសាស្ត្រនៃការគ្រប់គ្រង ការបង្រៀន និងរៀនដើម្បីអោយស្របតាមកម្មវិធីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដែលក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញ។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT ) អាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនក្នុងការគាំទ្រដល់ការរៀនសូត្រ។ (Adi Suryani, 2010)។

តើអ្វីទៅជា ICT?

បើយោងតាមគេហទំព័រ( world-breaking-news.blogspot.com )បានលើកឡើងថា៖ ពាក្យICT គឺជាពាក្យផ្លូវការមួយមកពីពាក្យពេញ Information Communication Technology ដែលគ្របយកក្រុមនៃឧបករណ៍ ឬ កម្មវិធីអាចទំនាក់ទំនងគ្នាបាន ក្នុងនោះមានដូចជា ៖ ប្រព័ន្ធកុំព្យូទ័រ ឧបករណ៍កុំព្យូទ័រ ទូរស័ព្ទនិងកម្មវិធីកុំព្យូទ័រ ។

**I = Information** ៖ គឺចង់ផ្តោតទៅលើការផ្ទុកនិងគ្រប់គ្រងទិន្នន័យឲ្យបានលក្ខណៈសុក្រឹតរៀបរយទៅតាមប្រភេទទិន្នន័យនីមួយៗ និងអនុញ្ញាតឲ្យគេងាយទាយយកទិន្នន័យមកប្រើប្រាស់បានយ៉ាងឆាប់រហ័សបំផុត ។ កម្មវិធីប្រើសម្រាប់ការរក្សាទុកទិន្នន័យទាំងអស់នោះមានដូចជា Ms. Access, SQL Server, My SQL,Oracle,MDX និងកម្មវិធីជាច្រើនទៀត។

**C = Communication** ៖ ការបង្កើតទំនាក់ទំនងដោយប្រព័ន្ធអេឡិចត្រូនិចរវាងឧបករណ៍និងឧបករណ៍ ឬ កម្មវិធីនិងកម្មវិធី មានដូចជា៖ Video Conference ការសិក្សាពីចម្ងាយ ការបញ្ជូនទិន្នន័យពីកន្លែងមួយ

ទៅកន្លែងមួយទៀត ប្រព័ន្ធពិគ្រោះយោបល់សុខភាពប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិច (E-Library), ប្រព័ន្ធ ប្រាប់បញ្ចូលគ្នា រវាងប្រព័ន្ធទូរស័ព្ទនិងកុំព្យូទ័រ អាចឲ្យយើង Call ពីកុំព្យូទ័រទៅទូរស័ព្ទដៃបាន (VOIP= Voice Over Internet Protocol) និងការជជែកកម្សាន្តនៅលើអ៊ីនធឺណេតជាដើម។ ឧបករណ៍ឬបច្ចេកវិទ្យាប្រើសម្រាប់ការទំនាក់ទំនងខាងលើមានដូចជា ការប្រើបណ្តាញអ៊ីនធឺណេតជាដើម។

ឧបករណ៍ ឬបច្ចេកវិទ្យាប្រើសម្រាប់ការទំនាក់ទំនងខាងលើមានដូចជា ការប្រើបណ្តាញកុំព្យុទ័រ (Networking), ការភ្ជាប់ដោយមិនចាំបាច់ប្រើខ្សែ (Wireless Networking) និងបណ្តាញអ៊ីនធឺណេតជាដើម ។

**T = Technology៖** មានន័យថាជាការបញ្ជូនទិន្នន័យ បង្កើតទំនាក់ទំនង ផ្ទុកទិន្នន័យ ការគណនា បញ្ចូលទិន្នន័យ និងទាញទិន្នន័យពីកម្មវិធីដែលផ្ទុកមកវិញដោយបច្ចេកវិទ្យា ។

បច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ។

យើងអាចនិយាយបានថា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ជាពាក្យមួយដែលបានក្តោបរួមទៅនឹងឧបករណ៍ជាច្រើនដែលរួមមានឧបករណ៍ និងកម្មវិធីទំនាក់ទំនងជាច្រើនបង្កប់នៅក្នុងនោះ។

នៅក្នុងនោះដែរ គេបានបែងចែក ICT ជាពីរផ្នែកគឺ ផ្នែករឹង និងផ្នែកទន់។ ផ្នែករឹង (Hard ware) សំដៅទៅលើសមាសធាតុកាយរបស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារទូរគមនាគមន៍ណាមួយ។ ឧបករណ៍នៃផ្នែករឹងនៅក្នុងកុំព្យូទ័រគឺ ខួរក្បាល ឧបករណ៍ដំណើរការ អង្គចងចាំ ម៉ូនីទ័រ ព្រីបធ័រ ក្តារចុច កណ្តុរ និងអង្គភាពដំណើរការកណ្តាល។ ចំណែក ឧបករណ៍ផ្នែករឹង ផ្សេងទៀតមានដូចជា វិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃថេបផ្លេត ។ល។ ផ្នែកទន់(Software) គឺជាការប្រមូល ផ្តុំនៃការណែនាំនីតិវិធីឯកសារដែលបំពេញភារកិច្ចផ្សេងៗគ្នាលើប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារទូរគមនាគមន៍ណាមួយដែល យើងអាចនិយាយបានថាកម្មវិធីទាំងនេះគឺជាកូដសរសេរ ដែលបានសរសេរសម្រាប់ប្រព័ន្ធប្រត្តិបត្តិការ។ ឧបករណ៍កម្មវិធីគឺ Ms Word Excel Power point Google Chrome MySQL។ ល ។ លើសពីនេះទៀត

ប្រព័ន្ធផ្កាយរណប និងឧបករណ៍ដទៃ ផ្សេងទៀតដូចជា សេវាកម្មផ្សេងៗ និងកម្មវិធីដែលបាន ដាក់បញ្ចូលគ្នា ក៏យើងអាចចាត់ទុកថាជា ចបច្ចេកវិទ្យាព័ត៌មាន និងសារទូរគមនាគមន៍ ( videoconferencing and Distance learning ) ផងដែរ។

សរុបមក ICT គឺជាបច្ចេកវិទ្យា ទាំងឡាយណាដែលអ្នកស្រាវជ្រាវ ឬអ្នកវិទ្យាសាស្ត្របង្កើតឡើង ដើម្បីផ្ទុកទិន្នន័យ បញ្ជូនទិន្នន័យ និងទំនាក់ទំនងនៅក្នុងស្ថាប័នមួយ តំបន់មួយ និងឆ្លងពីតំបន់មួយទៅតំបន់មួយទៀត ក្នុងនោះគេក៏អាចហៅ ICT ជា IT ក៏បានដែរ ។ តែទោះជាយ៉ាងណាមនុស្សមួយចំនួនបាន គិតផ្សេងៗគ្នាទៅ លើពាក្យនេះ ហើយក៏មិនបានបែងចែកទៅតាម ផ្នែកនីមួយៗរបស់វាដែរ។

## ២.៣. ការប្រើប្រាស់បច្ចេកវិទ្យាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀន

### ២.៣.១. ប្រសិទ្ធភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើតួនាទីគ្រូបង្រៀន

ក្នុងបរិបទសព្វថ្ងៃនេះ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍បានក្លាយជាចំណុចសំខាន់នៃអន្តរកម្មបង្រៀន - រៀនតាមរយៈវិធីសាស្ត្រដូចជាការជំនួសក្តារចុចដោយក្តារចុចឌីជីថលអន្តរកម្ម ។ សិស្សប្រើទូរស័ព្ទស្មាតហ្វូនផ្ទាល់ខ្លួន ឬឧបករណ៍ផ្សេងទៀតសម្រាប់សិក្សា ដែលសិស្សមើលការបង្រៀននៅផ្ទះនៅលើកុំព្យូទ័រ ឬទូរស័ព្ទស្មាតហ្វូនហើយប្រើពេលវេលា ក្នុងថ្នាក់រៀនសម្រាប់លំហាត់អន្តរកម្មពីចម្ងាយ។

នៅពេលដែលគ្រូមានចំណេះដឹងផ្នែកឌីជីថល និងបណ្តុះបណ្តាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ វិធីសាស្ត្រទាំងនេះអាចនាំឱ្យមានជំនាញគិតគូរកាន់តែខ្ពស់ ផ្តល់ជម្រើសប្រកបដោយភាពច្នៃប្រឌិត និងលក្ខណៈបុគ្គលសម្រាប់សិស្សដើម្បីបង្ហាញការយល់ដឹងរបស់ពួកគេហើយទុកឱ្យសិស្សត្រៀមខ្លួនកាន់តែប្រសើរក្នុងការដោះស្រាយជាមួយនឹងការផ្លាស់ប្តូរបច្ចេកវិទ្យា ដែលកំពុងបន្តកើតមាននៅក្នុងសង្គម។

តាមភាពជាក់ស្តែងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍របស់គ្រូបង្រៀននិងសិស្សហាក់នៅមានភាពចម្រូងចម្រាស់នៅឡើយ ។ ខណៈគ្រូមួយចំនួនបានបញ្ចូលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ចូលទៅក្នុងថ្នាក់រៀន និងការបង្រៀន និងរៀនរបស់ពួកគេយ៉ាងមានប្រសិទ្ធភាព ចំណែកគ្រូមួយចំនួនបាន ព្យាយាមកែប្រែការបង្រៀនរបស់ពួកគេ ដោយដាក់បញ្ចូល បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ មួយផ្នែកជាចំណែកនៃការបង្រៀន។

អ្នកខ្លះគឺមិនបានប្រកែកក្នុងការទទួលយកការបង្រៀននិងរៀនដោយប្រើICT ក្នុងថ្នាក់រៀនរបស់ពួកគេ ។ ជាការពិតតួនាទីរបស់គ្រូត្រូវបង្រៀន សិស្ស ឲ្យទទួលបាននូវខ្លឹមសារនៃមេរៀនមួយដ៏មានប្រសិទ្ធភាព សមស្របទៅនឹងវត្ថុបំណងដែលបានរំពឹងទុក្ខ ប៉ុន្តែគ្រូមិនអាចប្រើតែអ្វីដែលធ្លាប់ប្រើជាច្រើនឆ្នាំមកហើយនោះទេ។ ដូចគ្នាជាមួយសិស្សផងដែរ ពួកគាត់ត្រូវខិតខំពុះពារសម្រាប់ទាញយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ធ្វើជាផលប្រយោជន៍ ដើម្បីប្រើប្រាស់ក្នុងការសិក្សារបស់ពួកគាត់។

បច្ចេកវិទ្យាកុំព្យូទ័រអាចផ្លាស់ប្តូរតួនាទីរបស់គ្រូពីអ្នកផ្តល់ព័ត៌មានទៅជាអ្នកសម្របសម្រួលអ្នកផ្តល់យោបល់អ្នកប្រឹក្សាយោបល់អ្នកណែនាំគ្រូបង្វឹកអ្នកសិក្សាអ្នកណែនាំអ្នកគ្រប់គ្រងធនធាននិងបច្ចេកវិទ្យា និងអ្នកសម្របសម្រួលដល់សិស្ស (Jonassen et al , 1999) ។ គ្រូបង្រៀននាសតវត្សថ្មីនេះត្រូវតែទាក់ទង និងការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ ពួកគាត់ត្រូវតែផ្លាស់ប្តូរដើម្បីដើរឲ្យទាន់ការវិវត្តន៍ថ្មីៗនៃសង្គម និងពិភពលោក ។ ការរៀបរាប់នៅក្នុងការរំលឹកទ្រឹស្តីនេះ នឹងជួយឲ្យអ្នកស្រាវជ្រាវស្វែងរកនូវនីតិវិធីផ្សេងៗក្នុងការប្រើប្រាស់សំណួរក្នុងការស្រាវជ្រាវនៅក្នុងបរិបទនៃការបង្រៀនរបស់គ្រូនិង ការគ្រប់គ្រងរបស់នាយក។ មិនតែប៉ុណ្ណោះក៏អាច ជួយដល់អ្នកបង្កើតគោលនយោបាយដែលចង់បានទិន្នន័យដែលមានក្នុងការស្រាវជ្រាវនេះក្នុងការស្វែងយល់ពីស្ថានភាពប្រើប្រាស់ ក៏ដូចជាការអនុវត្ត បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ក្នុងការសិក្សារបស់សិស្សផងដែរ ( ស្វ័យសិក្សា) ។

### ២.៣.២ ប្រសិទ្ធភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើតួនាទីរបស់នាយក

ទោះជាយ៉ាងណាក៏ដោយដើម្បីឲ្យដំណើរការនៃការបង្រៀន និងរៀនមានប្រសិទ្ធភាព នាយកសាលាក៏ដូចជាអ្នកដឹកនាំសាលា ក៏មានការទទួលខុសត្រូវខ្ពស់ផងដែរសម្រាប់ការផ្តួចផ្តើមនិងអនុវត្តការផ្លាស់ប្តូរសាលារៀនតាមរយៈការប្រើប្រាស់ព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍ (ICT) និងអាចជួយសម្រួលដល់កិច្ចការចាំបាច់ផ្សេងៗ នៅក្នុងការសិក្សា បង្រៀននិងរដ្ឋបាលសាលា។

តួនាទីជាអ្នកដឹកនាំគឺជាកត្តាសំខាន់តែមួយគត់ដែលជះឥទ្ធិពលដល់ការធ្វើសមាហរណកម្មបច្ចេកវិទ្យាប្រកបដោយជោគជ័យ (Byrom & Bingham, ២០០១) ។ នាយកសាលាមានការទទួលខុសត្រូវដ៏សំខាន់សម្រាប់ការផ្តួចផ្តើមគំនិត និងអនុវត្តការផ្លាស់ប្តូរសាលារៀនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ហើយជួយសម្រួលដល់ការសម្រេចចិត្តស្មុគស្មាញអំពីការធ្វើសមាហរណកម្ម ប្រសិទ្ធភាពការកែលំអរសាលារៀន និងការផ្លាស់ប្តូរផ្សេងៗ ។ នាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជោគជ័យការផ្លាស់ប្តូរសាលារៀន (Schiller, ២០០៣)។ ដូចដែលបានបញ្ជាក់ខាងលើនាយកសាលាមានតួនាទីសំខាន់ក្នុងការធ្វើសមាហរណកម្មបច្ចេកវិទ្យា **(Wilmore & Betz, 2000)** ។ តួនាទីនេះមានសារៈសំខាន់ណាស់ ក្នុងការជួយគ្រូបង្កើតបរិយាកាសរៀនសូត្រដ៏ល្អសម្រាប់សិស្សានុសិស្សនាពេលបច្ចុប្បន្ននេះ។ ស្របតាមគំនិតនេះ (Wilmore & Betz ,2000) បានថ្លែងថា" បច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានអនុវត្តដោយជោគជ័យនៅក្នុងសាលារៀនតែប៉ុណ្ណោះប្រសិនបើនាយកសាលាគាំទ្រវាយ៉ាងសកម្មក៏ដូចជាផ្តល់ការអភិវឌ្ឍ និងការគាំទ្រជំនាញគ្រប់គ្រាន់ដល់បុគ្គលិករបស់គាត់កំពុងស្ថិតក្នុងដំណើរការផ្លាស់ប្តូរ ។ ហេតុដូច្នេះហើយនាយកសាលាគឺជាអ្នកដឹកនាំដ៏សំខាន់ម្នាក់នៃការផ្លាស់ប្តូរនៅឯកម្រិតសាលា។

### ២.៣.៣ ការបកស្រាយផ្សេងៗពីប្រសិទ្ធភាពនៃការប្រើប្រាស់ ICT ក្នុងការបង្រៀន

ដើម្បីក្លាយជាអ្នកប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាដែលមានទំនុកចិត្តនៅក្នុងថ្នាក់រៀនគ្រូបង្រៀនត្រូវមានការចូលរួមក្នុងការបណ្តុះបណ្តាលជាបន្តបន្ទាប់ ។ គ្រូបង្រៀនគួរតែយល់ពីអត្ថប្រយោជន៍នៃអក្ខរ

កម្មឪជីថល ។ ការបណ្តុះបណ្តាលផ្នែកអាយស៊ីធីចាំបាច់ត្រូវមានការទទួលស្គាល់ជាចាំបាច់សម្រាប់ការបង្រៀនជំនាញ និងជាការជម្រុញការអនុវត្តការបង្រៀននិងរៀន (Infodev.org)។

គ្រូបង្រៀនទាមទារអោយមានការប្រាស្រ័យទាក់ទងយ៉ាងទូលំទូលាយជាមួយអាយស៊ីធីដើម្បីអាចវាយតម្លៃនិងជ្រើសរើសធនធានដែលសមស្របបំផុត ទោះយ៉ាងណាការអភិវឌ្ឍការអនុវត្តគរុកោសល្យសមស្របត្រូវបានគេមើលឃើញថាសំខាន់ជាងជំនាញបច្ចេកទេសនៃអាយស៊ីធី។ ការបណ្តុះបណ្តាលមួយដងគឺមិនគ្រប់គ្រាន់ទេសាលារៀនត្រូវការវិនិយោគ និងអនុវត្តការបណ្តុះបណ្តាលដែលមានរយៈពេលវែងនិងការអភិវឌ្ឍជំនាញជាបន្តដើម្បីឱ្យទាន់បច្ចេកវិទ្យាឌីជីថលដែលមានការវិវត្តយ៉ាងឆាប់រហ័ស។

បើតាមការសរសេរអំពីប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគកមន៍យើង បានរៀបរាប់ច្រើនអំពី អត្ថប្រយោជន៍របស់ ICT ក្នុងការបង្រៀន និងរៀនក្នុងវិស័យអប់រំ។ នៅជុំវិញពិភពលោកយើងនេះមានអ្នកសិក្សាស្រាវជ្រាវជាច្រើនផងដែរបានសិក្សាស្រាវជ្រាវទៅលើ ប្រសិទ្ធភាពទាំងនេះ ។ ចំណុចជាច្រើនដែលអ្នកស្រាវជ្រាវនឹងយកមកបង្ហាញខាងក្រោម នឹងសរសេរអំពីការស្រាវជ្រាវរបស់មនុស្សមួយចំនួន ដែលបានចំណាយពេលសិក្សាស្រាវជ្រាវ លើប្រធានបទនេះ ហើយការបង្ហាញនេះក៏ជាភស្តុតាងបញ្ជាក់ឲ្យឃើញកាន់តែច្បាស់ថាការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានធ្វើឲ្យមានភាពរីកចម្រើននៃការបង្រៀន និងរៀន។ គ្រូបង្រៀនត្រូវការឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈជាក់លាក់ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការវាយតម្លៃការបង្រៀនជាលក្ខណៈបុគ្គល ការទទួលបានធនធានតាមអ៊ិនធឺណេតនិងសម្រាប់ជម្រុញអន្តរកម្មសិស្សនិងការសហការគ្នា ។ វាក៏ជះឥទ្ធិពលដល់ឥរិយាបថទូទៅរបស់គ្រូចំពោះបច្ចេកវិទ្យាព័ត៌មាន នៅក្នុងថ្នាក់រៀនប៉ុន្តែវាក៏គួរតែផ្តល់ការណែនាំជាក់លាក់លើការបង្រៀននិងរៀន ICT នៅក្នុងវិន័យនីមួយៗ ។ បើគ្មានការគាំទ្រនេះទេគ្រូមានទំនោរប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សម្រាប់ការអនុវត្តផ្អែកលើជំនាញកំណត់ការគិតរបស់និស្សិត(Smeets, E. 2005) ។ ចំពោះគ្រូបង្រៀននៅពេលពួកគេផ្លាស់ប្តូរការបង្រៀនវាក៏ចាំបាច់សម្រាប់អ្នកគ្រប់គ្រងការអប់រំ អ្នកមើលការខុសត្រូវអ្នកអប់រំគ្រូ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។ គ្រូគួតែត្រូវបាន

បណ្ដុះបណ្ដាលក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (Chapman, D., and Mählck, L. Eds. 2004)ដើម្បីធានាបាននូវអត្ថប្រយោជន៍នៃការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT)។

បើតាមលោក Beauchamp (2008) បានរកឃើញថា គ្រូបង្រៀនត្រូវទាញយកធនធាន ដ៏ច្រើន សន្ទឹកសន្ធាប់ដែលពួកគេអាចរកបានសម្រាប់គោលដៅជាក់លាក់ ដើម្បីបំពេញតាមតម្រូវការរបស់សិស្ស។ ទោះយ៉ាងណាសិស្សចាំបាច់ត្រូវមានជំនាញកម្រិតណាមួយនៃ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីដោះស្រាយជាមួយបច្ចេកវិទ្យាហើយលោកគ្រូ អ្នកគ្រូគួរតែជួយដល់សិស្សនូវកិច្ចការ សំខាន់ៗជាជាង់រង់ចាំ សិស្សឲ្យចុចប៊ូតុងកុំព្យូទ័រ ឬទូរស័ព្ទដើម្បីឆ្លើយតបនឹងសំណួរងាយៗពីគ្រូ។ ហេតុដូច្នេះហើយមានន័យថាគ្រូ បង្រៀនត្រូវតែសកម្មជាងសិស្សនិងបង្ហាញដល់សិស្សប្រកបដោយទំនុកចិត្ត។

ដើម្បីបញ្ជាក់ពីតួនាទីគ្រូក្នុងការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អ្នកស្រាវជ្រាវ ខ្លះបានពិចារណាទៅលើសមត្ថភាពគ្រូចំពោះ ICT ជាឧទាហរណ៍លោក Nico Ruttena និងលោក Wouter (2012) បានបង្ហាញពីការប្រើប្រាស់កុំព្យូទ័រ លោកបាននិយាយថា « ការបង្រៀននៅក្នុងថ្នាក់ រៀនអាចទទួលបានជោគជ័យ លើកលែងតែយើងមានជំនាញច្បាស់លាស់ » ។ ពួកគាត់បានបន្ថែមទៀត ថា « ប្រសិនបើគ្រូ និងសិស្សមិនមានជំនាញ និងមានសក្ដានុពលក្នុងការប្រើប្រាស់កុំព្យូទ័រទេ វាប្រហែល ជាធ្វើឲ្យការបង្រៀនមិនបានទទួលលទ្ធផលជាគោលដៅនោះឡើយ » ។ ម្យ៉ាងវិញទៀត តួនាទីរបស់គ្រូ បង្រៀនផ្ដោតទៅលើ មូលដ្ឋានគ្រឹះនៃគរុកោសល្យ ហើយការប្រើប្រាស់កុំព្យុទ័រសម្រាប់ការបង្រៀនតាម មុខវិជ្ជាត្រូវតែគួរបានអនុវត្តន៍។

ឆ្លងតាមការស្រាវជ្រាវមួយចំនួនបានអង្កេតឃើញថា មានភាពលំបាកសម្រាប់កាប្រើប្រាស់ ICT របស់គ្រូក្នុងការបង្រៀន ។ ពួកគេបានបង្ហាញថាការលំបាកក្នុងការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារ គមនាគមន៍ គឺទាក់ទងទៅនឹងភាពទន់ខ្សោយនៃចំណេះដឹងរបស់គ្រូបង្រៀន អំពីបច្ចេកវិទ្យាហើយនឹង លទ្ធភាពដែលពួកគេអាចប្រើប្រាស់បាន នៅក្នុងថ្នាក់រៀននិងសម្ថភាពប្រើប្រាស់របស់សិស្សផងដែរ ។

លើសពីនេះទៅទៀតគ្រូត្រូវដឹងអំពី ទំនាក់ទំនងរបស់បច្ចេកវិទ្យា ក្នុងការ ជួយសម្រួលទៅលើការសិក្សា (Morrisa, 2011) ។

ជាដំណោះស្រាយគ្រូបងង្រៀនចាំបាច់ត្រូវមានទំនុកចិត្តខ្ពស់ក្នុងការយល់ដឹងក៏ដូចជាជំនាញក្នុងការជំរុញឲ្យសិស្សស្វែងយល់ពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីដាក់បញ្ចូលមុខវិទ្យាទាំងនោះនៅក្នុងថ្នាក់រៀន។ ដូច្នោះហើយតម្រូវការនេះបានប្រែក្លាយជាការអភិវឌ្ឍដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបង្កើត ជំនាញគ្រូបង្រៀន (Ward and Parr,2010) ។

តាមការស្រាវជ្រាវបន្ថែមមួយទៀតបានផ្តោតទៅលើលក្ខណៈសម្បត្តិដែលគ្រូបង្រៀនទទួលបានពីការអនុវត្តនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ Hennessy et al., (2007) បាន អះអាងថា គ្រូនឹងទទួលបានអត្ថប្រយោជន៍ពី ICT ដែលជួយគាំទ្រដល់សិស្ស ដើម្បីបង្កើតទំនាក់ទំនងក្នុង ទ្រឹស្តីវិទ្យាសាស្រ្ត និងភស្តុតាងជាក់ស្តែង ។ ករណីការលើកឡើងផ្សេងទៀត តាមរយៈលោក Greene (2008) បានយល់ឃើញថា ការកង្វះធនធាន ICT ជាក់លាក់សម្រាប់កម្មវិធីសិក្សា ជាកត្តារួមមួយ ។ បន្ថែមមួយផ្សេងទៀត គាត់បានជឿជាក់ថាគ្រូ និងសិស្សជាទូទៅពួកគាត់មានជំនាញ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប៉ុន្តែពួកគេមិនបានទាញយកផលប្រយោជន៍ដូចៗគ្នា ក្នុងការប្រើប្រាស់ធនធានអនឡាញ ។ លើសពីនេះលោក Greene បានរកឃើញថា គ្រូបង្រៀនត្រូវការការបណ្តុះបណ្តាលសមស្របអំពីរបៀបប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការបង្រៀននិងការរៀន។

ទោះយ៉ាងណាគ្រូបង្រៀនត្រូវផ្លាស់ប្តូរពីរបៀបនៃការបង្រៀនតាមបែបប្រពៃណីទៅជាគ្រូបង្រៀនបែបគរុកោសល្យអន្តរកម្មជាមួយនិងអន្តប្រយោជន៍ ដែលផ្តល់ឲ្យដោយ ICT (Tanner et al., 2005 )។ យោងទៅតាមការបង្ហាញទាំងនេះយើងអាចកំណត់សម្គាល់បានថាតើគួរធ្វើដូចម្តេចក្នុងការធ្វើឲ្យតួនាទីគ្រូបង្រៀនមានការរីកចម្រើនក្នុងកាប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងនោះក៏មានសិស្សានុសិស្សផងដែរ។

ទាក់ទងទៅនិងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លោក Chen & Wu ( 2012 ) បានកត់សម្គាល់ថាគ្រូបង្រៀនគួរតែផ្តល់នូវឱកាសសម្រាប់ជួយសិស្សហើយក៏នឹងផ្តោតលើវិធីដែលសិស្សអាចរៀន និងពន្យល់ដល់ខ្លួនគេថាការធ្វើខុសនៅក្នុងមេរៀន គឺជាផ្នែកមួយនៃដំណើរការ ការសិក្សា។ម្យ៉ាងវិញទៀត ជុំវិញការប្រើប្រាស់ ICT គួរតែផ្តោតទៅលើវិធីប្រើប្រាស់ដ៏ស៊ីជម្រៅទៅលើសម្ភារៈដែលមានទំនាក់ទំនងទៅនឹងភាពជាក់ស្តែងដើម្បីធ្វើឲ្យសិស្សរៀនពីរបៀបដើម្បីបង្កើនជំនាញ និងទទួលបានចំណេះដឹង ។ ស្រដៀងគ្នានេះដែរ លោក Mukama & Anderron ( 2008 ) បានចង្អុលបង្ហាញថាការរៀនសូត្រនៅក្នុងបរិស្ថាននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គឺស្រដៀងនឹងដំណើរមួយ ហើយគ្រូដែលទើបតែចូលប្រឡូកក្នុងវិជ្ជាជីវៈមួយនេះជារឿយៗបានផ្តល់នូវទស្សនៈថ្មីៗ។

បើតាមទស្សនៈផ្សេងមួយទៀតរបស់លោក Beauchamp និងលោក Kennewell ( 2010 ) បានយល់ឃើញថា កំណែទម្រង់ភាគច្រើននៃការរៀនសូត្របានដឹកនាំដោយគ្រូ និងប្រព័ន្ធសូហ្វវែ ( software ) ហើយសិស្សគួរតែមានតួនាទីយ៉ាងសំខាន់ចំពោះការតម្រែតម្រង់នៃធនធាន ។ លើសពីនេះទៀតកាន់តែមានសារៈសំខាន់ណាស់សម្រាប់ គ្រូនិងសិស្សចេះប្រើប្រាស់ ICT ស្របពេលដែលពួកគេនៅឆ្ងាយពីប្រភពធនធាន ICT។ ជាឧទាហរណ៍ដូចជាលទ្ធផលនៃសកម្មភាពរៀន ជាមួយសិស្សដ៏ទៃទៀតនៅក្នុងថ្នាក់រៀន ឬ ក៏នៅពេលទំនេររបស់ពួកគេ ( Cox and Marshall,2007 ) ។ ជាក់ស្តែងទស្សនវិស័យបែបនេះបានអំពាវនាវ ឬទាក់ទាញ ឲ្យមានការចូលរួមរបស់សិស្សក្នុងការរៀនសូត្ររបស់ពួកគេផ្ទាល់នៅពេលអនុវត្តន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ ប្រសិទ្ធភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ស្តីពីតួនាទីរបស់គ្រូអាចបានបង្ហាញ ឲ្យឃើញយ៉ាងច្បាស់តាមរយៈការសិក្សាថាតើអ្នកដែលអនុវត្តតាមលើរបៀបប្រើប្រាស់មុខងាររបស់ (ICT) អាចគាំទ្រដល់ការរៀនសូត្រយ៉ាងដូចម្តេច ? ( Hennessy et al, 2007 )

នៅក្នុងការសិក្សារបស់លោក Kennewell ( 2005 ) គាត់បានរកឃើញនៅក្នុងការសិក្សារបស់គាត់នៅសាលារៀនក្នុងប្រទេសវែលដែលគ្រូបានអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ និងជោគជ័យទាំងខ្លឹមសារគរុកោសល្យនៃវគ្គសិក្សា តាមរយៈការធ្វើសមាហរណកម្មបុគ្គល និងសហប្រតិបត្តិការនៃបច្ចេកវិទ្យា

គមនាគមន៍ និងព័ត៌មាន ( ICT ) ទៅក្នុងកម្មវិធីបង្រៀនរបស់ពួកគេ។ ការរកឃើញរបស់គាត់គាំទ្រគំនិត ដែលថាគ្រូ គឺជាអ្នកដឹកនាំដំណើរការសិក្សានៅក្នុងថ្នាក់រៀន។

មានអ្នកលើកឡើងចំនួនបួននាក់ផ្សេងៗគ្នាហើយពួកគេបានកត់សម្គាល់ថាមានយោបល់ល្អៗពីគ្រូមួយចំនួនធំទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការអប់រំ ។ លើសពីនេះទៀតពួកគេបានលើកឡើងថា ICT មានប្រយោជន៍ខ្លាំងណាស់សម្រាប់សិស្ស និងបានជួយក្នុងការអភិវឌ្ឍដំណើរការនៃការសិក្សាដូចជា ការយកចិត្តទុកដាក់លើវត្តមាន និងយន្តការឆ្លើយតបក្នុងការរៀនសូត្រនិងការយល់ដឹងនិងការបញ្ជូនព័ត៌មានដើម្បីជួយសម្រួលដល់ចំណេះដឹងរបស់សិស្ស។ ទោះយ៉ាងណាក៏ដោយពួកគេក៏បានរកឃើញនូវចំណុចអវិជ្ជមានមួយចំនួនដូចជា ការបញ្ចេញមតិ និងជំនាញទំនាក់ទំនងដែលបង្ហាញថាមិនមែនគ្រូទាំងអស់សុទ្ធតែប្រកាន់ខ្ជាប់នូវបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទាំងស្រុងនោះទេ ។ ជាការសន្និដ្ឋានអាកប្បកិរិយារបស់គ្រូ គឺសំខាន់ណាស់នៅក្នុងដំណើរការអប់រំហើយការកង្វះចំណាប់អារម្មណ៍ ដែលបង្ហាញដោយគ្រូមួយចំនួនមានឥទ្ធិពលអាក្រក់ទៅលើ ដំណើរការអប់រំនៅក្នុងថ្នាក់រៀន និងសិស្ស ។

ដើម្បីពិនិត្យមើលសារៈប្រយោជន៍នៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការអប់រំភស្តុតាងចាំបាច់ត្រូវពិនិត្យពីទូទាំងពិភពលោក។ ទោះយ៉ាងណាមានមតិជាច្រើនរបស់លោក Liao ( 2004 ) ដែលបានលើកឡើងដោយការសិក្សាខ្លះបានបង្ហាញថា « ការណែនាំនៅក្នុងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ គឺមានប្រយោជន៍ » ការប្រើប្រាស់ ICT មានភាពវិជ្ជមានជាងចំពោះការបង្រៀនតាមបែបប្រពៃណីនៅប្រទេសតៃវ៉ាន់។ ការសិក្សារបស់ជនជាតិតៃវ៉ាន់នេះត្រូវបានគាំទ្រដោយការសិក្សារបស់ជនជាតិចិន ( Zhou, Hu&,Gao,2010 ) តាមរយៈ Shaanxi Normal University ។

ការសិក្សានៃកម្មវិធីសិក្សារួមបញ្ចូលគ្នាបានបង្ហាញ ការប្រើប្រាស់សំណួរដោយប្រើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទូទាំងកម្មវិធីសិក្សារបស់សាលាគឺមានសារៈសំខាន់ណាស់ ( Ward & Parr, 2010 ) ។ ការសិក្សារបស់ពួកគាត់នៅក្នុង ប្រទេស New Zealand បានដាក់ចេញនូវសម្មតិកម្មពីរ។

ទីមួយ មុខវិទ្យាសិក្សាសំខាន់និងការបង្រៀនរបស់ពួកគេច្រើនតែបង្ហាញនៅសាលា។ លើសពីនេះមុខវិជ្ជាទាំងនោះច្រើនតែមានគុណវុឌ្ឍិផ្តោតទៅលើអ្វីដែលឆ្លុះបញ្ចាំងលើសាលារៀន ។ ដូច្នេះពួកគេគិតថាសាលារៀនមិនមានបំណងបង្កើតអ្វីថ្មីជាមួយនឹងការផ្លាស់ប្តូរនៃការអនុវត្ត ឬ ការប្រើប្រាស់កុំព្យូទ័រឡើយ។ ទីពីរ ពួកគេគិតថាសូម្បីតែកន្លែងដែលមាន«គោលនយោបាយសាលាទាំងមូល» ក៏អាចមានការបកស្រាយខុសគ្នាដែរ ទៅតាមកម្រិតផ្នែកនិងគ្រូនីមួយៗ។

ការសិក្សាខ្លះបានលើកឡើងថា គ្រូគឺជាកូនសោរសម្រាប់ការរៀបចំនិងការតម្រែតម្រង់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងថ្នាក់ព្រោះថាសមាសធាតុទាំងពីរមានឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបដែលសិស្សរៀន ( Sang et all., 2010 ) ហើយនេះអាចជះឥទ្ធិពលដល់ការយល់ឃើញរបស់សិស្ស

នៃបច្ចេលវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅក្នុងថ្នាក់រៀន។ លើសពីនេះទៀតប្រភពនេះលើកឡើងនូវ

អំណះអំណាងថាឥរិយាបថរបស់គ្រូគួរតែត្រូវបានខិតខំបន្ថែម។ ភស្តុតាងនេះបានបង្ហាញថាវត្តមានរបស់គ្រូគឺជាកត្តាចាំបាច់នៅក្នុងការពិនិត្យមើលការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់សិស្សនៅក្នុងថ្នាក់រៀន។

ទោះជាយ៉ាងណាក៏ដោយភាពជាក់លាក់មួយ នៃការសិក្សាផ្នែកលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ថ្មីៗនេះ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកជំនាញផ្នែកអប់រំ និងអ្នកស្រាវជ្រាវ។ ឧទាហរណ៍ការសិក្សាត្រូវបានធ្វើឡើងដើម្បីកំណត់ឥរិយាបថរបស់គ្រូបង្រៀន ដែលផ្តោតទៅរកបច្ចេកវិទ្យាបង្រៀនទាក់ទងនឹងការផ្លាស់ប្តូរឯករាជ្យមួយចំនួនដូចជា យេនឌ័រ ឯកទេសកម្ម និងបទពិសោធន៍ជាច្រើន។

## ២.៣.៤. ការ អភិវឌ្ឍន៍ ផ្នែក បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ ក្នុង ការ បណ្តុះបណ្តាល គ្រូបង្រៀន

យោងទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសាគមនាគមន៍ក្នុងការអប់រំ របស់ក្រសួងអប់រំយុវជន និងកីឡាបោះពុម្ព នៅឆ្នាំ២០០៤ បានលើកឡើងថា៖

នាពេលថ្មីៗកន្លងមកនេះ ក្រសួង អប់រំ យុវជន និងកីឡាបានបង្ហាញសក្តីភាពនៃការប្តេជ្ញាចិត្តមោះមុតលើកកម្ពស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅក្នុងការអប់រំដោយបានតម្រូវអោយគរុសិស្សទាំងអស់រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ចំនួន២ម៉ោងក្នុងមួយសប្តាហ៍ចាប់ពីឆ្នាំ២០០៣តរៀងទៅ ។ ចំនួនកុំព្យូទ័រនៅតាមសាលាគរុកោសល្យនានាបានកើនឡើងគួរអោយចាប់អារម្មណ៍ចាប់តាំងពីឆ្នាំ២០០៣ ។កុំព្យូទ័រមួយចំនួនក្នុងចំណោមកុំព្យូទ័រ ទាំងនោះ បាន មក ពី ការ ចំណាយ ថវិកា ផែនការ សកម្មភាព ជា អាទិភាព និង មួយ ចំនួន ផ្សេង ទៀត បាន មក ពី ប្រភព ជំនួយ ផ្សេងៗ ។បរិមាណ កុំព្យូទ័រ បាន កើន ច្រើន គួរ អោយ កត់សំគាល់ ហើយ គ្រប់ សាលា គរុកោសល្យ ទាំងអស់ សុទ្ធតែ មាន បន្ទប់ បណ្តុះបណ្តាល ការ ប្រើប្រាស់ កុំព្យូទ័រ រៀងៗ ខ្លួន ។នៅ ក្នុង ឆ្នាំ ២០០៣ នេះ ផលធៀប គរុសិស្ស -កុំព្យូទ័រ នៅ តាម មជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ និង សាលា គរុកោសល្យ និង វិក្រឹត ការ ខេត្ត -ក្រុង មាន ៦៥% ។ផលធៀប នេះ បាន ថយ ចុះ នៅ ត្រឹម ៣២%នៅ ក្នុង ឆ្នាំ ២០០៤ ។ប្រការ នេះ បាន ជួយ បង្ក លក្ខណៈ អោយ ស្ថាប័ន គរុកោសល្យ ទាំងឡាយ អាច ចាប់ផ្តើម វគ្គ បណ្តុះបណ្តាល បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ រៀងៗ ខ្លួន ។ប៉ុន្តែ សាលា គរុកោសល្យ ទាំងអស់ ពុំ មែន សុទ្ធតែ មាន កុំព្យូទ័រ គ្រប់គ្រាន់ សម្រាប់ បង្រៀន វគ្គ បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ អោយ មាន ប្រសិទ្ធភាព នោះ ឡើយ ។សាលា ខ្លះ ជួប បញ្ហា គ្មាន ថាមពល អគ្គិសនី គ្រប់គ្រាន់ ដែល ជា ហេតុ តម្រូវ អោយ គេ ពឹងផ្អែក លើ ម៉ាស៊ីនភ្លើង ឬ តម្រូវ អោយ ផ្អាក រាល់ ការ ប្រើប្រាស់ ធនធាន អគ្គិសនី ផ្សេងៗ ទៀត ឬ សុំ អោយ ការិយាល័យ ផ្សេងៗ ទៀត ត្រូវ បិទ ចរន្តអគ្គិសនី ហើយ និង ផ្អាក ការងារ ខ្លួន ជា បណ្តោះអាសន្ន សិន ដើម្បី បង្ក លក្ខណៈ អោយ បន្ទប់រៀន កុំព្យូទ័រ អាច ដំណើរការ រៀន បាន ។

នៅ ដើមខែ កញ្ញា ឆ្នាំ ២០០៤ គ្រូឧទ្ទេស ចំនួន ជាង ពាក់កណ្តាល នៃ គ្រូឧទ្ទេស ទាំងអស់ ៦០០ នាក់ មក ពីសា លា គរុកោសល្យ និង វិក្រឹ ត ការ ខេត្ត -ក្រុង ទាំង ១៨ និង មជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ

ទាំង ៦ បាន ឆ្លងកាត់ វគ្គ បណ្តុះបណ្តាល បំណិន បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ ជា មូលដ្ឋាន និង ប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ នៅ ក្នុង ការងារ រដ្ឋបាល និង ការ បង្រៀន និង ការ រៀន ។ គ្រូឧទ្ទេស មួយ នាក់ មក ពីសា លា គរុកោសល្យ នីមួយៗ បាន ឆ្លងកាត់ វគ្គ បណ្តុះបណ្តាល អោយ ចេះ បង្កើត វេប សាយ សាមញ្ញ ដំបូង មួយ ហើយ និង បាន ដាក់ បញ្ចូល គេហទំព័រ រៀងខ្លួន ទៅ ក្នុង វេប សាយ ក្រសួង អប់រំ យុវជន និង កីឡា ។ដោយឡែក ពី នេះ គ្រូឧទ្ទេស មួយ នាក់ មក ពី មជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ ទាំងអស់ និង វិទ្យាស្ថាន ជាតិ អប់រំ បាន ផ្តើម បង្កើត ធនធាន រៀន តាម វេប សាយ និង ចក្ខុ សោត ទស្សន៍ សម្រាប់ មធ្យមសិក្សា តាមរយៈ សិក្ខាសាលា បណ្តុះ បណ្តាល មួយ ហើយ និង បាន ឆ្លងកាត់ វគ្គ បណ្តុះបណ្តាល ថៃរក្សា និង ជួសជុល កុំព្យូទ័រ នៅ ក្នុង ឆ្នាំ ២០០៤ នេះ ។

កម្មវិធី សិក្សា មួយ សម្រាប់ រៀន បច្ចេកវិទ្យាព័ត៌មាន និង សារ គមនាគមន៍ នៅ ក្នុង ការ បង្រៀន និង រៀន កំពុង តែ ត្រូវ បាន អភិវឌ្ឍ សម្រាប់ សាលា គរុកោសល្យ ខេត្ត -ក្រុង និង មជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ ។ កម្មវិធី សិក្សា នេះ នឹង មាន បញ្ចូល ការ ប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ សម្រាប់ ការងារ រដ្ឋបាល ការ អភិវឌ្ឍន៍ អាជីព បង្រៀន និង សម្រាប់ បង្កើត ធនធាន បង្រៀន ជា ភាសា ខ្មែរ ផង ដែរ ។នៅ កម្រិត មធ្យមសិក្សា វិញ នោះ គេ នឹង ត្រូវ ប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និង សារ គមនាគមន៍ ដើម្បី ពង្រឹងការ បង្រៀន ទៅ តាម មុខ វិជ្ជា ។

### ២.៣.៥ ការបកស្រាយផ្សេងៗពីប្រសិទ្ធភាពនៃការប្រើប្រាស់ ICT ក្នុងការគ្រប់គ្រងសាលា

គោលបំណងនៃការសិក្សានេះគឺដើម្បីពិនិត្យមើលថាតើមានការជាប់ទាក់ទងគ្នារវាងអាកប្បកិរិយា របស់នាយកឆ្ពោះទៅរកការអនុវត្ត ICT និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិទ្យានៅសាលានិង ថាតើមានទំនាក់ទំនងរវាងទម្រង់គ្រប់គ្រងរបស់នាយកសាលានិងកម្រិតនៃការអនុវត្ត ICT នៅក្នុងសាលា។

ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងប្រព័ន្ធអប់រំដែលត្រូវបានបង្ហាញឱ្យឃើញក្នុងរយៈពេល ប៉ុន្មានឆ្នាំចុងក្រោយនេះគឺការរួមបញ្ចូលបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងចំណោមបុគ្គលិកបង្រៀន និងសិស្ស (Gaitanaru, 2014) ។ អ្នកស្រាវជ្រាវជាច្រើនជឿថានាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើ

សមាហរណកម្ម ICT (Wasserman & Milligram, ២០០៥; Peled, Kelly និង Dori, ២០១១)។

អថេរជាច្រើនដែលទាក់ទងនឹងនាយកសាលាអាចប៉ះពាល់ដល់ការអនុវត្ត ICT ។ អថេរទាំងនេះរួមមានកម្រិតចំណាប់អារម្មណ៍ចម្បងការចូលរួមរបស់គាត់នៅក្នុងអ្វីគ្រប់យ៉ាងដែលទាក់ទងនឹងការធ្វើសមាហរណកម្ម ICT ចំនួនទឹកប្រាក់នៃការខិតខំប្រឹងប្រែងដែលគាត់វិនិយោគក្នុងការកៀងគរធនធានសម្រាប់តម្រូវការដែលគាត់បានកំណត់ និងរង្វាន់ដែលគាត់បានបង្កើតទាក់ទងនឹងគ្រប់ផ្នែកនៃការធ្វើសមាហរណកម្មអាយធីអាយធី (Peled, Kelly និង Dori, ២០១១; Meyudsar, Nachmias, Farkash និង Tobin, ២០០៣)។

ដោយសារតួនាទីសំខាន់របស់នាយកសាលាគេអាចសន្មតថាឥរិយាបថរបស់នាយកសាលាគឺជាអថេរដែលពាក់ព័ន្ធក្នុងការអនុវត្តការផ្លាស់ប្តូរជាទូទៅ និងក្នុងការអនុវត្តបច្ចេកវិទ្យាព័ត៌មានវិទ្យាជាពិសេស។ គោលបំណងនៃការសិក្សានេះគឺដើម្បីពិនិត្យមើលថាតើមានការជាប់ទាក់ទងគ្នារវាងអាកប្បកិរិយារបស់នាយកឆ្ពោះទៅរកការអនុវត្ត ICT និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិទ្យានៅសាលានិងថាតើមានទំនាក់ទំនងរវាងទម្រង់គ្រប់គ្រងរបស់នាយកសាលា និងកម្រិតនៃការអនុវត្ត ICT នៅក្នុងសាលា។

ស្របតាមគំនិតនេះWilmore និង Betz (២០០០) បានថ្លែងថា" បច្ចេកវិទ្យាព័ត៌មាន នឹងត្រូវបានអនុវត្តន៍ដោយជោគជ័យនៅក្នុងសាលារៀន ប្រសិនបើនាយកសាលាគាំទ្រវាយ៉ាងសកម្ម ក៏ដូចជាផ្តល់ការអភិវឌ្ឍនិងការគាំទ្រជំនាញគ្រប់គ្រាន់សម្រាប់បុគ្គលិករបស់គាត់ដែលកំពុងស្ថិតក្នុងដំណើរការផ្លាស់ប្តូរ។ ហេតុដូច្នេះហើយនាយកសាលាគឺជាអ្នកដឹកនាំដ៏សំខាន់ម្នាក់នៃការផ្លាស់ប្តូរនៅឯកម្រិតសាលារៀន។

អ្នកគ្រប់គ្រងអប់រំ គួរពង្រឹងសមត្ថភាពបច្ចេកវិទ្យាដើម្បីមានសមត្ថភាពផ្ទាល់ខ្លួនក្នុងការប្រើប្រាស់និងអាចលើកកម្ពស់វប្បធម៌សាលារៀនលើកទឹកចិត្តឱ្យបុគ្គលិកស្វែងយល់ពីបច្ចេកទេសថ្មីៗក្នុងការបង្រៀន ការរៀនសូត្រនិងការគ្រប់គ្រង (Schiller, ២០០៣)។ ដូច្នេះសាលារៀនត្រូវការអ្នកដឹកនាំដែលអាចជួយសម្រួលដល់ដំណើរការផ្លាស់ប្តូរនិងគាំទ្រសហគមន៍រៀនផ្នែកបច្ចេកវិទ្យា។

លោក Fullan (២០០៣)បានលើកឡើងថា៖ គ្មានការផ្លាស់ប្តូរទ្រង់ទ្រាយធំ ឬការខិតខំប្រឹងប្រែងកែទម្រង់សាលារៀនណាបានឈានទៅមុខដោយគ្មានការគាំទ្រពីថ្នាក់ដឹកនាំសាលានោះទេ។ ស្រដៀងគ្នានេះដែរលោក Schiller បានថ្លែងថា" នាយកសាលាមានតួនាទីសំខាន់ក្នុងការសម្របសម្រួលនៃការផ្លាស់ប្តូរការអប់រំ។

សាលាមួយអ្នកគ្រប់គ្រងត្រូវមានចំណេះដឹងអំពីបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) និងដឹងអំពីអ្វីដែលត្រូវស្វែងរកនៅក្នុងថ្នាក់រៀនប្រសិនបើមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពការវាយតំលៃរីការគាំទ្រគ្រូនៅថ្នាក់រៀនគឺត្រូវធ្វើ ។ ទស្សនៈនេះត្រូវបានគាំទ្រដោយ (Hope, Kely, ២០០០) ដែលបានកត់សម្គាល់ថាអ្នកដឹកនាំសាលាគួរតែប្រើបច្ចេកវិទ្យាដោយខ្លួនឯងដើម្បីអភិវឌ្ឍការយល់ដឹង របៀបដែលបច្ចេកវិទ្យាអាចត្រូវបានប្រើនិងយកគំរូតាមការអនុវត្តន៍ទៅបុគ្គលិកសាលា។

ស្រដៀងគ្នានេះដែរលោក (Stegall,១៩៩៨) បានបញ្ជាក់ថាវាមានសារៈសំខាន់ណាស់សម្រាប់នាយកសាលាក្នុងការប្រើប្រាស់កុំព្យូទ័រស្វែងរកជំនួយនិងយោបល់ពីអ្នកជំនាញពីបច្ចេកវិទ្យា។

ដូច្នេះការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលនឹងទទួលបានជោគជ័យនៅក្នុងសាលានឹងតម្រូវឱ្យអ្នកដឹកនាំដឹងអំពីលទ្ធភាព និងអនាគតការអភិវឌ្ឍបច្ចេកវិទ្យា និងវិធីដែលសាលាអាចបញ្ចូលវាទៅក្នុងការបង្រៀន និងការរៀនសូត្រក្នុងនាមជាអ្នកដឹកនាំ នាយកសាលាត្រូវតែបង្កើតលក្ខខណ្ឌការគាំទ្រដើម្បីជំរុញការធ្វើសមាហរណកម្មនៃបច្ចេកវិទ្យា (MacNeil & Delafield, ១៩៩៨) ។ នាយកសាលា គួរតែបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់បច្ចេកវិទ្យាព័ត៌មានវិទ្យសមស្រប (ការអភិវឌ្ឍបុគ្គលិកជំនាញសម្រាប់សមាជិកបុគ្គលិករបស់ពួកគេ។

នាយកសាលាត្រូវតែដើរតួមិនត្រឹមតែក្នុងការគាំទ្របច្ចេកវិទ្យាប៉ុណ្ណោះទេប៉ុន្តែថែមទាំងជួយសម្រួលដល់ការផ្លាស់ប្តូរនិងយុទ្ធសាស្ត្រអន្តរាគមន៍នានាផងដែរដើម្បីសម្រួលដល់ដំណើរការបង្រៀន - រៀន (Schiller, ២០០៣) ។ ជាមួយគ្នានេះដែរលោកបានបញ្ជាក់ថានាយកសាលាត្រូវតែធ្វើការសហការជាមួយគ្រូ

បង្រៀន បុគ្គលិកដើម្បីដឹកនាំការធ្វើសមាហរណកម្មបច្ចេកវិទ្យានៅក្នុងសាលារបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

នាយកសាលាត្រូវតែដើរតួជាគំរូហើយពួកគេគួរតែជាអ្នកប្រើបច្ចេកវិទ្យាព័ត៌មានដែលមានសមត្ថភាព។ ដូចដែលបានរៀបរាប់ខាងលើអ្នកដឹកនាំដែលកំពុងប្រើប្រាស់បច្ចេកវិទ្យា នៅពេលពួកគេកំពុងសិក្សាទ្រឹស្តីគឺពួកគេភាគច្រើនទទួលបានជោគជ័យ នៅការយល់ពីICTហើយបន្ទាប់មកដាក់វានៅក្នុងបរិបទនៃការបង្រៀននិងការរៀន ។ អ្នកដឹកនាំត្រូវតែដឹងរបៀបប្រើបច្ចេកវិទ្យាដើម្បីផ្លាស់ប្តូរការអនុវត្តដើម្បីឈានដល់គោលដៅថ្មីជាកំលាំងជំរុញសម្រាប់ការផ្លាស់ប្តូរនិងជាឧបករណ៍ក្នុងការបង្កើត ការអនុវត្តការគ្រប់គ្រង និងទំនាក់ទំនងទស្សនៈថ្មីនៃការបង្រៀននិងការរៀនសូត្រ

## ២.៤.ការជះឥទ្ធិពលនៃបច្ចេកវិទ្យាព័ត៌មានវិទ្យានិងសារគមនាគមន៍ទៅលើមុខវិជ្ជា សិក្សា

ដោយអ្នកស្រាវជ្រាវមើលឃើញពីភាពចាំបាច់នៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងការបង្រៀន និងរៀន ហើយភាគច្រើន គឺមានភាពទូលំទូលាយស្ទើគ្រប់មុខវិជ្ជា ជាពិសេសភាសាបរទេស ( ភាសាអង់គ្លេស ) ។

ការប្រើប្រាស់បច្ចេកវិទ្យាមាន មានឥទ្ធិពលវិជ្ជមានលើការបង្រៀន និងរៀនភាសាអង់គ្លេស។

បច្ចេកវិទ្យាអាចត្រូវបានអនុវត្តទៅនឹងការអនុវត្តការបង្រៀនដើម្បីពង្រឹង និងសម្រួលដល់ភាសាបរទេស។ កុំព្យូទ័រ អ៊ិនធឺណិត ក្តារឆ្លាតវៃ ទូរសព្ទដៃ វីដេអូហ្គេម ម៉ាស៊ីនចាក់តន្ត្រី ជាដើមគឺត្រូវបានប្រើក្នុងដំណើរការសិក្សាភាសាគោលដៅ ដើម្បីបង្កើនការលើកទឹកចិត្ត និងការយល់ដឹង របស់សិស្ស (Altun, 2015) ។ ការអនុវត្ត ICT នឹងនាំឱ្យមានភាពចម្រុះនៃមាតិកាភាសាអង់គ្លេស បរិបទ និងវិធីសាស្រ្តគរុកោសល្យក្នុងបរិយាកាសបង្រៀន។ ការអនុវត្តការប្រើប្រាស់ ICT ក្នុងការសិក្សាភាសាអង់គ្លេសបង្កើតបរិយាកាសទាក់ទាញ បត់បែន និងច្នៃប្រឌិត។ (Qin and Shuo, 2011)។

## ២.៥. សារៈសំខាន់ជាអន្តរជាតិនៃគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

នៅពេលដែលយើងឈានចូលដល់ សតវត្សទ២១មានការយកចិត្តទុកដាក់ជាអន្តរជាតិចំពោះតួនាទីដែលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អាចដើរតួក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម និងការអប់រំ។ ចំណុចនេះត្រូវបានគេដឹងថា ភាគច្រើននៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍របស់ពិភពលោកដែលបច្ចេកវិទ្យាបានជះឥទ្ធិពលដល់ អាជីវកម្ម សាលារៀន និងគេហដ្ឋាន ហើយដែលបានផ្លាស់ប្តូររបៀបដែលមនុស្សធ្វើការរៀនសូត្រ និងកិច្ចការផ្សេងៗ។

ឥទ្ធិពលនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) បានកើតមាននៅក្នុងប្រទេសអភិវឌ្ឍន៍ ហើយសក្តានុពល សម្រាប់ការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់បន្ថែមទៀតត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯសារគោលនយោបាយនៃប្រទេសជាច្រើន។ ឧទាហរណ៍ មេដឹកនាំនៃប្រទេសប្រជាធិបតេយ្យឧស្សាហកម្មដ៏សំខាន់ទាំងប្រាំបីរបស់ពិភពលោក ( G8 Heads of State,2020 ) បានកត់សម្គាល់ថា ICT បានក្លាយជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចពិភពលោក និងមានសក្តានុពលក្នុងការចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ ពង្រឹងប្រជាធិបតេយ្យ បង្កើនតម្លាភាពក្នុងអភិបាលកិច្ច បំប៉នភាពចម្រុះនៃវប្បធម៌ និងដើម្បីជំរុញសន្តិភាព និង ស្ថេរភាពអន្តរជាតិ។ ក្នុងពេលដំណាលគ្នានេះដែរ ប្រមុខរដ្ឋទាំងនេះបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាពឆ្លើយតបទៅ នឹងតម្រូវការនៃយុគសម័យព័ត៌មាននិងដើម្បីលើកកម្ពស់ចំណេះដឹងនិងជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន តាមរយៈការអប់រំ ការបណ្តុះបណ្តាល និងការរៀនសូត្រពេញមួយជីវិត។

អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ( ២០០១-២០០៦ ) ក៏បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃសេដ្ឋកិច្ច និងឥទ្ធិពលនៃបច្ចេកវិទ្យា ព័ត៌មាន សារគមនាគមន៍ ( ICT ) នៅក្នុងប្រទេសអភិវឌ្ឍន៍និងចង្អុលបង្ហាញពីតម្រូវការសម្រាប់ប្រទេសទាំងនោះ ដើម្បីអភិវឌ្ឍកម្លាំងពលកម្មដែល

មានជំនាញនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ដើម្បីបង្កើនផលិតភាពក៏ដូចជាតម្រូវការសម្រាប់យុវជនដើម្បីអភិវឌ្ឍជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ក្នុងការរៀបចំសម្រាប់មនុស្សពេញវ័យ។ ប៉ុន្តែវាមិនត្រឹមតែ មេដឹកនាំនៃប្រទេសអភិវឌ្ឍន៍ប៉ុណ្ណោះទេដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ អង្គការសហប្រជាជាតិនិងធនាគារពិភពលោកអង្គភាពទាំងពីរបានគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ( ICT ) ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រទេសក្រីក្របំផុតលើពិភពលោក។

ធនាគារពិភពលោក ( ២០០៣ ) បានដកស្រង់របាយការណ៍ដែលមានសក្តានុពលនៃ ICT ដើម្បីកែលម្អការផ្តល់ធនធានប្រកបដោយប្រសិទ្ធភាពដល់ជនក្រីក្រ នាំទីផ្សារទៅដល់សហគមន៍ជនបទ ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មរបស់រដ្ឋាភិបាល និង ដើម្បីផ្ទេរចំណេះដឹងដែលត្រូវការដើម្បីសម្រេចគោលដៅសហស្សវត្សរ៍ ( Millennium Development Goals ) ។ ប្រមុខរដ្ឋអាហ្វ្រិក ( African Union,2004 ) ព្រមគ្នាដោយលើកឡើងពីសក្តានុពលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការជំរុញពាណិជ្ជកម្ម ធ្វើឲ្យប្រសើរឡើងនូវការថែទាំសុខភាព លើកកម្ពស់អភិបាលកិច្ចល្អ និង ធ្វើឲ្យការអប់រំកាន់តែមានប្រសើរឡើង ។ នៅក្នុងចំណុចនេះដែរ ធានាគារពិភពលោក បានចេញរបាយការណ៍ដោយបានកត់សម្គាល់ថាបច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍ ( ICT ) អាចបង្កើតលទ្ធភាពទទួលបានការអប់រំតាមរយៈការរៀនសូត្រពីចម្ងាយ ជួយឲ្យមានចំណេះដឹង សម្រាប់សិស្ស បណ្តុះបណ្តាល គ្រូនិងពង្រីកលទ្ធភាពទទួលបានសម្ភារៈអប់រំដែលមានគុណភាព។ នៅក្នុងកិច្ចប្រជុំកំពូលពិភពលោកស្តីពីសង្គម ព័ត៌មាន អង្គការសហប្រជាជាតិ(២០០៥) កត់សម្គាល់សក្តានុពលនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពដើម្បីលើកកម្ពស់អក្ខរកម្ម និងដើម្បីគាំទ្រដល់ការអប់រំបឋមសិក្សាជាសកលនៅ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រទេសជាច្រើនត្រូវបានសន្យាថានឹងទទួលយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ដើម្បីដោះស្រាយតម្រូវការសេដ្ឋកិច្ចនិងសង្គម

របស់ពិភពលោកជាពិសេសក្នុងវិស័យអប់រំ ប៉ុន្តែបានទុកឲ្យប្រជាជាតិនីមួយៗដើម្បីផ្តល់ការសន្យាទាំងនេះ ។ គោលនយោបាយ និងកម្មវិធីជាតិអាចជាឧបករណ៍សំខាន់មួយសម្រាប់ការសម្រេចបាននូវប្រសិទ្ធភាព របស់ ICT ក្នុងការអប់រំហើយក៏ជាចំណុចសំខាន់នៃកិច្ចការនេះ។

## ២.៦. បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងប្រទេសកម្ពុជា

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលបានអនុវត្តក្នុងការអប់រំ គឺជាបច្ចេកវិទ្យាទាំងអស់ដែលរួមមាន កុំព្យូទ័រ អ៊ិនធឺណេត ការផ្សារភ្ជាប់បច្ចេកវិទ្យា និងអ្វីៗផ្សេងទៀតដែលអាចជួយសម្រួលដល់ការផ្តល់ការណែនាំ និងដំណើរការរៀនសូត្រ ដោយខ្លួនវាផ្ទាល់ហើយក្នុងពេលតែមួយ ជម្រុញសហប្រតិបត្តិការអន្តរជាតិនិងបណ្តាញនៅក្នុងការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈ ( Khan, Hasan, & Clement,2012 ) ។ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញចក្ខុវិស័យសម្រាប់រយៈពេលវែងរបស់ខ្លួនរួចរាល់ហើយផងដែរដើម្បីធានា ឲ្យមានភាពស្មើគ្នាក្នុងការទទួលបានការអប់រំជាមូលដ្ឋានសម្រាប់ពលរដ្ឋគ្រប់រូប និងរៀបចំឲ្យពួកគេដើរតួនាទី យ៉ាងសកម្មក្នុង ការកសាងឡើងវិញ ចំពោះប្រទេសកម្ពុជាដែលឆ្លងកាត់សង្គ្រាមជាច្រើនឆ្នាំ លើសពីនេះទៀត ក៏និងរួមបញ្ចូលប្រទេសកម្ពុជា នៅក្នុងសហគមន៍របស់ពិភពលោកដែលពឹងផ្អែកលើចំណេះដឹង ( MoEYS- 2004 ) ។

នៅក្នុងមួយទសវត្ស ចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមគំនិតផ្តួចផ្តើមជាច្រើន ដើម្បីសម្របសម្រួលសមាហរណកម្ម ឲ្យកាន់តែមានភាពប្រសើរនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ប៉ុន្តែត្រូវប្រឈមនិងបញ្ហា ថវិកា មួយចំនួន ជាពិសេសនៅសាលារដ្ឋ ដែលជាកត្តាបង្កើតឲ្យមាន ផលលំបាក ក្នុងការឈានទៅដល់ គោលបំណងរបស់ក្រសួង ( MoEYS- 2004 ) ។ បើយោងទៅតាមទិន្នន័យរបស់ ( Hootsuite, 2018 ) ប្រជាជននៃប្រទេស កម្ពុជា មានចំនួនជាង ១៦,១៣លាននាក់ ក្នុងនោះ ៨លានជាអ្នកប្រើប្រាស់ អ៊ីនធឺណេត លទ្ធផលនេះមានន័យថា ប្រជាជនកម្ពុជាប្រហែល ៥០ភាគរយ បានប្រើប្រាស់អ៊ីនធឺណេត។ ការយល់ដឹងជាមូលដ្ឋាន នៃការប្រើប្រាស់អ៊ីនធឺណេតជួយសម្របសម្រួលដល់ការរីកចម្រើននៃវិស័យអប់រំក្នុងប្រទេសកម្ពុជា។ តាមរយៈការសិក្សាជាក់ស្តែងមួយបានបង្ហាញថា ការអប់រំអាចធ្វើឲ្យ សេដ្ឋកិច្ច រីកចម្រើន ហើយការ រួមបញ្ចូលគ្នានេះ ត្រូវបានរកឃើញទាំង

ក្នុងការវិភាគម៉ាក្រូសេដ្ឋកិច្ចនិងមីក្រូសេដ្ឋកិច្ច ( Kozma,2005 ) ដែលបានបង្ហាញ កំណែទម្រង់កម្មវិធីសិក្សា កំណែទម្រង់គរុកោសល្យ កំណែទម្រង់ការវាយតម្លៃ ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូ និងការរៀបចំសាលារៀន ជាជំហានដ៏សំខាន់ក្នុងការសម្រេចបាននូវកំណើនអប់ដ៏រឹងមាំ។

ការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ បានជួយគាំទ្រ ទៅដល់ការផ្តល់និងទទួលព័ត៌មាន និងបង្កើតចំណេះដឹង ហើយបានជម្រុញ វិស័យផ្សេងៗក្នុងប្រទេសកម្ពុជា ទទួលបាននូវ ការសម្រេចគោលដៅដែលបានកំណត់ ដោយក្រសួងអប់រំ យុវជន និងកីឡា។ ប្រទេសកម្ពុជាបានជ្រាតចូលយ៉ាងល្អនៃប្រព័ន្ធអ៊ិនធឺណេត ( នៅជុំវិញ៥០ភាគរយក្នុងឆ្នាំ២០១៨ ) ហេតុដូច្នេះ យើងអាចទាញយកប្រើជាគុណសម្បត្តិ រួមជាមួយនិងចំណេះដឹង បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ ករណីនេះអាចផ្តល់ឲ្យនិស្សិតទទួលបានចំណែកច្រើនជាងសិស្សនៅតាមសាលាដែលមានរងការប៉ះពាល់ទៅលើការខ្វះធនធាន។ ការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានផ្តល់នូវបរិយាកាសនៃការរៀនសូត្រដ៏មានឥទ្ធិពល និងអាចផ្លាស់ប្តូរដំណើរនៃការការរៀនសូត្រ ដូច្នេះសិស្ស អាចដោះស្រាយ ចំណេះដឹងតាមរយៈសកម្មភាពនិងវិធីនៃការដឹកនាំខ្លួនឯងនិងបង្កើតនូវទម្រង់មួយ ( Volman & Van Eck, 2001 ) ។

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) បានជួយលើកកម្ពស់ការអប់រំតាមវិធីជាច្រើន។ ICT អាចរក្សាទុកនូវ ព័ត៌មាន ដ៏មានប្រសិទ្ធភាព កាត់បន្ថយបរិមាណព័ត៌មាន សម្របសម្រួលរចនាសម្ព័ន្ធឲ្យបានប្រសើរជាងមុន អាចដាក់បញ្ចូលក្នុង វិធីសាស្ត្របង្រៀន និងរៀនហើយវា អាចប្រើដើម្បីបង្កើតប្រព័ន្ធផ្សព្វផ្សាយបែបអន្តរកម្មថ្មី ( Khan, Hasan, & Clement, 2012 ) ។

សេចក្តីណែនាំនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ក្នុងវិស័យអប់រំ នឹងជួបការលំបាកភាគច្រើនគឺកើតឡើងទៅលើប្រទេស កំពុងអភិវឌ្ឍន៍ដូចជា ប្រទេសកម្ពុជាជាដើម ក៏ដូចជាករណី ដែលបានកើតឡើង នៅប្រទេសបង់ក្លាសដែសរាយការណ៍ដោយ Khan et al ( 2012) ។ កង្វះធនធាន ថវិកាមិនគ្រប់គ្រាន់ អវត្តមានចក្ខុវិស័យ និងគម្រោង កង្វះនយោបាយសង្គម កត្តាវប្បធម៌ អំពើពុករលួយ ឥរិយាបថរបស់គ្រូបង្រៀន ចំពោះ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( ICT ) ភាពកង្វះពេលវេលា និងជំនាញ គឺជាបញ្ហាជាច្រើនដែលប្រទេសកម្ពុជា កំពុងប្រឈមមុខក្នុងដំណើរការនេះ។ ម្យ៉ាងវិញ

ទៀត ការដែលមិនបានរំពឹងទុកនៃការបញ្ចប់នៃការសិក្សាដែលខ្លួនជាប្រទេសមានការអភិវឌ្ឍទាបLeast Development Country ( LDC ) រហូតដល់ឆ្នាំ២០២៥ ដូចដែលបានចែងក្នុង របាយការណ៍របស់ភ្នាក់ងារអង្គការសហប្រជាជាតិ ( United Nation, de Gaudemar, 2016 ) អាចប្រឈមមុខនិងបញ្ហាដែលបានរៀបរាប់ខាងលើ។

## ២.៧. គោលនយោបាយ និង យុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា

យោងតាមគោលនយោបាយអប់រំនៃប្រទេសកម្ពុជាដែលបាន បោះពុម្ពផ្សាយ ដោយក្រសួងអប់រំ យុវជន និងកីឡានៅក្នុងឆ្នាំ ២០១៨ បានចែងអំពីចំណុចសំខាន់ៗជាច្រើនដែលមានទំនាក់ទំនងទៅនិងចក្ខុវិស័យ គោលដៅ យុទ្ធសាស្ត្រ និងគោលការណ៍ផ្សេងៗ ក្នុងការបង្រៀននិងរៀនដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ ក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យ លើកយកការលើកកម្ពស់ការបង្រៀន និងរៀន សម្រាប់សិស្ស និស្សិត គ្រប់រូបដែលបញ្ចប់ការសិក្សាឲ្យមាន គំនិតវិវត្តន៍ច្នៃប្រឌិត ប្រកបដោយ ក្របសីលធម៌ អាចប្រកួតប្រជែងបានក្នុងសង្គមព័ត៌មាន និងសេដ្ឋកិច្ច ដែលផ្អែកលើពុទ្ធិ។ ជាគោលដៅ និងយុទ្ធសាស្ត្រ ស្តីពី បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ មានគោលដៅបញ្ជ្រាប បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឲ្យក្លាយជាឧបករណ៍ សម្រាប់បង្រៀននិងរៀន និងចែករំលែកចំណេះដឹង ក្នុងវិស័យអប់រំទាំងមូល សំដៅ បំប៉នសិស្ស និស្សិត នូវចំនេះដឹង និងបំណិនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីធ្វើ អន្តរកាលទៅរកពិភពការងារ ក្នុងសតវត្សទី១២

ស្រដៀងទៅនឹង គោលនយោបាយ ដែលទាក់ទងទៅនិង បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវបានធ្វើឡើងតាំងពីខែ ធ្នូ ឆ្នាំ ២០០៤ ដែលបាន ផ្តោតសំខាន់ចំនួន២ ទៅលើការបង្រៀន និងរៀននៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគន៍។

១. ផ្នែកទីមួយគឺផ្តល់លទ្ធភាពទទួលបាននូវ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់គ្រូ និងសិស្សទាំងអស់ជាពិសេសនៅកម្រិតអនុវិទ្យាល័យដែលបានធានាថាបច្ចេកវិទ្យាគមនាគមន៍ និង

ព័ត៌មាន ត្រូវបានប្រើឧបករណ៍សម្រាប់កាត់បន្ថយ គម្លាតឌីជីថល រវាងសាលារៀននៅកម្ពុជា និងសាលាដ៏ទៃទៀតនៅក្នុងប្រទេសជិតខាង។

២. ផ្នែកទីពីរសង្កត់ធ្ងន់ទៅលើតួនាទី និងមុខងាររបស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងវិស័យអប់រំជាឧបករណ៍បង្រៀន និងរៀនក្នុងមុខវិជ្ជាផ្សេងៗគ្នានិងមុខវិជ្ជាខ្លួនផ្ទាល់។ ការទទួលព័ត៌មាននៅលើអ៊ិនធឺណេត និងបង្កើនការប្រាស្រ័យទាក់ទង តាមរយៈអ៊ីម៉ែលរវាងសាលារៀននិងបុគ្គលិកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់អ្នកអប់រំ ។ គោលនយោបាយនេះបានសង្កត់ធ្ងន់ថែមទៀតលើការប្រើប្រាស់កុំព្យូទ័រ ដើម្បីទទួលបានព័ត៌មាន ចំណេះដឹង ជំនាញ និងការប្រាស្រ័យទាក់ទងគ្នា។

ជាមួយនឹងគោលការណ៍ជាច្រើនដែលក្រសួងបានដាក់អនុវត្ត មានចំណុចមួយចំនួនដែលផ្តោតទៅលើការបង្រៀន និងរៀននៃសិស្ស និងនិស្សិត ដែលចាំបាច់នៃការប្រើប្រាស់ ICT ។

១. ក្រសួងអប់រំយុវជន និងកីឡា នឹងធានាឲ្យសិស្ស និស្សិតកម្ពុជាគ្រប់រូបដែលបញ្ចប់ការអប់រំក្នុងប្រព័ន្ធអាចប្រើប្រាស់ចំណេះដឹង និងបំណិន ICT ដើម្បីមានលទ្ធភាពអាចបន្តការសក្សានិងការបំពេញការងារវិជ្ជាជីវៈ។

២. ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើតប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀននិងរៀននីមួយៗតាមមជ្ឈមណ្ឌលគរុកោសល្យ សាលារៀន និងគ្រឹះស្ថានអប់រំដ៏ទៃទៀត តាមរយៈការប្រើប្រាស់ឧបករណ៍ ICT និងធនធានអប់រំអេឡិចត្រូនិក។

៣. ក្រសួងអប់រំ យុវជន និងកីឡា នឹងប្រើប្រាស់ការសិក្សាតាម ប្រព័ន្ធអេឡិចត្រូនិច ( E-learning )ដើម្បីគាំទ្រឲ្យមានការផ្តល់សេវាអប់រំដល់គ្រប់អនុវិទ្យាល័យ សម្រាប់សិស្សនិស្សិត និងការអភិវឌ្ឍមត្ថភាព ស្ថាប័នក៏ដូចជា ការរៀនសូត្រពេញមួយជីវិត។

បើយោតាមគោលនយោបាយទាំង២ គឺនៅក្នុងឆ្នាំ ២០០៤ និងឆ្នាំ ២០១៨ យើង អាចបកស្រាយថា នៅក្នុង ឆ្នាំ២០០៤ គោលនយោបាយនៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ គឺសង្កត់ធ្ងន់ទៅលើការបង្រៀននិងរៀន ដែលផ្តោតសំខាន់នៅក្នុងថ្នាក់អនុវិទ្យាល័យដែលជំរុញឲ្យគ្រូ និងសិស្សបានយល់ដឹងពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ គោលនយោបាយបានផ្តោតទៅលើការប្រើប្រាស់របស់សិស្ស និង

គ្រូ និងការឆ្លើយតបទៅនឹងការប្រកួតប្រជែង និងប្រទេសជិតខាង។ ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវបាននូវគោលនយោបាយយ៉ាងទូលំទូលាយ ដោយមិនប្រកាន់ ថាបុគ្គល ស្រី ប្រុស ឬ ជនរស់នៅដាច់ស្រយាលឡើយ។ ស្រដៀងគ្នានេះដែរ គោលនយោបាយនៅក្នុងឆ្នាំ ២០១៨ នៃក្រសួងអប់រំ យុវជន និងកីឡា ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានសង្កត់ន័យបន្ថែមជាច្រើនទៀត ដោយបង្ហាញពីការជានា ដល់សិស្ស នូវចំណេះដឹងផ្នែក បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគន៍ បង្កើតប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀនតាមសាលារៀននិងបណ្តុះបណ្តាលគ្រូ ការសិក្សាតាមអេឡិចត្រូនិក ការសហការគ្នាផ្សេងៗទៀត ធ្វើយ៉ាងណាឲ្យមានការប្រកួតប្រជែងនាសតវត្សទី២១។

ការស្រាវជ្រាវ និងគោលនយោបាយនៃការអប់រំដែលបានរៀបរាប់ ខាងលើបានស្តែងចេញកាន់តែច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការសម្រួលផ្នែកសិក្សារបស់គ្រូ និងអ្នកសិក្សា។

កម្ពុជាជាប្រទេសមួយដែលកំពុងអភិវឌ្ឍជាបណ្តើរៗ ទៅលើការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើវិស័យអប់រំ ។ តាមរយៈការធ្វើគោលនយោបាយនិងយុទ្ធសាស្ត្រស្តីអំពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំនៃប្រទេសកម្ពុជានាឆ្នាំ២០០៤ និងឆ្នាំ២០១៨ បានស្តែងចេញឲ្យឃើញ ពីភាពបម្រែបម្រួលនៃចក្ខុវិស័យ គោលដៅ របស់ក្រសួងក្នុងការធ្វើយ៉ាងណាឲ្យការបង្រៀន និងរៀនសូត្ររបស់គ្រូ សិស្ស មានការប្រកួតប្រជែង នៅក្នុងតំបន់ក៏ដូចជា ពិភពលោកទាំងមូល ។ ដើម្បីឆ្លើយតបទៅនឹងប្រធានបទស្តីពីស្ថានភាពប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ជំនួយដល់ការអប់រំ នៅតាមវិទ្យាល័យ អ្នកស្រាវជ្រាវ នឹងធ្វើការវាស់ស្ទង់ទៅលើពីរចំណុច ដាចម្បងគឺស្ថានភាពប្រើប្រាស់ ICT និងកត្តាប្រឈម ។ អ្នកស្រាវជ្រាវ នឹងចុះតាមសាលារៀនសាធារណៈចំនួន៨ នៅក្នុងខេត្តរតនគិរី ដែលស្ថិតនៅតំបន់ផ្សេងៗគ្នា គឺតំបន់ទីរួមខេត្ត តំបន់ទីប្រជុំជន និងតំបន់ជនបទ ដាច់ស្រយាល ។ វិធីសាស្ត្រក៏ដូចជាព័ត៌មានលម្អិតជាច្រើននៃការស្រង់ទិន្និន័យនឹងត្រូវបានបកស្រាយនៅក្នុងជំពូកទី៣។

# ជំពូកទី ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ អំពីរបៀបស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រទាំងមូលក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ លក្ខណៈរបស់ភាគសំណាក និងក្រមសីលធម៌ក្នុងការចុះប្រមូលទិន្នន័យ។

## ៣.១ ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ ស្ដីពីអំពីស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងការគ្រប់គ្រងនៅកម្រិតវិទ្យាល័យនៃខេត្តរតនគិរី។ នៅក្នុងការស្រាវនេះដែរនឹងត្រូវបានធ្វើឡើងនៅក្នុងវិទ្យាល័យចំនួន ០៨ ដែលស្ថិតក្នុងខេត្តរតនគិរី។

**តារាងទី១៖ ការកំណត់ភាគសំណាក**

| លរ | ឈ្មោះវិទ្យាល័យ | ក្រុង/ស្រុក | ចំនួនត្រូវសម្ភាសន៍ | | | | ស្ថានភាព |
|---|---|---|---|---|---|---|---|
| | | | គណៈគ្រប់គ្រង | | គ្រូទុតិយភូមិ | សិស្ស | |
| | | | នាយក | នាយករង | | | |
| ១ | វិទ្យាល័យ ហ៊ុនសែន ភូមិថ្មី | បានលុង | ១ | ១ | ១២ | ១២ | ក្នុងក្រុង |
| ២ | វិ. អន្តេវាសិកដ្ឋានក្រុងបាលុង | បានលុង | ១ | ១ | ១២ | ១២ | |
| ៣ | វិទ្យាល័យ ប៊ូថងអូរជុំ | អូរជុំ | ១ | ១ | ១២ | ១២ | ទីប្រជុំជន |
| ៤ | វិទ្យាល័យ ត្រពាំងក្រហម | កូនមុំ | ១ | ១ | ១២ | ១២ | |
| ៥ | វិទ្យាល័យ សោមធំ | អូរយ៉ាដាវ | ១ | ១ | ១២ | ១២ | ដាច់ស្រយាល |
| ៦ | វិទ្យាល័យ លំផាត់ | លំផាត់ | ១ | ១ | ១២ | ១២ | |
| ៧ | វិទ្យាល័យ អណ្ដូងមាស | អណ្ដូងមាស | ១ | ១ | ១២ | ១២ | |
| ៨ | វិទ្យាល័យ វីរៈជ័យ | វើនសៃ | ១ | ១ | ១២ | ១២ | |
| សរុប | | | ១៦នាក់ | | ៩៦នាក់ | ៩៦នាក់ | |

ដោយផ្អែកលើវិទ្យាល័យទាំង៨ខាងលើនេះ គឺជាវិទ្យាល័យដែលបានកំណត់ពីលក្ខណៈផ្សេងៗគ្នានៃភូមិសាស្ត្រ ដោយផ្តោតទៅលើទីរួមខេត្ត ទីប្រជុំជន និងតំបន់ជនបទនៃខេត្ត។ អ្នកស្រាវជ្រាវជឿជាក់ថាសាលាទាំង៨ខាងលើនេះបាន បង្ហាញយ៉ាងជាក់លាក់នូវស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ តាមវិទ្យាល័យនានា ព្រោះទីតាំងភូមិសាស្ត្រអាចធ្វើជាតំណាងឲ្យវិទ្យាល័យមួយចំនួនទៀតនៅក្នុងខេត្ត។

## ៣.២ ក្រុមគោលដៅ

ការសិក្សាស្រាវជ្រាវនេះគឺផ្តោតទៅលើស្ថានភាពប្រើប្រាស់ និងបញ្ហាប្រឈម ។ ដើម្បីបានទទួលនូវគោលបំណងទាំងនេះ អ្នកស្រាវជ្រាវ និងសិក្សាស្រាវជ្រាវទៅលើបុគ្គលិកអប់រំ ( នាយក នាយករង គ្រូបង្រៀនមុខវិជ្ជានៅតាមវិទ្យាល័យ ) សិស្សានុសិស្ស ដែលមាននៅក្នុងថ្នាក់ ១០ ១១ និង ១២ នៃវិទ្យាល័យគោលដៅ ។

នៅក្នុងដំណើការនៃ ការប្រមូលទិន្នន័យនេះអ្នកស្រាវជ្រាវនឹង យកគម្រងសំណួរដែលបានរៀបចំរួចស្រេច ក្រោមការណែនាំពីសំណាក់ គ្រូដឹកនាំបង្គោល នឹងគ្រូដឹកនាំរង ដាក់ស្នើសុំការបំពេញ ក៏ដូចជាការសរសេចូលនូវចម្លើយមួយចំនួនទៅតាមប្រភេទនៃសំណួរ។ អ្នកស្រាវជ្រាវនឹងសម្ភាស នាយកសាលាចំនួន០១រូប នាយករង០១រូប គ្រូ១២នាក់ និងសិស្សានុសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ១២នាក់ ក្នុងមួយវិទ្យាល័យ ដើម្បីកំណត់តំបន់ស្រាវជ្រាវក្នុងការធ្វើជាគំរូសំណាកនៃការវិភាគនិងប្រមូលទិន្ន័យ ។

តារាងទី២៖ ក្រុមគោលដៅនិងអ្នកចូលរួម

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | នាយក/នាយិកាវិទ្យាល័យ | ៨ នាក់ |
| | នាយករង/នាយិការងវិទ្យាល័យ | ៨ នាក់ |
| ២ | គ្រូបង្រៀន (តាមមុខវិជ្ជា ) | ៩៦នាក់ |
| ៤ | សិស្សានុសិស្ស( កម្រិតមធ្យមសិក្សាទុតិយភូមិ ) | ៩៦នាក់ |
| សរុបៈ | | ២០៨ នាក់ |

## ៣.៣. ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន សិស្សចំនួន៩៦នាក់ដែលរៀនចាប់ពីថ្នាក់ទី១០ ដល់ទី១២ និងគ្រូបង្រៀនដែលកំពុងតែបង្រៀនតាមមុខវិជ្ជានៅមធ្យមសិក្សាទុតិយភូមិ ( ចាប់ពីថ្នាក់ទី១០ ដល់ទី១២ ) ចំនួន ៩៦នាក់ នាយក ឬនាយិកាចំនួន ៨នាក់ នាយករង ឬនាយិការងចំនួន ៨នាក់ ក្នុងសាលាវិទ្យាល័យចំនួន ៨ ដែលស្ថិតនៅក្នុងក្រុង ស្រុកទាំង ៨ នៃខេត្តរតនគិរី គឺក្រុងបានលុង(០២ វិទ្យាល័យ) ស្រុកអូរជុំ ស្រុកកូនមុំ ស្រុកអូរយ៉ាដាវ ស្រុកលំផាត់ ស្រុកអណ្តូងមាស និងស្រុកវើនសៃ។ ចំពោះសំណាកដែលជ្រើសរើសគឺធ្វើឡើងនៅក្នុងវិទ្យាល័យទាំងនោះមានដូចជា៖

វិទ្យាល័យអន្តេវាសិកដ្ឋានក្រុងបានលុង សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការងចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យហ៊ុនសែន ភូមិថ្មី សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការងចំនួន ០១នាក់ និងគ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យប៊ូថង អូរជុំ សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យកូនមុំ សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យសោមធំ សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យលំផាត់ សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យអណ្តូងមាស សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

វិទ្យាល័យវើនសៃ សិស្សចំនួន ១២នាក់ នាយក ឬនាយិកាចំនួន ០១នាក់ នាយករង ឬនាយិការង ចំនួន ០១នាក់ និង គ្រូបង្រៀនតាមមុខវិជ្ជាទាំងអស់ ១២ នាក់ ។

## ៣.៤. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបកណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើនៅក្នុងការប្រមូលទិន្នន័យ មានជាកម្រងសំណួរដែលមានលក្ខណៈកម្រិតចម្លើយ ( ទម្រង់បិទ ) នឹងទម្រង់សំណួរបើក។ ដើម្បីឲ្យការប្រមូលទិន្នន័យនេះបាន ត្រូវមានកម្រងសំណួរសម្រាប់សិស្ស កម្រងសំណួរសម្រាប់គ្រូបង្រៀនតាមមុខវិជ្ជា កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា ។ គម្រងសំណួរត្រូវបានបង្កើតឡើងជា ៣ ប្រភេទ ដើម្បីធ្វើការប្រមូលទិន្នន័យក្នុងនោះរួមមាន៖

កម្រងសំណួរសម្រាប់សិស្សចំនួន ៩៦ ច្បាប់ កម្រងសំណួរសម្រាប់គ្រូបង្រៀនតាមមុខវិជ្ជាចំនួន ៩៦ ច្បាប់ និងកម្រងសំណួរសម្រាប់គណៈគ្រប់គ្រង១៦ ច្បាប់។ មុនពេលផ្តល់កម្រងសំណួរនេះអ្នកចូល

រួមផ្តល់ព័ត៌មាន ជាដំបូងគឺត្រូវធ្វើការទំនាក់ទំនងជាមួយមន្ទីរអប់រំ ការិយាល័យអប់រំ ក្រុង ស្រុកគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ នឹងសិស្សានុសិស្ស ដើម្បីឲ្យមានភាពងាយស្រួលក្នុងការបំពេញកម្រងសំណួរ ។ ដោយឡែកក្នុងស្ថានភាពនៃការចុះប្រមូលទិន្នន័យនេះផងដែរ ជាពេលដែលមានការផ្ទុះរីករាលដាលនៃជម្ងឺកូវីដ១៩ ដូចនេះយើងបានជួបសម្ភាសផ្ទាល់ជាមួយតែគណៈគ្រប់គ្រងតែប៉ុណ្ណោះ សម្រាប់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សយើងជួបតាមរយៈOnline ដោយសូមការសហការពីគណៈគ្រប់គ្រងក្នុងការទំនាក់ទំនងជាមួយសិស្ស ក៏ដូចជាជាមួយលោកគ្រូ-អ្នកគ្រូ ដើម្បីមានភាពងាយស្រួលក្នុងការពន្យល់ណែនាំពីរបៀបបំពេញកម្រងសំណួរ ។ អ្នកសិក្សាស្រាវជ្រាវបានបង្កើតក្រុម តេឡេក្រាមទៅតាមសាលានីមួយៗ ដើម្បីងាយស្រួលក្នុងការសម្របសម្រួលទៅលើបញ្ហាផ្សេងៗជាមួយអ្នកចូលរួមផ្តល់ទិន្នន័យក្នុងករណីចាំបាច់ណាមួយ។

### ៣.៤.១. កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសម្រាប់សួរសិស្សគឺមានគោលបំណងដើម្បីរកឲ្យឃើញពីស្ថានភាពក្នុងការរៀន និងបង្រៀនដោយប្រើប្រាសបច្ចេកវិទ្យាព័ត៌មាន នឹងសារគមនាគមន៏កត្តាមួយចំនួនដែលមាន ឥទ្ធិពលក្នុងការរៀន សំណួរទាក់ទងកត្តាផ្ទាល់ខ្លួន កត្តាសាលារៀន នឹង បញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ ICT ជាកម្រងសំណួរទម្រងបិទ ។

### ៣.៤.២ កម្រងសំណួរសម្រាប់គ្រូ

កម្រងសំណួរសម្រាប់សួរគ្រូ មានគោលបំណងដើម្បីរកឲ្យឃើញពីស្ថានភាពដែលគ្រូបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន នឹងសារគមនាគមន៍ក្នុងការបង្រៀនទាំងនៅសាលា និងពេលសិស្សត្រឡប់ ទៅផ្ទះវិញ។ កម្រងសំណួរក៏បានបង្ហាញពីវិធីសាស្ត្រប្រើប្រាស់ នៃការបង្រៀន ព្រមទាំងបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀន នៅក្នុងថ្នាក់នឹងពីចម្ងាយផងដែរ ។

កម្រងសំណួរសម្រាប់គ្រូនេះក៏ឆ្លុះបញ្ចាំងផងដែរអំពីការប្រើបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ក្នុងការដឹកនាំគ្រប់គ្រងបុគ្គលិក និងដើម្បីកំណត់បញ្ហាប្រឈមនានាផងដែរ។

### ៣.៤.៣ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មានគោលបំណងដើម្បីរកឲ្យឃើញពីស្ថានភាពដែលគ្រូបានប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន នឹងសារគមនាគមន៍ក្នុងការបង្រៀន និងដើម្បីរកឲ្យឃើញពីស្ថានភាពដែល គណៈគ្រប់គ្រងបានប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មានវិទ្យា សារគមនាគមន៍ក្នុងការដឹកនាំគ្រប់គ្រងព្រមទាំងបញ្ហាប្រឈមនានាផងដែរ។

## ៣.៥. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវត្រូវបានរៀបចំ គ្រប់គ្រង និងប្រមូលទិន្នន័យដោយអ្នកស្រាវជ្រាវ និងប្រើប្រាស់ឧបករណ៍ ស្រាវជ្រាវដែលបានបង្កើតឡើងដោយមានការពិភាក្សាណែនាំយ៉ាងយកចិត្តទុកដាក់ និងមានប្រសិទ្ធភាពពីសំណាក់ សាស្ត្រចារ្យ ណែនាំ នឹង សាស្ត្រចារ្យ ណែនាំរង ។ ការសិក្សានេះបានប្រើវិធីសាស្ត្របរិមាណវិស័យក្នុងការប្រមូលទិន្នន័យ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យ គឺបានធ្វើការសម្ភាសជាមួយសិស្ស លោកគ្រូ អ្នកគ្រូនិង គណៈគ្រប់គ្រងសាលាស្នើសុំឲ្យបំពេញកម្រងសំណួរសម្រាប់សិស្ស គ្រូ នឹង គណៈគ្រប់គ្រង់ដោយប្រើកម្រងសំណួរដែលបានរៀបចំទុកជាមុនតាមគោលបំណងនៃការស្រាវជ្រាវ ដើម្បីឲ្យការស្រាវជ្រាវនេះទទួលបានជោគជ័យ មានប្រភពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ។

## ៣.៦. ដំណើរការក្នុងការប្រមូលទិន្នន័យ

បន្ទាប់ពីបានបង្កើតកម្រងសំណួរ ឧបករណ៍ប្រមូលទិន្នន័យរួច រួមទាំងមានការអនុម័តពីសាស្ត្រាចារ្យដឹកនាំ ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងដោយសុំការអនុញ្ញាតិពីមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីចុះទៅដល់សាលារៀនគោលដៅ ។ ជាដំបូងចុះជួបជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និងកីឡា ដើម្បីស្នើសុំការសហការ និងសាកសួរព័ត៌មានបន្ថែមអំពីទីតាំងដែលបានកំណត់ទុកសម្រាប់ធ្វើការស្រាវជ្រាវនេះ ។ អ្នកស្រាវជ្រាវក៏បានសុំលិខិតអនុញ្ញាតិពីមន្ទីរអប់រំដើម្បីចុះតាមសាលាគោលដៅ ។ បន្ទាប់ពីបានជួបជាមួយគណៈគ្រប់គ្រង អ្នកស្រាវជ្រាវបានសំការអនុញ្ញាតិធ្វើការសម្ភាស នឹងចែកជូនកម្រងសំណួរដល់គណៈគ្រប់គ្រងសាលា ដោយឡែកក្នុងស្ថានភាពនៃការចុះប្រមូលទិន្ន័យនេះផងដែរ ជាពេល

ដែលមានការផ្ទុះរីករាលដាលបែជម៉ឺកូវីដ១៩ ដូចនេះយើងបានជួបសម្ភាសផ្ទាល់ជាមួយតែគណៈគ្រប់គ្រងតែប៉ុណ្ណោះ សម្រាប់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សយើងជួបតាមរយៈOnline ដោយយើងបានបង្កើតកម្រងសំណួរតាមរយៈGoogle Forms និងទម្លាក់ជូនលោកគ្រូ អ្នកគ្រូ និងសិស្សទី ១០ ដល់ទី ១២ ហើយស្នើសុំឲ្យពួកគាត់ជួយបំពេញចម្លើយទៅតាមសំណួរដែលមាននៅក្នុងកម្រងនោះ ។បន្ទាប់ពីនាយក នាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បានបំពេញកម្រងសំណួរទាំងនៅលើសន្លឹកកិច្ចការ ក៏ដូចជាតាមរយៈ Google forms រួចរាល់ហើយ យើងក៏បានប្រមូលនូវកម្រងសំណួរទាំងអស់យកមកបញ្ចូលក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគទិន្នន័យ ។

ការសិក្សាស្រាវជ្រាវនេះបានចុះសិក្សាតាមទីកន្លែងដែលបានជ្រើសរើសនោះ ហើយមានរយៈពេលប្រហែល បួនសប្តាហ៍នៃថ្ងៃធ្វើការគឺគិតចាប់ពីថ្ងៃទី ០៥ ខែ កក្កដា ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២១ ។

## ៣.៧. ការវិភាគទិន្នន័យ

ដោយប្រើចម្លើយដែលបានមកពីការបំពេញកម្រងសំណួរបូករួមទាំង ចម្លើយដែលបានមកពីការសម្ភាស គណៈគ្រប់គ្រង សាលា និង លោកគ្រូ អ្នកគ្រូ ការវិភាគនេះគឺត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រវិភាគទិន្នន័យបែបបរិមាណវិស័យ ។ ការសិក្សានេះបានអនុវត្តការវិភាគដោយប្រើកម្មវិធី SPSS តាមបែបស្ថិតិមានដូចជា ការវិភាគបែបពិពណ៌នា ( ចំនួន មធ្យមភាគ ភាគរយ ជាដើម ) ដើម្បីរកឃើញពីស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារ គមនាគមន៍ក្នុងការបង្រៀន និងការគ្រប់គ្រងនៅមធ្យមសិក្សាទុតិយភូមិ និងបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រង និងការបង្រៀនដោយប្រើតារាងតាមរយៈ( MS. Word )។

## ៣.៨ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ក្រមសីលធម៌គឺមានសារៈសំខានណាស់ សម្រាប់ការសិក្សាស្រាវជ្រាវពីព្រោះរាល់ការសម្ភាសន៍គឺយើងមិនធ្វើឲ្យមានផលប៉ះពាល់ដល់អ្នកចូលរួមទេ នឹងរក្សាការសំងាត់។ ដើម្បីរក្សាក្រមសីលធម៌ យើងបានធ្វើការណែនាំខ្លួន ប្រាប់ពីគោលបំណង រយៈពេលសុំសម្ភាស ការសន្យាលើលក្ខណមួយចំនួនដូចជាការរក្សាការសម្ងាត់ជូនគាត់ ព័ត៌មានទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត

ឡើយ។ ហើយរាល់ការសម្ភាសន៍ត្រូវបានសុំការអនុញ្ញាតិ និងមានការឯកភាពពីអ្នកដែលឆ្លើយតបការ សម្ភាស។ ក្នុងដំណើរការសម្ភាសន៍ គឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នកសម្ភាសន៍បានស្លៀកសំលៀកបំពាក់សមរម្យ ទឹកមុខស្រស់ស្រាយ ញញឹមរួសរាយ នឹងបង្ហាញនូវភាព ស្និតស្នាល សម្ដីទន់ភ្លន់ និងអង្គុយតាមបែបបទគោលការណ៍អ្នកសម្ភាសន៍។

## ៣.៩. ព្រំដែននៃការសិក្សាស្រាវជ្រាវ

ការសិក្សានេះបានផ្តោតទៅលើតែស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងការបង្រៀន និងការគ្រប់គ្រង និងបញ្ហាប្រឈមនានាក្នុងមធ្យមសិក្សាទុតិយភូមិ ក្នុងក្រុងស្រុកចំនួន ០៨ ក្នុងចំណោម ក្រុងស្រុកទាំង ០៩ នៃខេត្តរតនគិរីតែប៉ុណ្ណោះ ។ ក្រុមគោលដៅដែលបានជ្រើសរើសយកមកសិក្សាគឺ សិស្ស ( កំពុងរៀនតាមOnline ចាប់ពីថ្នាក់ទី ១០ ដល់ទី១២ ) លោកគ្រូ អ្នកគ្រូ ដែលបង្រៀន(តាមOnline) គណៈគ្រប់គ្រងវិទ្យាល័យទាំង ០៨ ។ រាល់ការសម្ភាសមិនបានសម្ភាសពីអ្វីដែលមិនទាក់ទងទៅនិងប្រធានបទនោះទេ។ ព័ត៌មានដែលទទួលបានត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនបានយកឈ្មោះ ឬអ្វីដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកផ្តល់បទសម្ភាសទេ ។ ការសិក្សានេះបានធ្វើឡើង ដើម្បីស្រាវជ្រាវឲ្យឃើញពីស្ថានភាពនៃការប្រើប្រាស់ ICT ក្នុងការបង្រៀន គ្រប់គ្រង និងបញ្ហាប្រឈមនានា នៅមធ្យមសិក្សាទុតិយភូមិ ។ ម្យ៉ាងទៀតចំពោះតំបន់ដែលបានជ្រើសរើសយកមកសិក្សាមានលក្ខណៈមិនទាន់គ្រប់ដណ្តប់ទាំងស្រុងសម្រាប់ទូទាំងប្រទេសនៅឡើយទេ ដូចច្នេះវាមិនអាចតំណាងឲ្យតំបនឬខេត្ត ផ្សេងបានទេ ។

## ៣.១០ ព័ត៌មានទូទៅរបស់អ្នកចូលរួម

### ៣.១០.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសក្រុមគោលដៅដែលត្រូវទៅតាមលក្ខខណ្ឌកំណត់នៅក្នុងគម្រូជ្រើសរើសដូចជាៈ ថ្នាក់ដឹកនាំសាលារៀន ( នាយក/នាយិកា និងនាយករង/នាយិការង ) គ្រូបង្រៀន ( គ្រូបង្រៀនតាមមុខវិជ្ជាផ្សេងពីថ្នាក់ទី១០ ទី១១ និង ទី១២ ) និងសិស្សានុសិស្សតាមវិទ្យាល័យគោលដៅទាំងអស់ចំនួន ០៨( ថ្នាក់ទី ១០ ១១ទី១២ ) និងជ្រើសរើសជាគម្រូសម្រាប់ធ្វើការ

សិក្សាស្រាវជ្រាវនេះ។ ដូច្នេះភាគរយផលធៀប ភេទ នឹង អាយុរបស់អ្នកចូលរូមមិនត្រូវបានធ្វើការកំណត់ទុកជាមុនឡើយ ។ ជាលទ្ធផល យើងទទួលបានអ្នកចូលរូមសរុបចំនួន ២០០នាក់ ដែលរួមមាន៖ គណៈគ្រប់គ្រងសាលារៀនចំនួន ១៤ នាក់គ្រូបង្រៀនតាមមុខវិជ្ជាឯកទេសទី១០ ទី១១ និងទី១២ចំនួន ៩០នាក់ សិស្សានុសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិទាំងបីកម្រិតមានចំនួន ៩៦នាក់។ ហើយកម្រងសំណួរទាំងអស់ដែលបានចែកជូនអ្នកពាក់ព័ន្ធមានចំនួន ២០៨ ច្បាប់ បានប្រគល់ត្រឡប់មកវិញចំនួន ២០០ច្បាប់ ដោយក្នុងនោះ អនុគណៈគ្រប់គ្រង ០២រូប និងលោកគ្រូ អ្នកគ្រូ០៦រូបមកពីវិទ្យាល័យផ្សេងៗគ្នាមិនបានផ្តល់ត្រឡប់នូវកម្រងសំណួរនោះទេ។

### ៣.១០.១.១ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ នឹងមានបង្ហាញព័ត៌មានទូទៅមួយចំនួនរបស់គណៈគ្រប់គ្រងសាលាដែលជាសំណាកស្រាវជ្រាវទាំងអស់រួមមាន រយៈពេលបម្រើការងារជានាយក ប្រភេទក្របខណ្ឌ ភេទ និងកម្រិតសញ្ញាបត្រ ដែលនឹងមានបង្ហាញក្នុងតារាងខាងក្រោម ៖

**តារាងទី៣៖ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង**

| ល.រ | ការបរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរួម |
| ១ | តួនាទីគ្រប់គ្រង | នាយក | ៨ | ៥៧% |
| | | នាយករង | ៦ | ៤៣% |
| | | សរុប | ១៤ | ១00% |
| ២ | អាយុរបស់គណៈគ្រប់គ្រង | ២៥-៣០ឆ្នាំ | 0 | 0% |
| | | ៣១- 35ឆ្នាំ | ២ | ១៤% |

| | | | | |
|---|---|---|---|---|
| | | ៣៦- ៤០ឆ្នាំ | ៨ | ៥៧% |
| | | ៤០ឆ្នាំឡើងទៅ | ៤ | ២៩% |
| | | សរុប | ១៤ | ១០០% |
| ៣ | រយៈពេលបម្រើការងារក្នុងវិស័យអប់រំ | ៥ - ១៥ | ៦ | ៤៣% |
| | | ១៦ - ២៥ | ៥ | ៣៦% |
| | | ២៦ - ៣៥ | ៣ | ២១% |
| | | សរុប | ១៤ | ១០០% |
| ៤ | ប្រភេទក្របខណ្ឌ | គ្រូកម្រិតឧត្តម | ៩ | ៦៤% |
| | | គ្រូកម្រិតមធ្យម | ៥ | ៣៦% |
| | | សរុប | ១៤ | ១០០% |
| ៥ | កម្រិតសញ្ញាបត្រ | បណ្ឌិត | 0.00% | 0.00% |
| | | អនុបណ្ឌិត | ៦ | ៤៣% |
| | | បរិញ្ញាបត្រ | ៧ | ៥០% |
| | | បាកឌុប | ១ | ៧% |
| | | សរុប | ១៤ | ១០០% |
| ៦ | | ១ ដល់ ៥ ឆ្នាំ | ៥ | ៣៦% |

| | | | | |
|---|---|---|---|---|
| | | ៦ ដល់១០ឆ្នាំ | ២ | ១៤% |
| | | ១១ ដល់ ១៥ឆ្នាំ | ៤ | ២៩% |
| | | ១៦ ដល់ ២០ឆ្នាំ | ៣ | ២១% |
| | | លើស២០ឆ្នាំ | 0 | 0.0% |
| | | សរុប | ១៤ | ១00% |

យោងតាមទិន្នន័យតារាងទី២ ដែលបានបង្ហាញអំពីព័ត៌មានមួយចំនួននៃ គណៈនាយកដែលគ្រប់គ្រងនៅសាលាគោលដៅបានបង្ហាញដូចខាងក្រោម ៖

**តួនាទី៖** គណៈគ្រប់គ្រងដែលចូលរួមក្នុងការឆ្លើយក្នុងកម្រងសំណួរមានចំនួន ១៤ នាក់ស្មើនឹង ១00ភាគរយ ក្នុងចំណោមគណៈគ្រប់គ្រង ១៤ នាក់នៃសាលា 0៨ ផ្សេងៗគ្នា ។ តាមទិន្នន័យគឺ មាននាយកសាលាចំនួន ៨នាក់ ស្មើនឹង៥៧ភាគរយ និងនាយករងចំនួន ៦នាក់ ស្មើនឹង ៤៣ភាគរយ បានចូលរួមផ្តល់នូវទិន្នន័យ ។

**អាយុ៖** តាមទិន្នន័យបានបង្ហាញថា គណៈគ្រប់គ្រងទាំង ១៤នាក់ នៃ៨សាលា ដែលបានចូលរួមគឺមានអាយុ ៣១ ដល់ ៣៥ឆ្នាំមានចំនួន ២នាក់ ស្មើនឹង ១៤ភាគរយ អាយុពី៣៦ ដល់ ៤0ឆ្នាំមានចំនួន ៨នាក់ ស្មើនឹង ៥៧ភាគរយ អាយុពី៤0ឆ្នាំឡើងទៅមានចំនួន ៤នាក់ ស្មើនឹង ២៩ ភាគរយ ។ តាមរយៈលទ្ធផលនេះ យើងអាចសន្និដ្ឋានបានថា គណៈគ្រប់គ្រងមិនមានអាយុចន្លោះពី ២៥ ដល់ ៣៥ឆ្នាំនោះទេ។

**រយៈពេលនៃការបម្រើការងារក្នុងក្រសួងអប់រំ៖** គណៈគ្រប់គ្រង ទាំង ១៤នាក់ នៃសាលាគោលដៅដែលអ្នកស្រាវជ្រាវបានចុះស្វែងរកទិន្នន័យ គឺបានបម្រើការងារជាបុគ្គលិកអប់រំ យុវជន និងកីឡា

គឺពី ៥ ដល់១៥ ឆ្នាំ មានចំនួន ៦នាក់ ស្មើនឹង ៤៣ភាគរយ ពី ១៦ ដល់ ២៥ឆ្នាំ មានចំនួន ៥នាក់ ស្មើនឹង ៣៦ភាគរយ ពី២៦ ដល់ ៣៥ មានចំនួន ៣នាក់ ស្មើនឹង ២១ភាគរយ។

**ប្រភេទក្របខណ្ឌ:** គណៈគ្រប់គ្រងទាំង ១៤នាក់ នៃសាលាគោលដៅគឺមានក្របខណ្ឌពីរផ្សេងគ្នា។ គ្រូកម្រិតឧត្តមមានចំនួន ៩នាក់ ស្មើនឹង ៦៤ភាគរយ គ្រូកម្រិត គ្រូមូលដ្ឋានមានចំនួន ៥នាក់ ស្មើនឹង ៣៦ ភាគរយ ។

**កម្រិតសញ្ញាបត្រ:** គណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត ) មានចំនួន ៦នាក់ ស្មើនឹង ៤៣ភាគរយ សញ្ញាបត្របរិញ្ញាបត្រមានចំនួន ៧នាក់ ស្មើនឹង ៥០ភាគរយ សញ្ញាបត្របាក់ឌុបមានចំនួន១នាក់ ស្មើនឹង ៧ភាគរយ។ តាមលទ្ធផលនេះបញ្ជាក់បានថា មិនមានគណៈ គ្រប់គ្រងណាម្នាក់ដែលស្ថិតនៅក្នុង កម្រិត សញ្ញាបត្របណ្ឌិត ឬ បរិញ្ញាបត្ររងនោះឡើយ ។

**រយៈពេលក្លាយជាគណៈគ្រប់គ្រង:** គណៈគ្រប់គ្រង ដែលបានគ្រប់គ្រងស្ថាប័នសិក្សានីមួយៗ មានរយៈពេលខុសៗគ្នាដូចតទៅ៖ គណៈគ្រប់គ្រងដែលបានគ្រប់គ្រង ពី ១ ដល់ ៥ឆ្នាំមានចំនួន ៥នាក់ ស្មើនឹង ៣៦ភាគរយ ពី ៦ ដល់ ១០ឆ្នាំមានចំនួន ២នាក់ ស្មើ ១៤ភាគរយ ពី ១១ ដល់ ១៥ឆ្នាំ មានចំនួន ៤នាក់ ស្មើ២៩ភាគរយ និងពី ១៥ ដល់ ២០ឆ្នាំ មានចំនួន ៣នាក់ ស្មើ២១ភាគរយ ។ តាមទិន្នន័យនេះ បានបង្ហាញថា គ្រប់គ្រងទាំងអស់សុទ្ធតែមានបទពិសោធន៍រយៈពេលច្រើនឆ្នាំ ប៉ុន្តែមិនមានគណៈ គ្រប់គ្រងណាម្នាក់ដែលមានការគ្រប់គ្រងលើសពី ២០ ឆ្នាំនោះទេ។

### ៣.១០.១.២. ព័ត៌មានទូទៅពីគ្រូបង្រៀនតាមមុខវិជ្ជា

បន្ទាប់ពីការបង្ហាញអំពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងនៅផ្នែកខាងលើ នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ នឹងបង្ហាញព័ត៌មានទូទៅមួយចំនួនរបស់គ្រូបានបង្រៀនតាមមុខវិជ្ជា ដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលមានព័ត៌មានលម្អិតពី៖ ថ្នាក់ដែលគ្រូបានបង្រៀន ភេទ អាយុ និងបទពិសោធន៍បង្រៀន ដូច មានក្នុងតារាងខាងក្រោម៖

## តារាងទី៤ ៖ ព័ត៌មានទូទៅពីគ្រូ

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | គ្រូបង្រៀនថ្នាក់ទី | ថ្នាក់ទី១០ | ៣៦ | ៤០% |
| | | ថ្នាក់ទី១១ | ២៥ | ២៧.៨% |
| | | ថ្នាក់ទី១២ | ២៩ | ៣២.២% |
| | | សរុប | ៩០ | ១០០% |
| ២ | ភេទ | ប្រុស | ៥៦ | ៦២.២% |
| | | ស្រី | ៣៤ | ៣៧.៨% |
| | | សរុប | ៩០ | ១០០% |
| ៣ | អាយុ | ២០-៣០ ឆ្នាំ | ៤៥ | ៥០% |
| | | ៣១ -៤០ ឆ្នាំ | ៤១ | ៤៥.៥% |
| | | ៤១-៥០ ឆ្នាំ | ៤ | ៤.៤% |
| | | លើសពី៥០ឆ្នាំ | ០ | ០.០% |
| | | សរុប | ៩០ | ១០០% |

| | | | | |
|---|---|---|---|---|
| ៤ | រយៈពេលនៃការបង្រៀន | ១ ដល់ ៥ឆ្នាំ | ៣៧ | ៤១.១% |
| | | ៦ ដល់ ១០ឆ្នាំ | ២៩ | ៣២.២% |
| | | ១១ ដល់ ១៥ឆ្នាំ | ១៨ | ២០% |
| | | ១៦ឆ្នាំឡើងទៅ | ៦ | ៦.៧% |
| | | សរុប | ៩០ | ១០០% |
| ៥ | មុខវិជ្ជា | ភាសាខ្មែរ | ១០ | ១១.១ |
| | | គណិតវិទ្យា | ១៣ | ១៤.៤ |
| | | គីមីវិទ្យា | ១០ | ១១.១ |
| | | រូបវិទ្យា | ១១ | ១២.២ |
| | | ជីវវិទ្យា | ៧ | ៧.៨ |
| | | ផែនដីវិទ្យា | ៥ | ៥.៦ |
| | | ភូមិវិទ្យា | ៨ | ៨.៩ |
| | | ICT | ២ | ២.២ |
| | | ភាសាអង់គ្លេស | ១៤ | ១៥.៦ |
| | | សិលធម៌- ពលរដ្ឋ | ១០ | ១១.១ |
| | | សរុប | ៩០ | ១០០% |

| | | | | |
|---|---|---|---|---|
| ៦ | កម្រិតសញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | ៥ | ៥.៦% |
| | | បរិញ្ញាបត្រ | ៥៦ | ៦២.២% |
| | | បរិញ្ញាបត្ររង | ២ | ២.២% |
| | | បាក់ឌុប | ២៧ | ៣០% |
| | | សរុប | ៩០ | ១០០% |

តាមទិន្នន័យតារាងខាងបានបង្ហាញថា គ្រូតាមឯកទេសភាគច្រើនគឺបង្រៀនថ្នាក់ទី១០ ដែលក្នុងនោះមានគ្រូចំនួន ៣៦នាក់ ក្នុងចំណោម៩០នាក់ ស្មើនឹង ៤០ភាគរយ គ្រូបង្រៀនថ្នាក់ទី១២ មានចំនួន ២៩នាក់ ក្នុងចំណោម ៩០នាក់ ស្មើនឹង ៣២.២ ភាគរយ។ ក្រៅពីនោះជាគ្រូបង្រៀថ្នាក់ទី ១១ មានចំនួន ២៥នាក់ ស្មើនឹង ២៧.៨ ភាគរយ។

**ភេទៈ** គ្រូបង្រៀនតាមឯកទេសភាគច្រើន ជាគ្រូបុរសមានចំនួន ៥៦នាក់ ក្នុងចំណោម ៩០នាក់ ស្មើនឹង ៦២.២ភាគរយ ក្រៅពីនោះជាគ្រូបង្រៀនជានារីដែលមានចំនួន ៣៤នាក់ ស្មើនឹង ៣៧.៨ភាគរយនៃគ្រូសរុប ៩០នាក់។

**អាយុៈ** តាមទិន្នន័យ គ្រូបង្រៀនភាគច្រើនមានអាយុ ពី ២០ ដល់ ៣០ឆ្នាំ ដែលមានចំនួនរហូតដល់ ៤៥នាក់ក្នុងចំណោម ៩០នាក់ ស្មើនឹង ៥០ភាគរយ រីឯគ្រូបង្រៀនដែលមានអាយុចន្លោះពី ៣១ ដល់ ៤០ ឆ្នាំ មានចំនួន ៤១នាក់ ស្មើនឹង៤៥.៥ភាគរយ ក្រៅពីនេះគឺជាគ្រូបង្រៀនដែលមានអាយុពី ៤១-៥០ ឆ្នាំ មានចំនួន ៤នាក់ ស្មើនឹង ៤.៤ភាគរយនៃគ្រូសរុប ៩០នាក់។ ដូចនេះមិនមានគ្រូបង្រៀនណាម្នាក់មានអាយុលើសពី ៥០ឆ្នាំ ឡើងទៅនោះទេ។

**រយៈពេលនៃការបង្រៀនៈ** តាមការស្រង់ទិន្នន័យ និងការបង្ហាញក្នុងតារាងខាងលើនេះយើងឃើញថាគ្រូបង្រៀនដែលមានរយៈពេលនៃកាបង្រៀនចាប់ពី ១ ដល់ ៥ឆ្នាំ មានចំនួន ៣៧នាក់ ស្មើនឹង ៤១.១ភាគរយ គ្រូបង្រៀនដែលមានរយៈពេលនៃការបង្រៀនចន្លោះពី ៦ ដល់១០ឆ្នាំមានចំនួន ២៩នាក់ ស្មើនឹង ៣២.២ភាគរយ គ្រូបង្រៀនដែលមានរយៈពេលនៃការបង្រៀនចន្លោះពី ១១ ដល់ ១៥ឆ្នាំ មានចំនួន ១៨នាក់ ស្មើនឹង២០ភាគរយ។ ចំណែកគ្រូបង្រៀនដែលមានរយៈពេលនៃការបង្រៀនលើសពី ១៦ ឆ្នាំ មានចំនួនតែ ៦នាក់ប៉ុណ្ណោះ ដែលគិតជាភាគរយស្មើនឹង ៦.៧ភាគរយ។

**គ្រូបង្រៀនតាមមុខវិជ្ជាៈ** នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានសិក្សាលើគ្រូដែលមានមុខវិជ្ជាខុសៗគឺភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា ICT សីលធម៌ពលរដ្ឋ និងភាសាបរទេស។

ជាលទ្ធផលដែលទទួលបានពីការចូលរួមមានគ្រូ ភាសាខ្មែរចំនួន ១០នាក់ ស្មើ ១១.១ភាគរយ គ្រូគណិតវិទ្យាមានចំនួន ១៣នាក់ ស្មើ ១៤.៤ភាគរយ គ្រូរូបវិទ្យាមានចំនួន ១១នាក់ ស្មើនឹង ១២.២ភាគរយ គ្រូឯកទេសគីមីវិទ្យាមានចំនួន ១០នាក់ ស្មើនឹង ១១.១ភាគរយ គ្រូជីវវិទ្យាមាន ៧នាក់ ស្មើនឹង៧.៨ភាគរយ ICT មានចំនួន ២នាក់ ស្មើនឹង ២.២ភាគរយ គ្រូភូមិវិទ្យាមានចំនួន ៨នាក់ ស្មើនឹង ៨.៩ ភាគរយ ផែនដីវិទ្យាមានចំនួន ៥នាក់ស្មើ ៥.៦ភាគរយ គ្រូសីលធម៌ពលរដ្ឋមានចំនួន ១០នាក់ ស្មើនឹង ១១.១ភាគរយ និងគ្រូភាសាអង់គ្លេសចំនួន ១៤នាក់ ស្មើនឹង ១៥.៦។

### ៣.១០.១.៣. ព័ត៌មានទូទៅពីសិស្ស

ដូចទៅនឹងការរៀបរាប់មុនៗនៃពីរចំណុចខាងលើ នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវនឹងបង្ហាញអំពីព័ត៌មានទូទៅរបស់សិស្សានុសិស្ស ដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលរួមមានព័ត៌មានលម្អិតពីៈ

ថ្នាក់ដែលពួកគេគេកំពុងរៀន ភេទ អាយុ នឹងកម្រិតគ្រួសារ ដូចមានក្នុងតារាងខាងក្រោមៈ

## តារាងទី ៥៖ ព័ត៌មានទូទៅពីសិស្ស

| ល.រ | បរិយាយ | | សរុប | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ៤៦ | ៤៧.៩% |
| | | ស្រី | ៥០ | ៥២.១% |
| | | **សរុប** | **៩៦** | **១០០%** |
| ២ | ថ្នាក់ | ១០ | ៣២ | ៣៣.៣% |
| | | ១១ | ២៤ | ២៥% |
| | | ១២ | ៤០ | ៤១.៧% |
| | | **សរុប** | **៩៦** | **១០០%** |
| ៣ | អាយុ | ១០-១៥ | ១០ | ១០.៤% |
| | | ១៦-២០ | ៧៦ | ៧៩.២% |
| | | ២១ - ២៥ | ១០ | ១០.៤% |
| | | **សរុប** | **៩៦** | **១០០%** |
| ៤ | កម្រិតជីវភាព | កម្រិតទាប | ១៧ | ១៧.៧% |
| | | កម្រិតមធ្យម | ៧៨ | ៨១.៣% |

| | | | | |
|---|---|---|---|---|
| | | កម្រិតបង្គួរ | ១ | ១% |
| | | **សរុប** | **៩៦** | **១០០%** |

**ភេទ៖** សិស្សភាគច្រើនដែលបានចូលរួមឆ្លើយកម្រងសំណួរ ជាភេទនារី ដែលមានរហូតដល់ចំនួន៥០ នាក់ស្មើនឹង ៥២.១ ភាគរយ។ ក្រៅពីនេះជាភេទបុរសដែលមានចំនួន ៤៦ នាក់ ស្មើនឹង ៤៧.៩ ភាគរយ នៃសិស្សសរុប៩៦នាក់។

**អំពីថ្នាក់រៀន៖** តាមទិន្នន័យក្រាហ្វិច ខាងលើ បានបង្ហាញថា សិស្សដែលបានចូលរួមឆ្លើយកម្រងសំណួរ ភាគច្រើនគឺថ្នាក់ទី ១២ ដែលមានចំនួន ៤០នាក់ក្នុងចំណោម ៩៦នាក់ ស្មើនឹង ៤១.៧ភាគរយ ខណៈដែលសិស្សថ្នាក់ទី១០ មានត្រឹមតែ ៣២ នាក់ស្មើនឹង ៣៣.៣ភាគរយ ។ ក្រៅពីនេះ គឺ ជាសិស្សថ្នាក់ទី១១ ដែលមានចំនួន ២៤នាក់ ស្មើនឹង ២៥ភាគរយ នៃសិស្សសរុប ៩៦នាក់ ។

**អាយុ៖** សិស្សភាគច្រើនមានអាយុ ចន្លោះពី ១៦ ដល់ ២០ ឆ្នាំដែលបានចូលរួមឆ្លើយកម្រងសំណួរដែលអ្នកស្រាវជ្រាវបានដាក់ឲ្យមានរហូតដល់ ៧៦នាក់ ស្មើនឹង ៧៩.២ភាគរយ ចំណែកសិស្សដែលមានអាយុក្នុងកម្រិត ១០ ដល់ ១៥ ឆ្នាំ មានចំនួន១០នាក់ គិតជាភាគរយគឺស្មើនឹង ១០.៤ភាគរយ ស្របពេលដែលសិស្សមានអាយុ ពី ២១ ដល់ ២៥ឆ្នាំ ក៏មានចំនួន ១០នាក់ស្មើនឹង ១០.៤ភាគផងដែរ ។

**កម្រិតជីវភាព៖** តាមរយៈការបង្ហាញខាងលើ វាជាការ បង្ហាញអំពីកម្រិតនៃជីវភាពរបស់សិស្ស នៅក្នុងសំណាកនៃអ្នកស្រាវជ្រាវដែលបានប្រមូលពីចំនួនសិស្ស ៩៦នាក់។ យើងអាចពិនិត្យឃើញថា សិស្សដែលស្ថិតនៅក្នុងកម្រិតទាបមានចំនួន ១៧នាក់ដែលស្មើនឹង ១៧.៧ ភាគរយ សម្រាប់សិស្ស ដែលមានកម្រិតជីវភាពមធ្យមមានចំនួន ៧៨នាក់ ស្មើនឹង ៨១.៣ភាគរយ សិស្សដែលស្ថិតនៅកម្រិតបង្គួរ មានចំនួន ១នាក់ ស្មើនឹង ១ភាគរយ ។ ដូចនេះមិនមានសិស្សដែលមានជីវភាពកម្រិតខ្ពស់បានចូលរួមផ្តល់ទិន្នន័យនោះទេ ។

# ជំពូកទី ៤
# លទ្ធផលនិង ការពិភាក្សា

# ជំពូកទី៤

# លទ្ធផលនិងការពិភាក្សា

នៅក្នុងជំពូកទី៤ នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើបទបង្ហាញពីលទ្ធនៃការវិភាគទិន្នន័យ ការបកស្រាយ នឹងការពិភាក្សានូវអ្វីដែលបានឃើញតាមរយៈការបំពេញកម្រងសំណួរ របស់ធាតុសំណាកដែលរួមមាន លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ គ្រូបង្រៀនតាមមុខវិជ្ជា និងសិស្សានុសិស្សថ្នាក់ទី១០ ទី១១ ទី១២ ទៅលើប្រធានបទ **ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀននិងគ្រប់គ្រងនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី** ។ ហើយរាល់ចំណុចសំខាន់ៗផ្សេងៗទៀតដែលទាក់ទងនឹងប្រធានបទ ត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា ។ កម្មវិធី SPSS ត្រូវបានប្រើសម្រាប់បញ្ចូលទិន្នន័យ វិភាគ និងតារាង បន្ទាប់មកធ្វើការបកស្រាយ។ ដោយទិន្នន័យចេញពីកម្មវិធី SPSS ដើម្បីស្វែងយល់ពីស្ថានភាព ក្នុងការប្រើប្រាស់ ICT ក្នុងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការគ្រប់គ្រង របស់នាយកសាលានៅ កម្រិតធម្យមសិក្សាទុតិយភូមិ ។ នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ បានធ្វើ ការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួររបស់អ្នកចូលរួម។ ការវិភាគលើកម្រង សំណួរ មានគោលបំណង ស្វែងរកឲ្យឃើញអំពីស្ថានភាពក្នុងការប្រើប្រាស់ ឧបករណ៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ទន្ទឹមនឹង នោះ អ្នកសិក្សាស្រាវជ្រាវក៏ធ្វើការសិក្សាស្វែងរកពីបញ្ហាប្រឈម នៅក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន របស់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូតាមមុខវិជ្ជាផងដែរ។ ទិន្នន័យលើ កម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធនានាមានដូចជា៖ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូបង្រៀន និង សិស្សានុសិស្ស ( កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ ទី១២ ) ត្រូវបានវិភាគ ឆ្លុះបញ្ចាំងពី ស្ថានភាពក្នុងការប្រើប្រាស់ ឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងការបង្រៀន និង គ្រប់គ្រង ហើយលទ្ធផលនៃការពិភាក្សានេះ គឺធ្វើឡើងតំណាងឲ្យទិដ្ឋភាពរួមនៃការប្រើប្រាស់ ICT សម្រាប់ ការបង្រៀន និងគ្រប់គ្រង នៅតាមគ្រឹះស្ថានសិក្សាសាធារណៈចំនួន ០៨ ក្នុងរតនគិរី។

## ៤.១. លទ្ធផល

ការវិភាគនេះអ្នកស្រាវជ្រាវ បានប្រើប្រាស់កម្មវិធី SPSS ក្នុងការវិភាគរកតម្លៃមធ្យម Mean ក្នុងការវាយតម្លៃកម្រិតនៃការយល់ដឹងរបស់សិស្សក្នុងការប្រើប្រាស់ ICT ក្នុងការសិក្សានៅថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅក្នុងខេត្តរតនគិរីដោយធ្វើ ការកំណត់ការវាយតម្លៃចែកជាប្រាំកម្រិត ទៅតាមមធ្យមភាគដូចខាងក្រោម ៖

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{Highest Score - Lowest Score}}{\text{No. of Levels}} = \frac{5 - 1}{5} = \frac{4}{5} = 0.80$$

១. តម្លៃ Meanចាប់ពី 1 - 1.80 = ខ្សោយណាស់

២. តម្លៃ Meanចាប់ពី 1.81 - 2.60 = ខ្សោយ

៣. តម្លៃ Meanចាប់ពី 2.61 - 3.40 = មធ្យម

៤. តម្លៃ Meanចាប់ពី 3.41 - 4.20 = ល្អ

៥. តម្លៃ Meanចាប់ពី 4.21 - 5.00 = ល្អណាស់

## ៤.១.១. ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់សិស្ស

### ៤.១.១.១. កម្រិតនៃការយល់ដឹងរបស់សិស្សក្នុងការប្រើប្រាស់ឧបករណ៍ ICT

តារាងទី៦ ៖ កម្រិតយល់ដឹងលើការប្រើប្រាស់ឧបករណ៍ICT

| ល.រ | កម្រិតការយល់ដឹងលើការប្រើប្រាស់ឧបករណ៍ICT | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| 1 | ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | 96 | 2.16 | ខ្សោយ |
| 2 | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | 96 | 3.55 | ល្អ |
| 3 | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ ( Delete, move, save. ) | 96 | 2.68 | មធ្យម |
| 4 | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point ) | 96 | 2.86 | មធ្យម |
| 5 | ការធ្វើបទបង្ហាញដោយប្រើ Projector | 96 | 1.61 | ខ្សោយណាស់ |
| 6 | ការស្វែងរកឯកសារពាក់ពន្ធ័មេរៀនតាមអ៊ិនធឺណេត | 96 | 2.99 | មធ្យម |
| 7 | ការកែរូបភាព ឬវីដេអូផ្សេងៗ | 96 | 2.32 | ខ្សោយ |
| 8 | ទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការរៀន | 96 | 2.96 | មធ្យម |
| 9 | ប្រើប្រាស់សារអេឡិចត្រូនិច Email | 96 | 2.62 | មធ្យម |
| 10 | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | 96 | 3.90 | ល្អ |
| 11 | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | 96 | 3.46 | ល្អ |
| 12 | ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) | 96 | 2.66 | មធ្យម |
| 13 | ការប្រើប្រាស់កម្មវិធី Zoom Meeting | 96 | 2.23 | ខ្សោយ |
| 14 | ការប្រើប្រាស់កម្មវិធី Google Meet | 96 | 2.66 | មធ្យម |
| 15 | ការចែករំលែកឯកសារមេរៀនដល់មិត្តភក្តិពីអ៊ិនធឺណេត | 96 | 3.01 | មធ្យម |
| សរុប | | | 2.77 | មធ្យម |

តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា តម្លៃមធ្យមសរុបគឺ 2.77 នេះមានន័យថា សិស្សភាគច្រើនមានកម្រិតនៃការយល់ដឹងទៅលើការប្រើប្រាស់ ICT នៅកម្រិតមធ្យមនៅឡើយ។ ដោយឡែកនៅចំណុចសូចនាករទី១០ (ប្រើប្រាស់សារអេឡិចត្រូនិច Telegram) សូចនាករទី ១១(ប្រើប្រាស់សារអេឡិចត្រូនិច Telegram) និងសូចនាករទី២ (ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត) បានបង្ហាញថាការយល់ដឹងរបស់សិស្សទៅលើការប្រើប្រាស់ ICT គឺល្អ នេះសរបញ្ជាក់អោយឃើញថាសិស្សទាំងអស់ក្នុងខេត្តរតនគិរីមានការយល់ដឹងទូលំទូលាយជាមួយការប្រើប្រាស់ឧបការណ៍ICTក្នុងការសិក្សារបស់ពួកគេ

ជាពិសេស ជាមួយកម្មវិធី Messenger ដែលមានតម្លៃមធ្យម3.90 ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត មានតម្លៃមធ្យម 3.55 ការប្រើប្រាស់កម្មវិធី Telegram មានតម្លៃមធ្យម 3.46។

តាមរយៈ សូចនាករទី៣( ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save.) មានតម្លៃមធ្យម 2.66 ទី៤(ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point) មានតម្លៃមធ្យម 2.86 ទី៦ (ការស្វែងរកឯកសារពាក់ពន្ធ័មេរៀនតាមអ៊ិនធឺណេត)មានតម្លៃមធ្យម 2.99 ទី៨ (ទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការរៀន) មានតម្លៃមធ្យម 2.96 ទី៩(ប្រើប្រាស់សារអេឡិចត្រូនិច Email) មានតម្លៃមធ្យម 2.62 ទី១២ (ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) មានតម្លៃមធ្យម 2.66 ទី១៤ (ការប្រើប្រាស់កម្មវិធី Google Meet)មានតម្លៃមធ្យម 2.66 នឹងទី១៥ (ការចែករំលែកឯកសារមេរៀនដល់មិត្តភក្តិពីអ៊ិនធឺណេត)មានតម្លៃមធ្យម 3.01 នៃតារាងខាងលើដដែលបានបង្ហាញថាសិស្សមានកម្រិតនៃការយល់ដឹងទៅលើការប្រើប្រាស់ឧបករណ៍ICT ត្រឹមតែកម្រិតមធ្យមតែប៉ុណ្ណោះ។

សម្រាប់សូចនាករទី១ (ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ) មានតម្លៃមធ្យម 2.16 ទី៧ (ការកែរូបភាព ឬវីដេអូផ្សេងៗ)មានតម្លៃមធ្យម 2.32 ទី១៣ (ការប្រើប្រាស់កម្មវិធី Zoom Meeting) មានតម្លៃមធ្យម 2.23 សូចនាករទាំងនេះបានបង្ហាញពីកម្រិតខ្សោយដែលសិស្សភាគច្រើនយល់ដឹងពីការប្រើប្រាស់ឧបករណ៍ទាំងនេះបានតិចតួច។

សូចនាករចុងក្រោយ គឺចំណុចទី៥(ការធ្វើបទបង្ហាញដោយប្រើ Projector) ដោយផ្អែកលើលទ្ធផលបានបង្ហាញថាសិស្សភាគច្រើនមានការយល់ដឹងបានតិចតួចបំផុតពាក់ព័ន្ធទៅនឹងការប្រើប្រាស់ Projector ដែលមានតម្លៃមធ្យម ស្មើរនឹង 1.61។

## ៤.១.១.២. ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការសិក្សារបស់សិស្ស

តារាងទី៧៖ ស្ថានភាពទូទៅនៃការប្រើប្រាស់ICT

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT | ចំនួន | មធ្យម | កម្រិត |
|---|---|---|---|---|
| 1 | តើនៅសាលារបស់អ្នកមានបន្ទប់កុំព្យូទ័សម្រាប់សិក្សាកម្មវិធី ICTដែរឬទេ ? | 96 | 1.83 | ខ្សោយ |
| 2 | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍ដែរឬទេ ? | 96 | 2.05 | ខ្សោយ |
| 3 | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ។ | 96 | 2.09 | ខ្សោយ |
| 4 | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ ? | 96 | 2.77 | មធ្យម |
| 5 | តើអ្នកមានចងក្រងក្រុមសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ | 96 | 3.62 | ល្អ |
| 6 | តើសាលារបស់អ្នកធ្លាប់ផ្តល់សម្ភារៈ ICT ដល់អ្នកដែរឬទេ ? | 96 | 1.26 | ខ្សោយណាស់ |
| 7 | តើសាលារបស់អ្នកមានគ្រូបង្រៀនកុំព្យូទ័ដែរឬទេ ? | 96 | 2.08 | ខ្សោយ |
| 8 | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ពីICTទៅដល់អ្នកដែឬទេ ? | 96 | 1.72 | ខ្សោយណាស់ |
| 9 | តើសាលារបស់អ្នកមាន Facebook page ផ្សព្វផ្សាយសម្រាប់សាលាដែរឬទេ ? | 96 | 3.54 | ល្អ |
| 10 | តើអ្នកមានទូរសព្ទ័ដៃ ឬកុំព្យូទ័ដែរឬទេ ? | 96 | 3.88 | ល្អ |
| 11 | តើអ្នកបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀនដែរឬទេ ? | 96 | 2.65 | មធ្យម |
| 12 | តើអ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិដែរឬទេ ? | 96 | 3.65 | ល្អ |
| 13 | តើអ្នកបានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងគ្រូ ឬនាយកសាលាដែរឬទេ ? | 96 | 3.61 | ល្អ |
| 14 | តើអ្នកមានបានប្រើប្រាស់កុំព្យូទ័រ ឬទូរសព្ទ័ក្នុងការសិក្សាដែរឬទេ ? | 96 | 3.98 | ល្អ |
| សរុប | | | 2.76 | មធ្យម |

តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា តម្លៃមធ្យមសរុបគឺ 2.76 នេះមានន័យថា ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការសិក្សារបស់សិស្ស ស្ថិតនៅកម្រិតមធ្យមនៅឡើយ។ សម្រាប់ចំណុចសូចនាករទី៥ ទី៩ ទី១០ ទី១២ ទី១៣ និងទី១៤ នៃតារាងខាងលើនេះដែរបានបង្ហាញថា ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការសិក្សារបស់សិស្ស ស្ថិតនៅកម្រិតល្អ ពោលគឺ សូចនាករទី៥ (ការចងក្រងក្រុមសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក) គឺស្ថិតនៅកម្រិតល្អ ដែលមានមធ្យម 3.62 នេះមានន័យថាសិស្សមានការខិតខំស្វះស្វែងក្នុងការសិក្សារៀនសូត្រតាមរយៈការសិក្សាពីចម្ងាយដោយមានការចងក្រងជាក្រុមសិក្សាតាមរយៈប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក។ សូចនាករទី៩ (Facebook pageផ្លូវការសម្រាប់សាលា) គឺស្ថិតនៅកម្រិតល្អ ដែលមានមធ្យម 3.54 លទ្ធផលនេះបង្ហាញអោយឃើញថា សាលាពិតជាយកចិត្តទុកដាក់ទៅលើការសិក្សាអប់រំរបស់សិស្សស្សានុសិស្សពិតមែន ដោយមានការរៀបចំបង្កើតនូវ Facebook Page ផ្ទាល់ខ្លួនដែលបង្កភាពងាយស្រួលដល់សិស្សក្នុងតាមដានរាល់ព័ត៌មានទាំងឡាយអំពីការសិក្សា ក៏ដូចជាមេរៀនផ្សេងៗផងដែរ។ សូចនាករទី១០ (លទ្ធភាពដែលសិស្សមានទូរសព្ទ័ដៃ ឬកុំព្យូទ័រក្នុងការប្រើប្រាស់ទៅលើការសិក្សា) ស្ថិតនៅកម្រិតល្អ ដែលមានមធ្យម3.88 លទ្ធផលនេះក៏បានឆ្លុះបញ្ចាំងផងដែរថា ដើម្បីស្របតាមការវិវឌ្ឍរបស់សង្គម ជាពិសេសក្នុងបរិបថកូវីដនេះផងដែរ សិស្សានុសិស្សគឺពិតជាខិតខំស្មុះស្មាក្នុងការដើរអោយទាន់សម័យកាលដោយធ្វើការបំពេញទៅតាមលក្ខខ័ណ្ឌនៃការសិក្សាពីចម្ងាយ ដោយធ្វើការទិញនូវឧបករណ៍បច្ចេកវិទ្យានានា ដូចជា ទូរសព្ទ័ ថេបប្លេត កុំព្យូទ័រ ជាដើម។ សូចនាករទី១២ (ការប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ) សូចនាករនេះគឺស្ថិតនៅកម្រិតល្អ ដែលមានមធ្យម3.65 នេះគឺឆ្លុះបញ្ចាំងអោយឃើញថា សិស្សពិតជាអាចប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទាំងនោះក្នុងការទំនាក់ទំនងគ្នា ជាពិសេសបម្រើដល់ការសិក្សា របស់ពួកគេទាំងអស់គ្នាផងដែរ។ សូចនាករទី១៣ (ការប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងជាមួយគ្រូ ឬនាយកសាលា) សូចនាករនេះទៀតសោធគឺស្ថិតនៅកម្រិតល្អ ដែលមានមធ្យម 3.61 នេះជាសញ្ញាបង្ហាញថា សិស្សពិតជាបានយល់ដឹងទូលំទូលាយអំពីការប្រើប្រាស់ICT ក្នុងការទំនាក់ទំនង ជាពិសេសជាមួយគណៈគ្រប់គ្រងក៏ដូចជាគ្រូបង្រៀនដើម្បីស្វែងរកព័ត៌មានផ្សេងៗ។ សូចនាករទី១៤ (ការប្រើប្រាស់កុំព្យូទ័រ ឬទូរសព្ទ័ក្នុងការសិក្សា)

ចំពោះសូចនាករនេះក៏ស្ថិតនៅកម្រិតល្អ ដោយមានមធ្យម 3.98 ខ្ពស់ជាងគេនៅក្នុងចំណោមសូចនាករទាំងអស់ នេះក៏បានបង្ហាញផងដែរថាសិស្សពិតជាបានខិតខំសិក្សារៀនសូត្របើទោះបីជាស្ថិតក្នុងស្ថានភាពដែលមាន កូវីដ-១៩ នេះក៏ដោយ។ សម្រាប់សូចនាករទី៤(ប្រព័ន្ធអ៊ិនធឺណេតនៅតាមសាលារៀន) គឺស្ថិតនៅកម្រិតមធ្យម ដែលមាន មធ្យម 2.77 និងសូចនាករទី១១ (ការប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន) ស្ថិតនៅកម្រិតមធ្យម ដែលមានមធ្យម 2.65។

សូចនាករទី១ (បន្ទប់សិក្សាកុំព្យូទ័សម្រាប់សិក្សាកម្មវិធី ICT) គឺស្ថិតនៅកម្រិតខ្សោយ ដែលមាន មធ្យម 1.83 នេះមានន័យថានៅតាមសាលាភាគច្រើនមិនមានបន្ទប់សម្រាប់ដាក់កុំព្យូទ័រដើម្បីទុកបង្រៀនសិស្សទេ។ សូចនាករទី២ (ចំនួនកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់សិក្សា)ក៏ស្ថិតនៅកម្រិតខ្សោយដូចគ្នាដែរដែលមានមធ្យម 2.05 ដែលយើងអាចនិយាយបានថាវាជាលទ្ធផលមួយដែលស្តែងពីកង្វះខាតឧបករណ៍ICT សម្រាប់ធ្វើការបង្រៀនសិស្ស។ សូចនាករទី៣ ក៏ដូចគ្នាដែរដែលបង្ហាញពីកង្វះម៉ោងសិក្សាសម្រាប់សិស្ស ក្នុងនោះមធ្យមរបស់ចំណុចនេះគឺបានត្រឹមតែ 2.09 តែប៉ុណ្ណោះគឺស្ថិតនៅកម្រិតខ្សោយ។ ដោយឡែកសម្រាប់សូចនាករទី៧ បង្ហាញពីការខ្វះខាត់គ្រូបង្គោលផ្នែកICT ដែលសូចនាករនេះ ស្ថិតនៅកម្រិតខ្សោយ និងមានមធ្យមតែ 2.08 ប៉ុណ្ណោះ។

សូចនាករទី៨ (ការផ្តល់សម្ភារៈ ICT ដល់គ្រូ) ស្ថិតនៅកម្រិតខ្សោយបំផុត ដែលមានមធ្យម 1.26 មានន័យថាលោកគ្រូ អ្នកគ្រូ នៅតាមសាលាខ្លះទទួលបានសម្ភារៈ ICTតិចតួចបំផុត។ មិនខុសគ្នាពីសូចនាករទី៨ដែរ ដែលស្ថិតនៅកម្រិតខ្សោយបំផុត ដែលមានមធ្យម 1.72។

### ៤.១.១.៣. ស្ថានភាពនៃការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា

តារាងទី៨៖ ការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា

| | ស្ថានភាពនៃការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| 1 | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការសិក្សាតាមកម្មវិធីមួយណាដែរ? | 83.3% | 7.3% | 4.2% | 3.1% | 1.0% | 1.0% |
| 2 | តើអ្នកធ្វើការទំនាក់ទំនងជាមួយនាយកដោយប្រើប្រាស់កម្មវិធីមួយណា? | 74.0% | 20.8% | 2.1% | 0.00% | 0.00% | 3.1% |
| 3 | តើអ្នកចូលរួមការប្រជុំនានាជាមួយគ្រូឬនាយកដោយប្រើប្រាស់កម្មវិធីមួយណា? | 47.9% | 9.4% | 35.4% | 6.3% | 0.00% | 1.0% |
| 4 | តើអ្នកទទួលព័ត៌មានអំពីការប្រជុំនានាដោយមធ្យោបាយណា? | 77.1% | 15.6% | 3.1% | 3.1% | 0.00% | 1.0% |
| 5 | តើអ្នកធ្វើការទំនាក់ទំនងជាមួយមិត្តភក្តិដោយប្រើប្រាស់កម្មវិធីមួយណា? | 20.8% | 76.0% | 1.0% | 0.00% | 0.00% | 2.1% |
| 6 | ប្រសិនបើមានការប្រឡងពីចម្ងាយតើកម្មវិធីអ្វីដែលគ្រូរបស់អ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ? | 53.1% | 8.3% | 19.8% | 5.2% | 13.5% | 0.00% |
| 7 | តើអ្នកផ្ញើវិញ្ញាសាប្រឡងជូនគ្រូរបស់អ្នកដោយមធ្យោបាយណា? | 69.8% | 11.5% | 8.3% | 2.1% | 7.3% | 1.0% |
| 8 | តើកម្មវិធីណាមួយដែលអ្នកបានប្រើក្នុងការរៀនតាមអនឡាញនេះ? | 57.3% | 5.2% | 26.0% | 8.3% | 2.1% | 1.0% |
| 9 | តើអ្នកចុះវត្តមានរបស់អ្នកដោយមធ្យោបាយណា? | 58.3% | 9.4% | 17.7% | 2.1% | 12.5% | 0.00% |
| 10 | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង? | 49.0% | 10.4% | 22.9% | 13.5% | 1.0% | 3.1% |
| សរុប | | 59.06% | 17.39% | 14.05% | 4.37% | 3.74% | 1.33% |

**តាមរយៈតារាងខាងលើបានបង្ហាញថា៖** កម្មវិធីTelegram គឺជាកម្មវិធីមួយដែលសិស្សនិយមប្រើប្រាស់នៅក្នុងការសិក្សារបស់ពួកគេ ដែលមានមធ្យមភាគសរុប 59.06% ស្ថិតនៅកម្រិតមធ្យម។ តាមរយៈសូចនាករក៏បានបង្ហាញផងដែរថា កម្មវិធី Telegram ក៏ជាកម្មវិធីដែលសិស្សងាយស្រួលប្រើក្នុងការទំនាក់ទំនងផងដែរ ដែលមានមធ្យមភាគ 49.0% ស្ថិតនៅកម្រិតមធ្យម។ ក្នុងការទំនាក់ទំនងការសិក្សាពីចម្ងាយសិស្សានុសិស្សក៏បានប្រើប្រាស់ កម្មវិធីTelegram ដ៏លើសលុបផងដែរ ដែលមានមធ្យមភាគ 83.3% ស្ថិតក្នុងកម្រិតល្អណាស់។ សូចនាករទី៤ ក៏បានបង្ហាញផងដែរថា សិស្សភាគច្រើនទទួលបានព័ត៌មាននានាពីសាលាក៏តាមរយៈកម្មវិធីTelegram ផងដែរ ដែលមធ្យមភាគ77.1% ស្ថិតក្នុងកម្រិតល្អ។

សរុបមកTelegramគឺជាកម្មវិធីដែលសិស្សភាគច្រើនបានប្រើប្រាស់ក្នុងការទៅនាក់ទំនងគ្នា មិនថាក្នុងម៉ោងសិក្សា រឺម៉ោងរដ្ឋបាលផ្សេងៗ។

## ៤.១.២. ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់គ្រូ

### ៤.១.២.១. កម្រិតនៃការយល់ដឹងរបស់គ្រូបង្រៀនលើការប្រើប្រាស់ICT

តារាងទី៩៖ កម្រិតយល់ដឹងរបស់គ្រូបង្រៀនលើការប្រើប្រាស់ឧបករណ៍ICT

| ល.រ | កម្រិតនៃការយល់ដឹងរបស់គ្រូបង្រៀនលើការប្រើប្រាស់ICT | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| 1 | ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | 90 | 2.80 | មធ្យម |
| 2 | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | 90 | 3.98 | ល្អ |
| 3 | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save. ) | 90 | 3.94 | ល្អ |
| 4 | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point ) | 90 | 2.69 | មធ្យម |
| 5 | ការធ្វើបទបង្ហាញដោយប្រើ Projector | 90 | 2.22 | ខ្សោយ |
| 6 | ការស្វែងរកឯកសារពាក់ពន្ធ័មេរៀនតាមអ៊ិនធឺណេត | 90 | 2.72 | មធ្យម |
| 7 | ការកែរូបភាព ឬវីដេអូផ្សេងៗ សម្រាប់បង្រៀនសិស្ស | 90 | 2.21 | ខ្សោយ |
| 8 | ទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការបង្រៀន | 90 | 2.68 | មធ្យម |
| 9 | ប្រើប្រាស់សារអេឡិចត្រូនិច Email | 90 | 2.61 | មធ្យម |
| 10 | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | 90 | 3.97 | ល្អ |
| 11 | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | 90 | 3.90 | ល្អ |
| 12 | ការប្រើប្រាស់កម្មវិធីរបស់Google ( Classroom, Forms…... ) | 90 | 3.68 | ល្អ |
| 13 | ការប្រជុំ ឬបង្រៀនតាមវីដេអូ Zoom Meeting | 90 | 3.45 | ល្អ |
| 14 | ការប្រជុំ ឬបង្រៀនតាមវីដេអូ Google Meet | 90 | 3.70 | ល្អ |
| 15 | ការចែករំលែកឯកសារមេរៀនដល់សិស្សពីអ៊ិនធឺណេត | 90 | 2.74 | មធ្យម |
| សរុប | | | 3.15 | មធ្យម |

តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការបង្រៀនរបស់គ្រូ គឺស្ថិតនៅកម្រិតមធ្យម ដែលមានតម្លៃមធ្យមសរុបគឺ 3.15 ។

សម្រាប់ចំណុចសូចនាករទី២ (ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត) ស្ថិតនៅកម្រិតល្អ ដែលមានមធ្យម 3.98 ដែលមានន័យថាលោកគ្រូ អ្នកគ្រូភាគច្រើនអាចប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេតបានល្អប្រសើរ។ សូចនាករទី៣ (ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ Delete, move, save. ) ស្ថិតនៅកម្រិតល្អដូចគ្នា ដែលមាន មធ្យម 3.94 នោះមានន័យថាលោកគ្រូ អ្នកគ្រូ អាចគ្រប់គ្រងទិន្នន័យបានល្អប្រសើរផងដែរ។

សូចនាករទី១០ (ប្រើប្រាស់សារអេឡិចត្រូនិច Messenger) ស្ថិតនៅកម្រិតល្អ មានមធ្យម 3.97 ដែនមានន័យថាលោកគ្រូ អ្នកគ្រូ អាចប្រើប្រាស់កម្មវិធី Messenger បានល្អប្រសើរ។ សូចនាករទី១១ (ប្រើប្រាស់សារអេឡិចត្រូនិច Telegram) ទី១២ (ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) ទី១៣ (ការប្រជុំ ឬបង្រៀនតាមវិដេអូ Zoom Meeting) ទី១៤ (ការប្រជុំ ឬបង្រៀនតាមវិដេអូ Google Meet) សុទ្ធតែស្ថិតនៅកម្រិតល្អ ដែលសរបញ្ជាក់ឲ្យឃើញថា លោកគ្រូ អ្នកគ្រូភាគច្រើនអាចប្រើប្រាស់កម្មវិធីទាំងនេះបានល្អប្រសើ។

ងាកមកមើលសូចនាករទី១វិញ (ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ) យើងសង្កេតឃើញថា លោកគ្រូ អ្នកគ្រូភាគច្រើនប្រើបាននៅកម្រិតមធ្យម ដែលមានមធ្យម 2.80។ សម្រាប់សូចនាករទី៤ ដែលនិយាយពីការប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point) វិញក៏មិនខុសពីសូចនាករទី១ដែរដោយ លោកគ្រូអ្នកគ្រូអាចប្រើបាននៅកម្រិតមធ្យមតែប៉ុណ្ណោះ ដែលមានមធ្យម 2.69 ។ សម្រាប់ចំណុចទី៦ ក៏ស្ថិតក្នុងកម្រិតមធ្យមដែរ ដែលមានមធ្យម 2.72 ។ ការទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការបង្រៀន ស្ថិតនៅកម្រិត មធ្យម មានមធ្យម 2.68 ។ ការប្រើប្រាស់សារអេឡិចត្រូនិច Email មានមធ្យម 2.61 ស្ថិតក្នុងកម្រិតមធ្យម។ ការចែករំលែកឯកសារពី Internet ក៏ស្ថិតនៅក្នុងកម្រិតមធ្យមដែរ ដែលមានមធ្យម 2.74។ ដោយឡែកការធ្វើបទបង្ហាញដោយប្រើ Projector មានមធ្យម2.22 និងការកែរូបភាព ឬវីដេអូផ្សេងៗ សម្រាប់បង្រៀន មានមធ្យម 2.21 គឺសុទ្ធតែស្ថិតក្នុងកម្រិតខ្សោយ ដែលមានន័យថាផ្នែកទាំងពីរនេះគឺលោកគ្រូ អ្នកគ្រូមួយចំនួនប្រើបានតិចតួចតែប៉ុណ្ណោះ។

## ៤.១.២.២ ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន។

តារាងទី១០៖ ស្ថានភាពទូទៅនៃការប្រើប្រាស់ICT

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| 1 | តើនៅសាលារបស់អ្នក មានបន្ទប់ធនធានសម្រាប់សិក្សាកម្មវិធី ICT ដែរឬទេ ? | 90 | 1.88 | ខ្សោយ |
| 2 | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់គ្រូនិងសិស្សដែរឬទេ ? | 90 | 2.00 | ខ្សោយ |
| 3 | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ។ | 90 | 2.19 | ខ្សោយ |
| 4 | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ ? | 90 | 2.32 | ខ្សោយ |
| 5 | តើនៅសាលារបស់អ្នកមានការជួយជ្រោមជ្រែងពីអង្គការដៃគូណាទេសម្រាប់ការបង្រៀនពី ICT ? | 90 | 2.12 | ខ្សោយ |
| 6 | តើសាលារបស់អ្នកមានចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ ? | 90 | 3.87 | ល្អ |
| 7 | តើអង្គភាពរបស់អ្នកបានផ្តល់សម្ភារៈ ICT ដល់គ្រូដែរឬទេ ? | 90 | 1.88 | ខ្សោយ |
| 8 | តើអង្គភាពរបស់អ្នកមានជំនួយការបច្ចេកទេសផ្នែកបច្ចេកវិទ្យា ដែរឬទេ ? | 90 | 2.02 | ខ្សោយ |
| 9 | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ICTទៅដល់សិស្សដៃឬទេ ? | 90 | 1.99 | ខ្សោយ |
| 10 | តើសាលារបស់លោក - លោកស្រីមាន គេហទំព័ផ្លូវការសម្រាប់សាលាដែរឬទេ ? | 90 | 1.10 | ខ្សោយខ្លាំង |
| 11 | តើសាលារបស់លោក លោកស្រីមានFacebook pageផ្លូវការសម្រាបសាលាដែរឬទេ ? | 90 | 3.76 | ល្អ |
| 12 | តើក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗនៅសាលារបស់អ្នកមានFacebook page ប្រចាំមុខវិជ្ជាដែរឬទេ ? | 90 | 1.87 | ខ្សោយ |

| | | | | |
|---|---|---|---|---|
| 13 | តើអ្នកមានឧបករណ៍បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ដែរឬទេ? | 90 | 4.22 | ល្អណាស់ |
| 14 | តើអ្នកមានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការបង្រៀនសិស្សដែរឬទេ? | 90 | 4.31 | ល្អណាស់ |
| 15 | តើអ្នកបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬ ស្វែងរកឯកសារដែរឬទេ? | 90 | 3.88 | ល្អ |
| 16 | តើអ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិកដែរឬទេ? | 90 | 4.03 | ល្អ |
| 17 | តើអ្នកបានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងសិស្សានុសិស្ស និងមាតាបិតាសិស្សដែរឬទេ? | 90 | 2.69 | មធ្យម |
| 18 | តើសិស្ស មានបានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការសិក្សាដែរឬទេ? | 90 | 3.63 | ល្អ |
| 19 | តើសិស្សបានប្រើប្រាស់ ICT សម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀនឬស្វែរកឯកសារឬទេ? | 90 | 2.68 | មធ្យម |
| 20 | តើអ្នកគិតថាការគ្រប់គ្រងដោយប្រើ កម្មវិធី (ICT) ជាការគ្រប់គ្រងដែលមានប្រសិទ្ធភាពដែរឬទេ? | 90 | 3.00 | មធ្យម |
| សរុប | | | 2.77 | មធ្យម |

តាមរយៈតារាងខាងលើយើងអាចកំណត់បានថាស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការបង្រៀនរបស់គ្រូមានមធ្យមសរុប 2.77 ស្ថិតក្នុងកម្រិតមធ្យម។

សម្រាប់សូចនាករទី១៣ (ឧបករណ៍បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍) មានមធ្យម 4.22 និងសូចនាករទី១៤ (ការប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការបង្រៀន) មានមធ្យម 4.31 សុទ្ធតែបានឆ្លុះបញ្ចាំងពីកម្រិតមួយដែលលោកគ្រូអ្នកគ្រូអាចមាន និងប្រើឧបករណ៍ទាំងនោះបានយ៉ាងល្អប្រសើរ។

សូចនាករទី៦ (ការចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក) មានមធ្យម 3.87 ស្ថិតក្នុងកម្រិតល្អ ដែលមានន័យថា លោកគ្រូ អ្នកគ្រូពិតជាបានយកចិត្តទុកដាក់លើការងារ ជាពិសេសការបង្រៀន។ សូចនាករទី១១ (ការបង្កើត Facebook pageផ្លូវការសម្រាបសាលា) មានមធ្យម 3.76 ស្ថិតក្នុងកម្រិតល្អ។

សូចនាករទី១៥ (ការប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬ ស្វែងរកឯកសារ) មានមធ្យម 3.88 ស្ថិតក្នុងកម្រិតល្អ មានន័យថាលោកគ្រូ អ្នកគ្រូពិតជាបានយកចិត្តទុកដាក់លើការបង្រៀនរបស់ខ្លួន ដែលខិតខំស្រាវជ្រាវស្វែងរកនូវឯកាសារមេរៀនសម្រាប់សិស្ស។

សូចនាករទី១៦ (ការប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិក) មានមធ្យម 4.03 ស្ថិតក្នុងកម្រិតល្អ មានន័យថា លោកគ្រូអ្នកគ្រូ យល់ដឹងបានល្អប្រសើរពីICT ដែលអាចឈានដល់ការប្រើប្រាស់ក្នុងការទំនាក់ទំនងក្នុងកិច្ចការនានាផងដែរ ។ សូចនាករទី១៨ (ការប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការសិក្សារបស់សិស្ស) មានមធ្យម 3.63 ស្ថិតក្នុងកម្រិតល្អ។ សូចនាករទី១៧ (ការប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងសិស្សានុសិស្ស និងមាតាបិតាសិស្ស)មានមធ្យម 2.69 ស្ថិតក្នុងកម្រិតមធ្យម។ សូចនាករទី១៩ មានមធ្យម 2.68 ស្ថិតក្នុងកម្រិតមធ្យម។ សូចនាករទី២០ (ប្រសិទ្ធភាពនៃការគ្រប់គ្រងដោយប្រើ កម្មវិធី ICT) មានមធ្យម 3.00 ស្ថិតក្នុងកម្រិតមធ្យម នេះមានន័យថាលោកគ្រូ អ្នកគ្រូយល់ឃើញថាការគ្រប់គ្រងដោយប្រើ កម្មវិធី ICTមានប្រសិទ្ធភាពត្រឹមកម្រិតមធ្យមតែប៉ុណ្ណោះ គឺមិនមានប្រសិទ្ធភាពខ្លាំងពេក និងខ្សោយពេកនោះទេ។ ដោយឡែកសូចនាករទី១ (បន្ទប់ធនធានសម្រាប់សិក្សាកម្មវិធី ICT) មានមធ្យម 1.88 ស្ថិតក្នុងកម្រិតខ្សោយ បានន័យថា សាលាភាគច្រើនមិនមានបន្ទប់ធនធានសម្រាប់សិក្សាបច្ចេកទេស ICT នោះទេ រីឯសូចនាករទី២ (កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់គ្រូ និងសិស្សនៅតាមសាលា) មានមធ្យម2.00 ស្ថិតក្នុងកម្រិតខ្សោយ ដែលមានន័យថា នៅតាមសាលាភាគច្រើនមិនមានបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់គ្រូ និងសិស្សនោះទេ។ សូចនាករទី៣ (ម៉ោងសិក្សាមុខវិជ្ជា ICT នៅតាមសាលា) មានមធ្យម 2.19 ស្ថិតក្នុងកម្រិតខ្សោយ នេះសរបញ្ជាក់ថា នៅតាមសាលាភាគច្រើនមិនមានម៉ោងសម្រាប់បង្រៀនវគ្គ ICT ដល់សិស្សនោះទេដោយផ្អែកទៅលើសូចនាករទី២ ដែលបង្ហាញថានៅតាមសាលាភាគច្រើនមិនមានកុំព្យូទ័រសម្រាប់សិក្សាម៉ោងICនេះទេ។ សូចនាករទី៤ (ប្រព័ន្ធអ៊ិនធឺណេតសម្រាប់ប្រើប្រាស់នៅតាមសាលា) មានមធ្យម 2.32 ស្ថិតក្នុងកម្រិតខ្សោយ មានន័យថានៅតាមសាលាភាគច្រើនមិនមានប្រព័ន្ធអ៊ិនធឺណេតសម្រាប់បម្រើដល់ការបង្រៀន និងរៀនឡើយ។ សូចនាករទី៥ (ការ

ជួយជ្រោមជ្រែងពីអង្គការដៃគូនានាសម្រាប់ការបង្រៀនពី ICT) មានមធ្យម 2.12 ស្ថិតក្នុងកម្រិតខ្សោយ មានន័យថានៅតាមសាលាភាគច្រើនមិនទាន់មានការជួយឧបត្ថមគាំទ្រទៅលើផ្នែក ICTទេ ដែលជាហេតុនាំឲ្យសិស្សមានការយល់ដឹងពី ICT នៅមានកម្រិតនៅឡើយ។ សូចនាករទី៧ (ការផ្ដល់សម្ភារៈ ICT ដល់គ្រូដៃរពីសំណាក់អង្គភាពសាមីរបស់ខ្លួន) មានមធ្យម 1.88

ស្ថិតនៅកម្រិតខ្សោយ។ សូចនាករទី៨ (ជំនួយការបច្ចេកទេសផ្នែកបច្ចេកវិទ្យានៅតាមសាលា) មានមធ្យម 2.02 ស្ថិតនៅកម្រិតខ្សោយ បានន័យថានៅតាមសាលាមិនមានជំនួយការបច្ចេកទេសគ្រប់គ្រាន់ទេ ដែលជាហេតុនាំឲ្យការយល់ដឹងរបស់លោកគ្រូ អ្នកគ្រូនៅមានកម្រិត។ សូចនាករទី៩ (ការបង្រៀនវគ្គខ្លី ICTទៅដល់សិស្ស) មានមធ្យម 1.99 ស្ថិតនៅក្នុងកម្រិតខ្សោយ។ សូចនាករទី១០ (គេហទំព័ផ្លូវកាសម្រាប់សាលា) មានមធ្យមភាគ 1.10 ស្ថិតក្នុងកម្រិតខ្សោយ។ សូចនាករទី១២ (Facebook page សម្រាប់ក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗនៅសាលា) មានមធ្យម 1.87 ស្ថិតនៅកម្រិតខ្សោយ មានន័យថា នៅតាមសាលានីមួយៗ ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗស្ទើតែមិនបានបង្កើត Facebook Page សម្រាប់មុខវិជ្ជារបស់ខ្លួននោះទេ។

### ៤.១.២.៣ ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការបង្រៀន។

តារាងទី១១៖ ការប្រើប្រាស់កម្មវិធីICTក្នុងការបង្រៀន

| | ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICT ក្នុងការបង្រៀន | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| 1 | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការងារតាមកម្មវិធីមួយណាដែរ | 90.0% | 4.4% | 5.6% | 0.00% | 0.00% | 0.00% |
| 2 | តើអ្នកធ្វើការទំនាក់ទំនងជាមួយគណៈគ្រប់គ្រងដោយប្រើប្រាស់កម្មវិធីមួយណា | 84.4% | 8.9% | 6.7% | 0.00% | 0.00% | 0.00% |
| 3 | តើអ្នកចូលរួមការប្រជុំនានាជាមួយគណៈគ្រប់គ្រងរបស់អ្នកដោយប្រើប្រាស់កម្មវិធីមួយណា | 17.8% | 2.2% | 73.3% | 4.4% | 1.1% | 1.1% |
| 4 | តើអ្នកទទួលព័ត៌មានអំពីការប្រជុំនានាដោយមធ្យោបាយណា | 82.2% | 4.4% | 13.3% | 0.00% | 0.00% | 0.00% |
| 5 | តើនាយកបញ្ជូនរបាយការផ្សេងៗទៅថ្នាក់មន្ទីរ ដោយមធ្យោបាយណា | 88.9% | 4.4% | 3.3% | 1.1% | 0.00% | 2.2% |
| 6 | តើអ្នកចូលរួមប្រជុំ ជាមួយថ្នាក់ក្រសួងមន្ទីរដោយមធ្យោបាយណា | 21.1% | 2.2% | 62.2% | 10.0% | 2.2% | 2.2% |
| 7 | តើអ្នកធ្វើការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សដោយប្រើប្រាស់កម្មវិធីមួយណា | 27.8% | 14.4% | 2.2% | 1.1% | 24.4% | 30.3% |
| 8 | តើអ្នកធ្វើការទំនាក់ទំនងជាមួយសិស្សដោយប្រើប្រាស់កម្មវិធីមួយណា | 72.2% | 12.2% | 5.6% | 4.4% | 1.1% | 4.4% |
| 9 | ប្រសិនបើប្រឡងពីចម្ងាយ តើកម្មវិធីអ្វីដែលអ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ | 45.6% | 4.4% | 16.7% | 6.7% | 26.7% | 0.00% |
| 10 | តើកម្មវិធីណាមួយដែលអ្នកបានប្រើក្នុងការបង្រៀនតាមអនឡាញនេះ | 45.6% | 4.4% | 38.9% | 7.8% | 3.3% | 0.00% |
| 11 | តើអ្នកចុះវត្តមានរបស់អ្នកដោយមធ្យោបាយណា | 47.8% | 5.6% | 10.0% | 6.7% | 23.3% | 6.7% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 12 | តើអ្នកផ្ញើវិញ្ញាសាប្រឡងប្រចាំខែឬឆមាសជូនគណៈគ្រប់គ្រងដោយមធ្យោបាយណា? | 85.6% | 6.7% | 3.3% | 3.3% | 0.00% | 1.1% |
| 13 | តើអ្នកបញ្ជូនលទ្ធផលប្រចាំខែ ឬឆមាសជូនគណៈគ្រប់គ្រងដោយមធ្យោបាយណា? | 87.8% | 6.7% | 2.2% | 1.1% | 0.00% | 2.2% |
| 14 | តើអ្នកចូលរួមក្នុងវេទិកាពិភាក្សាឬសិក្ខាសាលាផ្សេងៗតាមកម្មវិធីមួយណា? | 22.2% | 5.6% | 10.0% | 2.2% | 2.2% | 2.2% |
| 15 | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង? | 78.9% | 5.6% | 8.9% | 3.3% | 0.00% | 3.3% |
| សរុប | | 59.86% | 5.84% | 17.10% | 3.47% | 5.62% | 3.71% |

តាមរយៈលទ្ធផលវិភាគខាងលើបានបង្ហាញថា៖

លោកគ្រូ-អ្នកគ្រូនៅតាមសាលាភាគច្រើនគាត់ជ្រើសរើសយកកម្មវិធីTelegram ក្នុងការទំនាក់ទំនងផ្សេងៗ ដែលមានមធ្យមភាគសរុប 59.86% គឺស្ថិតក្នុងកម្រិតមធ្យម។ លទ្ធផលក៏បានបង្ហាញផងដែរថា សម្រាប់ការទំនាក់ទំនងការងារផ្សេងៗរបស់លោកគ្រូ អ្នកគ្រូ គឺប្រើប្រាស់Telegram ក្នុងការអនុវត្តការងារស្នូលនៅក្នុងសាលា ដែលមានមធ្យមភាគ 90.0% ស្ថិតក្នុងកម្រិតល្អណាស់។ ចំនែកការបញ្ជូនរបាយការណ៍ទៅថ្នាក់ក្រសួង រឺមន្ទីរ នាយកសាលាក៏ជ្រើសរើសយកកម្មវិធីTelegram ផងដែរដែលមានមធ្យមភាគ 88.9% ស្ថិតក្នុងកម្រិតល្អណាស់។ សម្រាប់ការផ្ញើរ វិញ្ញាសា ឬលទ្ធផលប្រឡងប្រចាំខែក៏លោកគ្រូអ្នកគ្រូនៅតាមសាលាភាគច្រើនគាត់បានជ្រើសរើសយក Telegram ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី ១២ និងទី ១៣ ដែលស្ថិតក្នុងកម្រិតល្អណាស់។ ដោយឡែកការប្រជុំនានាដែលសាលារៀបចំ គឺរៀបចំតាមរយៈ Google Meet ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី៣ ដែលមានមធ្យមភាគ 73.3% ស្ថិតក្នុងកម្រិតល្អ ស្របពេលដែលការប្រជុំនានាដែលរៀបចំដោយថ្នាក់ក្រសួង ក៏ប្រើGoogle Meet ផងដែរដែលមានំធ្យមភាគ 62.2% ស្ថិតក្នុងកម្រិតល្អដូចឡគ្នា។ ដោយឡែកកម្មវិធីទាំងអស់ដែលបានលើកឡើងលោកគ្រូអ្នកគ្រូភាគច្រើនជ្រើរើសយក Telegram ដែលពួកគាត់គិតថាវាងាយស្រួលក្នុងការប្រើប្រាស់មិនមានភាពសាំញ៉ាំ និងមានសុវត្ថិភាពទៀតផង។

## ៤.១.៣ស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នាយក

### ៤.១.៣.១.កម្រិតការយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT

តារាងទី១២៖ កម្រិតយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT

| ល.រ | កម្រិតយល់ដឹងនៃការប្រើប្រាស់ឧបករណ៍ ICT | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| 1 | ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | 14 | 3.48 | ល្អ |
| 2 | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | 14 | 4.29 | ល្អណាស់ |
| 3 | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save.) | 14 | 4.26 | ល្អណាស់ |
| 4 | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point) | 14 | 3.07 | មធ្យម |
| 5 | ការធ្វើបទបង្ហាញដោយប្រើ Projector | 14 | 3.79 | ល្អ |
| 6 | ការស្វែងរកឯកសារពាក់ពន្ធ័នានាតាមអ៊ិនធឺណេត | 14 | 2.93 | មធ្យម |
| 7 | ការកែរូបភាព ឬវីដេអូផ្សេងៗ | 14 | 2.07 | ខ្សោយ |
| 8 | ទាញយកឯកសារពីអ៊ិនធឺណេត | 14 | 3.43 | ល្អ |
| 9 | ប្រើប្រាស់សារអេឡិចត្រូនិច Email | 14 | 2.93 | មធ្យម |
| 10 | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | 14 | 3.43 | ល្អ |
| 11 | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | 14 | 4.50 | ល្អណាស់ |
| 12 | ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) | 14 | 3.86 | ល្អ |
| 13 | ការប្រជុំ ឬបង្រៀនតាមវីដេអូ Zoom Meeting | 14 | 3.41 | ល្អ |
| 14 | ការប្រជុំ ឬបង្រៀនតាមវីដេអូ Google Meet | 14 | 3.45 | ល្អ |
| 15 | ការចែករំលែកឯកសារនានាដល់បុគ្គលិកពីអ៊ិនធឺណេត | 14 | 3.07 | មធ្យម |
| សរុប | | 14 | 3.46 | ល្អ |

ដោយផ្អែកលើតារាងលទ្ធផលខាងលើ នោះយើងទទួលបានលទ្ធផល់ដូចតទៅ៖

តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា កម្រិតនៃការយល់ដឹងរបស់គណៈគ្រប់គ្រងក្នុងការប្រើប្រាស់ ICT គឺស្ថិតនៅកម្រិតល្អ ដែលមានតម្លៃមធ្យមសរុបគឺ 3.46 នេះសបញ្ជាក់អោយឃើញថា គណៈគ្រប់គ្រងនៅតាមសាលាមានការយល់ដឹងបានល្អប្រសើរពីបច្ចេកវិទ្យា ជាពិសេសការប្រើប្រាស់នូវឧបករណ៍ និងកម្មវិធីបច្ចេកទេសមួយចំនួន។

សម្រាប់ចំណុចសូចនាករទី២ (ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត) មានមធ្យម 3.98 ស្ថិតនៅកម្រិតល្អណាស់។ សូចនាករទី៣ (ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save.) មានមធ្យម 4.26 ស្ថិតក្នុងកម្រិតល្អណាស់។ សូចនាករទី១១ (ប្រើប្រាស់សារអេឡិចត្រូនិច Telegram) មានមធ្យម 4.50 ស្ថិតនៅកម្រិតល្អណាស់។ តាមរយៈសូចនាករទាំង៣ខាងលើបានយើងអាចដឹងបានថាគណៈគ្រប់គ្រងគឺមានការយល់ដឹងខ្ពស់ពីការប្រើប្រាស់នូវឧបករណ៍បច្ចេកវិទ្យាទាំងនេះបានយ៉ាងល្អប្រសើរ។

សូចនាករទី១(ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ) មានមធ្យម 3.48 សូចនាករទី៥ (ការធ្វើបទបង្ហាញដោយប្រើ Projector) មានមធ្យម 3.79 សូចនាករទី៨ (ទាញយកឯកសារពីអ៊ិនធឺណេត) មានមធ្យម 3.43 ស្របពេលដែល សូចនាករទី១០ (ប្រើប្រាស់សារអេឡិចត្រូនិច Messenger) ក៏មានមធ្យម 3.43 ផងដែរ។ សូចនាករទី១២ (ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) មានមធ្យម 3.86 សូចនាករទី១៣ (ការប្រជុំ ឬបង្រៀនតាមវីដេអូ Zoom Meeting) មានមធ្យម 3.41 និងសូចនាករទី១៤ (ការប្រជុំ ឬបង្រៀនតាមវីដេអូ Google Meet) មានមធ្យម 3.07 ដែលសូចនាករទាំង៧នេះគឺស្ថិតនៅក្នុងកម្រិតល្អ នេះបញ្ជាក់អោយឃើញថាគណៈគ្រប់គ្រងភាគច្រើនគឺមានការយល់ដឹងបានល្អទៅលើការប្រើប្រាស់នូវឧបករណ៍បច្ចេកវិទ្យាទាំងនោះ។

សូចនារកទី៤ (ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ Word, Excel, power point ) មានមធ្យម 3.07 សូចនាករទី៦ (ការស្វែងរកឯកសារពាក់ពន្ធ័នានាតាមអ៊ិនធឺណេត)មានមធ្យម 2.93 ស្របពេលដែលសូចនាករទី៩ (ប្រើប្រាស់សារអេឡិចត្រូនិច Email) ក៏មានមធ្យម 2.93 ផងដែរ ខណៈពេលដែលសូចនាករទី១៥ (ការចែករំលែកឯកសារនានាដល់បុគ្គលិកពីអ៊ិនធឺណេត) មានមធ្យម 3.07 ដែលសូចនាករទាំង៤នេះគឺស្ថិតនៅកម្រិតមធ្យម នេះមានន័យថា គណៈគ្រប់គ្រងទាំងអស់មានកម្រិតនៃការយល់ដឹងពីការប្រើប្រាស់ឧបការណ៍ទាំង៤ខាងលើមានកម្រិតមធ្យមនៅឡើយ។ ដោយឡែកសម្រាប់សូចនាករទី៧ (ការកែរូបភាព ឬវីដេអូផ្សេងៗ) មានមធ្យមភាគ 2.07 ស្ថិតក្នុងកម្រិតខ្សោយ ដែលមានន័យថាគណៈគ្រប់គ្រងមិនសូវយល់ដឹងច្បាស់ពីការប្រើប្រាស់ និងការកែរូបភាពនានានោះទេ។

### ៤.១.៣.២.ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន

តារាងទី១៣៖ ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងសាលារៀន | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| 1 | តើនៅសាលារបស់អ្នក មានបន្ទប់ធនធានសម្រាប់សិក្សាកម្មវិធី ICT ដែរឬទេ | 14 | 2.07 | ខ្សោយ |
| 2 | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់គ្រូ និងសិស្សដែរឬទេ | 14 | 2.00 | ខ្សោយ |
| 3 | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ | 14 | 2.14 | ខ្សោយ |
| 4 | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ | 14 | 2.14 | ខ្សោយ |
| 5 | តើនៅសាលារបស់អ្នកមានការជួយជ្រោមជ្រែងពីអង្គការដៃគូណាទេសម្រាប់ការបង្រៀនពី ICT | 14 | 2.14 | ខ្សោយ |
| 6 | តើសាលារបស់អ្នកមានចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ ? | 14 | 4.21 | ល្អណាស់ |
| 7 | តើអង្គភាពរបស់អ្នកបានផ្តល់សម្ភារៈ ICT ដល់គ្រូដែរឬទេ | 14 | 1.93 | ខ្សោយខ្លាំង |
| 8 | តើអង្គភាពរបស់អ្នកមានគ្រូបច្ចេកទេសផ្នែកបច្ចេកវិទ្យាដែរឬទេ | 14 | 2.09 | ខ្សោយ |
| 9 | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ICTទៅដល់សិស្សដែឬទេ | 14 | 2.43 | ខ្សោយ |
| 10 | តើសាលារបស់អ្នកមានគេហទំព័រផ្លូវកាសម្រាប់សាលាដែរឬទេ | 14 | 1.14 | ខ្សោយខ្លាំង |
| 11 | តើសាលារបស់អ្នកមានFacebook pageផ្លូវកាសម្រាបសាលាដែរឬទេ | 14 | 3.64 | ល្អ |
| 12 | តើក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗនៅសាលារបស់អ្នកមានFacebook page ប្រចាំមុខវិជ្ជាដែរឬទេ | 14 | 1.93 | ខ្សោយ |

| | | | | |
|---|---|---|---|---|
| 13 | តើបុគ្គលិកនៅសាលារបស់អ្នកមានឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដែរឬទេ | 14 | 4.29 | ល្អណាស់ |
| 14 | តើគ្រូបង្រៀនគាត់មានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការបង្រៀនសិស្សដែរឬទេ | 14 | 4.14 | ល្អ |
| 15 | តើគ្រូបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬស្វែងរកឯកសារដែរឬទេ | 14 | 3.93 | ល្អ |
| 16 | តើបុគ្គលិករបស់អ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិកដែរឬទេ | 14 | 4.50 | ល្អណាស់ |
| 17 | តើពួកគាត់បានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងសិស្សានុសិស្ស និងមាតាបិតាសិស្សដែរឬទេ | 14 | 3.29 | មធ្យម |
| 18 | តើសិស្ស មានបានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការសិក្សាដែរឬទេ | 14 | 3.78 | ល្អ |
| 19 | តើសិស្សបានប្រើប្រាស់ ICT សម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬស្វែងរកឯកសារឬទេ | 14 | 2.85 | មធ្យម |
| 20 | តើអ្នកគិតថាការគ្រប់គ្រងដោយប្រើ កម្មវិធី (ICT) ជាការគ្រប់គ្រងដែលមានប្រសិទ្ធភាពដែរឬទេ | 14 | 3.50 | ល្អ |
| សរុប | | | 3.83 | ល្អ |

ដោយផ្អែកលើតារាងលទ្ធផលខាងលើ នោះយើងទទួលបានលទ្ធផលដូចតទៅ៖

តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រងគឺស្ថិតនៅកម្រិតល្អ ដែលមានតម្លៃមធ្យមសរុបគឺ 3.83 នេះសរបញ្ជាក់អោយឃើញថា នៅតាមសាលានីមួយៗមានការយល់ដឹងបានល្អប្រសើរពីបច្ចេកវិទ្យា ជាពិសេសការប្រើប្រាស់នូវឧបការណ៍ និងកម្មវិធីបច្ចេកទេសមួយចំនួន។

សម្រាប់ចំណុចសូចនាករទី៦ (ការចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក) មានមធ្យម 4.21 សូចនាករទី១៣ (ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍របស់បុគ្គលិកនៅតាមសាលា) មានមធ្យម4.29 និងសូចនាករទី១៦ (ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា

ព័ត៌មាន និងសារគមនាគមន៍របស់បុគ្គលិក ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិក) មានមធ្យម 4.50 ដែលសូចនាករទាំងបីស្ថិតនៅកម្រិតល្អណាស់។

សូចនាករទី១១ (ការបបង្កើតFacebook Page ផ្លូវការសម្រាប់សាលា) មានមធ្យម 3.64 សូចនាករទី១៤ (ការប្រើឧបករណ៍បច្ចេកវិទ្យាសម្រាប់ការបង្រៀន) មានមធ្យម 4.14 សូចនាករទី១៥ (ការប្រើប្រាស់ឧបករណ៍ICT សម្រាប់ការសិក្សាស្រាវជ្រាវ) មានមធ្យម 3.93 សូចនាករទី១៨ (ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការសិក្សាស្រាវជ្រាវរបស់សិស្ស) មានមធ្យម 3.78 និងសូចនាករទី២០ (ប្រសិទ្ធភាពនៃការគ្រប់គ្រងដោយប្រើឧបករណ៍ ICT) មានមធ្យម 3.58 ដែលសូចនាករទាំង៥នេះស្ថិតនៅកម្រិតល្អ។ យើងអាចនិយាយបានថាលទ្ធផលនេះគឺជាលទ្ធផលល្អប្រសើមួយសម្រាប់គណៈគញរប់គ្រង។

សូចនាករទី១៧ (ការប្រើប្រាស់ ICTក្នុងការទំនាក់ទំនងជាមួយសិស្ស) មានមធ្យម 3.29 និង សូចនាករទី១៩ (ការប្រើប្រាស់ឧបករណ៍ICTរបស់សិស្សក្នុងការស្រាវជ្រាវមេរៀន) មានមធ្យម 2.85 ដែលសូចនាករទាំង២នេះស្ថិតក្នុងកម្រិតមធ្យម។

តាមរយៈសំណួរទី១ (បន្ទប់សម្រាប់សិក្សា ICT) តម្លៃមធ្យម 2.07 សំណួរទី២ (ឧបករណ៍ICT បម្រើដល់ការសិក្សា) មានមធ្យម 2.00 សំណួរទី៣ (ម៉ោងសិក្សាICT) មានមធ្យម 2.14 សំណួរទី៤ (ប្រព័ន្ធ internetបម្រើដល់ការងារ និងការសិក្សា) មានមធ្យម 2.14 សំណួរទី៥ (ការជួឧបត្ថមពីដៃគូនានា) មានមធ្យម 2.14 សំណួរទី៨ (គ្រូបច្ចេកទេសផ្នែកបច្ចេកវិទ្យា) មានមធ្យម 2.09 សំណួរទី៩ (ការបង្រៀនវគ្គខ្លី ICTទៅដល់សិស្ស) មានមធ្យម 2.43 និងសំណួរទី១២ (ការបង្កើតFacebook Page សម្រាប់ក្រុមមុខវិជ្ជានីមួយៗ) មានមធ្យម 1.93 ដែលសូចនាករទាំង៨នេះគឺស្ថិតក្នុងកម្រិតខ្សោយ។

សម្រាប់សូចនាករចុងក្រោយគឺ ទី៧ (ការផ្តល់សម្ភារៈICT ដល់គ្រូ) មានមធ្យម 1.93 និងទី១០ (ការបង្កើតគេហទំព័រផ្លូវការសម្រាប់សាលា) មានមធ្យម 1.14 សូចនាករទាំង២នេះស្ថិតក្នុងកម្រិតខ្សោយបំផុត។

## ៤.១.៣.៣.ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការគ្រប់គ្រង

តារាងទី១៤៖ ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការគ្រប់គ្រង

| | ស្ថានភាពនៃការប្រើប្រាស់កម្មវិធីICTក្នុងការគ្រប់គ្រង | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| 1 | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការងារតាមកម្មវិធីមួយណាដែរ? | 100% | 0% | 0.00% | 0.00% | 0.00% | 0.00% |
| 2 | តើអ្នកធ្វើការទំនាក់ទំនងជាមួយបុគ្គលិកដោយប្រើប្រាស់កម្មវិធីមួយណា? | 71.4% | 14.3% | 0.00% | 0.00% | 7.1% | 7.1% |
| 3 | តើអ្នករៀបចំការប្រជុំនានាជាមួយបុគ្គលិករបស់អ្នកដោយប្រើប្រាស់កម្មវិធីមួយណា? | 14.3% | 7.1% | 78.6% | 0.00% | 0.00% | 0.00% |
| 4 | តើអ្នកផ្តល់ព័ត៌មានអំពីការប្រជុំនានាដល់បុគ្គលិក ដោយមធ្យោបាយណា? | 85.7% | 14.3% | 0.00% | 0.00% | 0.00% | 0.00% |
| 5 | តើអ្នកបញ្ជូនរបាយការផ្សេងៗទៅថ្នាក់មន្ទីរ ដោយមធ្យោបាយណា? | 85.7% | 14.3% | 0.00% | 0.00% | 0.00% | 0.00% |
| 6 | តើអ្នកចូលរួមប្រជុំ ជាមួយថ្នាក់ក្រសួងមន្ទីរដោយមធ្យោបាយណា? | 7.1% | 0.00% | 85.8% | 0.00% | 0.00% | 7.1% |
| 7 | តើអ្នកធ្វើការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សដោយប្រើប្រាស់មធ្យោបាយ? | 0.00% | 0.00% | 0.00% | 0.00% | 7.1% | 71.4% |
| 8 | តើអ្នកធ្វើការទំនាក់ទំនងជាមួយសិស្សដោយប្រើប្រាស់មធ្យោបាយមួយណា? | 85.7% | 7.1% | 0.00% | 0.00% | 0.00% | 7.1% |
| 9 | ប្រសិនបើមានការប្រឡងពីចម្ងាយ តើកម្មវិធីអ្វីដែលបុគ្គលិករបស់អ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ? | 14.3% | 0.00% | 0.00% | 0.00% | 85.7% | 0.00% |
| 10 | តើកម្មវិធីណាមួយដែលគ្រូបានប្រើក្នុងការបង្រៀនតាមអនឡាញនេះ? | 21.4% | 0.00% | 57.1% | 21.4% | 0.00% | 0.00% |
| 11 | តើអ្នកគ្រប់គ្រងវត្តមានបុគ្គលិករបស់អ្នកដោយមធ្យោបាយណា? | 78.6% | 7.1% | 7.1% | 0.00% | 7.1% | 0.00% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 12 | តើអ្នកប្រមូលវិញ្ញាសាប្រឡងប្រចាំខែ ឬឆមាសដោយមធ្យោបាយណា? | 78.6% | 0.00% | 14.3% | 7.1% | 0.00% | 0.00% |
| 13 | តើអ្នកប្រមូលលទ្ធផលប្រចាំខែ ឬឆមាសដោយមធ្យោបាយណា? | 92.9% | 0.00% | 7.1% | 0.00% | 0.00% | 0.00% |
| 14 | តើអ្នកចូលរួមក្នុងវេទិកាពិភាក្សា ឬសិក្ខាសាលាផ្សេងៗតាមកម្មវិធីមួយណា? | 7.1% | 0.00% | 64.4% | 21.4% | 7.1% | 0.00% |
| 15 | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង? | 78.7% | 7.1% | 7.1% | 0.00% | 7.1% | 0.00% |
| សរុប | | 48.10% | 4.75% | 21.43% | 3.32% | 8.08% | 6.18% |

### តាមរយៈលទ្ធផលខាងលើយើងអាចនិយាយបានថា៖

គណៈគ្រប់គ្រងភាគច្រើនជ្រើសរើសប្រើប្រាស់Telegramច្រើនជាងគេ ដែលមានភាគរយសរុប 48.10% ដែលស្ថិតក្នុងកម្រិតមធ្យម។ សម្រាប់ការទំនាក់ទំនងការងារផ្សេងៗនៅក្នុងសាលានាយកសាលាភាគច្រើនប្រើប្រាស់កម្មវិធីTelegram ទាំងស្រុងដូចដែលបានបង្ហាញនៅក្នុងសូចនាករទី១ ដែលមានមធ្យមភាគ100% ស្ថិតនៅកម្រិតល្អណាស់ ជាកម្រិតខ្ពស់ជាច់គេ។ សម្រាប់ការប្រជុំនៅក្នុងសាលានាយកជ្រើសរើសប្រើ Google Meet ដើម្បីប្រជុំ ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី៣ ដែលមានមធ្យមភាគ78.6% ស្ថិតក្នុងកម្រិតល្អ។ ការបញ្ជូនរបាយការណ៍ទៅក្រសួងឬមន្ទីរ នាយកសាលាប្រើប្រាស់កម្មវិធី Telegram ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី៥ ដែលមានមធ្យមភាគ85.7% ស្ថិតក្នុងកម្រិតល្អណាស់។ សម្រាប់ការបង្រៀន លោកគ្រូអ្នកគ្រូគាត់បានប្រើប្រាស់កម្មវិធី Google Meet ដែលវាជាកម្មវិធីងាយស្រួលក្នុងការប្រើប្រាស់ ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី១០ ដែលមានមធ្យមភាគ 57.1% ស្ថិតក្នុងកម្រិតល្អ។ សម្រាប់ការចូលរួមសិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយថ្នាក់ក្រសួង នឹងមន្ទីរភាគច្រើនតាមរយៈកម្មវិធីGoogle Meet ផងដែរដូចដែលបានបង្ហាញនៅក្នុងសូចនាករទី៦ និងទី១៤។ សម្រាប់ការប្រឡង លោកគ្រូអ្នកគ្រូភាគច្រើនប្រើGoogle Forms ដូចនៅក្នុងសូចនាករទី៩ ដែលមានមធ្យមភាគ 85.7% ស្ថិតក្នុងកម្រិតល្អណាស់។ ចំណែកឯការប្រមូលវិញ្ញាសា និងលទ្ធផលប្រឡងសាលាក៏តម្រូវអោយប្រើប្រាស់កម្មវិធី Telegram ផងដែរ ដូចដែលបានបង្ហាញនៅក្នុងសូចនាករទី១៣ ដែលមាន

មធ្យមភាគ 92.9%។ សរុបមកកម្មវិធីដែលងាយស្រួលក្នុងការប្រើជាងគេគឺកម្មវិធី Telegram ដូចដែលបានឃើញនៅក្នុងសូចនាករទី១៥ ដែលមានមធ្យមភាគ 78.7% ស្ថិតក្នុងកម្រិតល្អ។

## ៤.២. បញ្ហាប្រឈមនៃការប្រើប្រាស់ ICT

### ៤.២.១ កត្តាប្រឈមរបស់សិស្សលើការប្រើប្រាស់ ICT

តារាងទី១៥៖ កត្តាប្រឈមរបស់សិស្សលើការប្រើប្រាស់ ICT




តាមរយៈលទ្ធផលវិភាគនៃតារាងខាងលើ សូចនាករទី៣ (ការទាញយកកម្មវិធីណាមួយ មកប្រើប្រាស់) មានមធ្យមភាគ 2.94 ទី៧ (ភាពលំបាកក្នុងការស្វែងរកឯកសារពាក់ពន្ធ័មេរៀននៃមុខវិជ្ជានីមួយៗ) មានមធ្យមភាគ 2.86 ដែលសូចនាករទាំងពីរនេះគឺស្ថិតក្នុងកម្រិតមធ្យម មានន័យថាមិនសូវជាបញ្ហានោះទេសម្រាប់សូចនាករទាំងនេះ។

សូចនាករទី១ (ភាពលំបាកនៃការប្រើប្រាស់ឧបករណ៍ ICTដែលអ្នកកំពុងមាន) មានមធ្យម 2.52 សូចនាករទី២ (បញ្ហាក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ) មានមធ្យមភាគ 2.19 សូចនាករ

ទី៤ (បញ្ហាប្រព័ន្ធអ៊ិនធឺណេត) មានមធ្យមភាគ 2.10 សូចនាករទី៥ (ការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត) មានមធ្យម 2.11 សូចនាករទី៦ (ភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT) មានមធ្យមភាគ 2.16 សូចនាករទី៨ (កង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT) មានមធ្យមភាគ 2.19 ដែលសូចនាករទាំង៦នេះ គឺស្ថិតក្នុងកម្រិតខ្សោយ។

ដោយឡែកសូចនាករដែលបង្ហាញពីភាពលំបាក់ខ្លាំង នោះគឺ សូចនាករទី៩ (បញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់ ICT) មានមធ្យមភាគ 1.79 និងទី១០ (បញ្ហាអាកាសធាតុបង្កជាផលលំបាកចំពោះការប្រើប្រាស់ICT)មានមធ្យម 1.77 ដែលសូចនាករទាំង២ស្ថិតក្នុងកម្រិតខ្សោយខ្លាំង។

## ៤.២.២ កត្តាប្រឈមរបស់គ្រូលើការប្រើប្រាស់ ICT

តារាងទី១៦៖ កត្តាប្រឈមរបស់គ្រូលើការប្រើប្រាស់ ICT




តាមរយៈលទ្ធផលវិភាគនៃតារាងខាងលើ សូចនាករទី១ (ភាពលំបាកនៃការប្រើប្រាស់ឧបករណ៍ ICT ដែលអ្នកកំពុងមាន) មានមធ្យម 2.66 ទី៧ (ភាពលំបាកក្នុងការស្វែងរកឯកសារពាក់ពន្ធ័មេរៀននៃមុខវិជ្ជា

នីមួយៗ) មានមធ្យមភាគ 2.66 ដែលសូចនាករទាំងពីរនេះគឺស្ថិតក្នុងកម្រិតមធ្យម មានន័យថាមិនសូវជាបញ្ហានោះទេសម្រាប់សូចនាករទាំងនេះ។

សូចនាករទី២ (បញ្ហាក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ) មានមធ្យមភាគ 2.16 សូចនាករទី៣(ការទាញយកកម្មវិធីណាមួយ មកប្រើប្រាស់) មានមធ្យមភាគ 2.25 សូចនាករទី៥ (ការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត) មានមធ្យម 2.05 សូចនាករទី៦ (ភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT) មានមធ្យមភាគ 2.33 សូចនាករទី៨ (កង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT) មានមធ្យមភាគ 2.04 ដែលសូចនាករទាំង៥នេះ គឺស្ថិតក្នុងកម្រិតខ្សោយ។

ដោយឡែកសូចនាករដែលបង្ហាញពីភាពលំបាក់ខ្លាំង នោះគឺ **សូចនាករទី៤** (បញ្ហាInternet លើការប្រើប្រាស់ICT) មានមធ្យមភាគ 1.78 **សូចនាករទី៧** (កង្វះការយល់ដឹងផ្នែកICTបង្កជាផលលំបាកក្នុងការគ្រប់គ្រង) មានមធ្យមភាគ 1.66 **សូចនាករទី៩** (បញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់ ICT) មានមធ្យមភាគ 1.75 និង**ទី១០** (បញ្ហាអាកាសធាតុបង្កជាផលលំបាកចំពោះការប្រើប្រាស់ICT)មានមធ្យម 1.74 ដែលសូចនាករទាំង៤ស្ថិតក្នុងកម្រិតខ្សោយខ្លាំង។

## ៤.២.៣ កត្តាប្រឈមរបស់របស់គណៈគ្រប់គ្រង

### តារាងទី១៧៖ កត្តាប្រឈមរបស់គណៈគ្រប់គ្រង




តាមរយៈលទ្ធផលវិភាគនៃតារាងខាងលើ សូចនាករទី១ (ភាពលំបាកនៃការប្រើប្រាស់ឧបករណ៍ ICT ដែលអ្នកកំពុងមាន) មានមធ្យម 3.07 សូចនាករទី២ (បញ្ហាក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ) មានមធ្យមភាគ 2.85 សូចនាករទី៣(ការទាញយកកម្មវិធីណាមួយ មកប្រើប្រាស់) មានមធ្យមភាគ 3.14 ដែលសូចនាករទាំង៣នេះគឺស្ថិតក្នុងកម្រិតមធ្យម មានន័យថាមិនសូវជាបញ្ហានោះទេសម្រាប់សូចនាករទាំងនេះ។

សូចនាករទី៥ (ការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត) មានមធ្យម 2.50 សូចនាករទី៦ (ភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT) មានមធ្យមភាគ 2.28 សូចនាករទី៨ (កង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT) មានមធ្យមភាគ 2.21 ដែលសូចនាករទាំង៣នេះ គឺស្ថិតក្នុងកម្រិតខ្សោយ។

ដោយឡែកសូចនាករដែលបង្ហាញពីភាពលំបាក់ខ្លាំង នោះគឺ **សូចនាករទី៤** (បញ្ហាInternet លើការប្រើប្រស់ICT) មានមធ្យមភាគ 1.42 **ទី៧** (កង្វះការយល់ដឹងផ្នែកICTបង្កជាផលលំបាកក្នុងការគ្រប់គ្រង) មានមធ្យមភាគ 1.23 **សូចនាករទី៩** (បញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់

ICT) មានមធ្យមភាគ 1.71 និង**ទី១០** (បញ្ហាអាកាសធាតុបង្កជាផលលំបាកចំពោះការប្រើប្រាស់ICT) មានមធ្យម 1.65 ដែលសូចនាករទាំង៤ស្ថិតក្នុងកម្រិតខ្សោយខ្លាំង។

### តារាងទី១៨៖ បញ្ហាប្រឈមរួមរបស់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ




សរុបមក យោងទៅតាមការបកស្រាយជាច្រើនអំពីបញ្ហាប្រឈមនៃការប្រើប្រាស់ ICT សម្រាប់ការគ្រប់គ្រង និងការបង្រៀន អ្នកស្រាវជ្រាវអាកំណត់ទៅលើបញ្ហា ៤ សំខាន់ៗដូចជា៖ កត្តាប្រព័ន្ធអ៊ិនធឺណេត កត្តាកង្វះការយល់ដឹងផ្នែកICT កត្តាអាកាសធាតុ និងកត្តាកង្វះគ្រូបង្គោលផ្នែកICT។ កត្តាកត្តាប្រព័ន្ធអ៊ិនធឺណេត ជាកត្តាមួយដែលមានភាគរយខ្ពស់ជាងគេហើយចាំបាច់បំផុត។ កត្តានេះជាដើមហេតុនៃការធ្វើឲ្យការអនុវត្តន៍លើការប្រើប្រាស់ ICT របស់គណៈគ្រប់គ្រង គ្រូ និងសិស្សជួបនូវបញ្ហា ដែលវាពាក់ព័ន្ធទៅនឹងល្បឿន អីនធឺណេតដែលរំខានដល់ការប្រើប្រាស់ប្រាចាំថ្ងៃ ជាពិសេសសាលាដែលនៅតំបន់ដាច់ស្រយាល។ បន្ទាប់ពីនេះ គឺកត្តាយល់ដឹងផ្នែកICT កង្វះការយល់ដឹងផ្នែកICTគឺពិតជាមានបញ្ហាផងដែរដល់ការគ្រប់គ្រង ការបង្រៀន និងការរៀនសូត្ររបស់សិស្ស។ កង្វះគ្រូបង្គោលផ្នែក ICT ដែលជាហេតុនាំឲ្យគ្រូ សិស្សមានការយល់ដឹងពីការប្រើប្រាស់ ICTនៅមានកម្រិត។ បើផ្តោតទៅលើ កត្តា៣ខាងលើ ពួកគេបាន

ប្រឈមនិង កត្តាមួយទៀតគឺកត្តាអាកាសធាតុ វាក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ ដែលបង្កឲ្យមានផលប៉ះពាល់ដល់ដំណើរការប្រើប្រាស់ ICT របស់គណៈគ្រប់គ្រង គ្រូ និងសិស្សជាពិសេសនៅរដូវវស្សា ។ ជាការសន្និដ្ឋាន បញ្ហាប្រឈមទាំង៤ ខាងលើជាមូលហេតុចម្បងនៃការប្រើប្រាស់ ICT នៅតាមសាលានៅក្នុងខេត្តរតនគិរី។

## ៤.៣. ការពិភាក្សា

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងការគ្រប់គ្រង និងការបង្រៀន នៅកម្រិតវិទ្យាល័យ នៃខេត្តរតនគិរី" អ្នកស្រាវជ្រាវបានកំណត់យកសំណួរ ចំនួន២ មកធ្វើការសិក្សាស្រាវជ្រាវ។

១. តើគណៈគ្រប់គ្រង និងគ្រូបង្រៀនបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងការគ្រប់គ្រង និងការបង្រៀនយ៉ាងដូចម្តេច?

២. តើអ្វីខ្លះជាបញ្ហាប្រឈមនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រងរបស់នាយក និងការបង្រៀនរបស់គ្រូ?

### សំណួរស្រាវជ្រាវទី១

នៅក្នុងការបកស្រាយនៃចំណុចខាងលើ ដែលស្តីអំពីស្ថានភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានបង្ហាញឲ្យអ្នកស្រាវជ្រាវបានស្វែងយល់ បានកាន់តែទូលំទូលាយអំពីស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមសាលារៀនកម្រិតវិទ្យាល័យដែលស្ថិតក្នុងខេត្តរតនគិរី។ ដូចទៅនឹងចំណុចជាច្រើនដែលអ្នកស្រាវជ្រាវបាន សរសេររៀបរាប់នៅផ្នែកខាងលើដែរ ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូនៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងគោលនយោបាយរបស់ ក្រសួងអប់រំ យុវជននិងកីឡា ដែលបានលើកឡើងក្នុងឆ្នាំ២០០៤។

នៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនោះ ក្រសួងបានចែក ផែនទីសំខាន់ៗដូចជា បង្កលក្ខណៈឲ្យគ្រូ និងសិស្ស គ្រប់រូបទាំងអស់ ជាពិសេសក្នុងមធ្យមសិក្សា ចេះប្រើប្រាស់ និង កាត់បន្ថយគម្លាតពីការប្រើប្រាស់ ICT ក្នុងតួនាទីគ្រប់គ្រង និងបង្រៀនរៀនតាមមុខវិជ្ជាផ្សេងៗ និងការប្រាស្រ័យទាក់ទងតាមសារអេឡិចត្រូនិច ប្រើប្រាស់ ICT ក្នុងការស្វ័យសិក្សា និងសិក្សាពីចម្ងាយ រួមទាំងការធ្វើតេស្តផ្សេងៗ។ ទន្ទឹមនឹងនេះ បើប្រើប្រៀបធៀបទៅនឹងគោលនយោបាយនិង យុទ្ធសាស្ត្រ ដែលបានចេញក្នុងឆ្នាំ ២០១៨ របស់ក្រសួងអប់រំ និងយោងតាមផលនៃការស្រាវជ្រាវខាងលើនេះ ការប្រើប្រាស់ ICT ក៏នៅមានគម្លាតកាន់តែទាបមួយកម្រិតផងដែរ។ ក្រសួងបានចេញគោលការណ៍នយោបាយជាច្រើនដូចជាធានាឲ្យសិស្សកម្ពុជាគ្រប់រូបដែលបញ្ចប់ការអប់រំក្នុងប្រព័ន្ធអាចប្រើប្រាស់ចំណេះដឹង និងបំណិន ICT បង្កើនប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀននិងរៀនដោយប្រើប្រាស់ឧបករណ៍ ICT និងធនធានអេឡិចត្រូនិច ប្រើប្រាស់ការសិក្សាតាមប្រព័ន្ធ E-Learning និង ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដែលផ្តោតលើគ្រូបង្រៀន។ លើសពីនេះទៅទៀត ក្នុងគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់គោលដៅលើ ICT ដើម្បីឲ្យក្លាយជាឧបករណ៍ សម្រាប់បង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្រៀន ក៏ដូចជាចែករំលែកចំណេះដឹងក្នុងវិស័យអប់រំ ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សទី២១។

សរុបមក យោងតាមការស្រាវជ្រាវ និងលទ្ធផលនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលបានដាក់បង្ហាញ និងគោលនយោបាយ និងយុទ្ធសាស្ត្រ របស់ក្រសួអប់រំ យុវជន និងកីឡា គឺនៅមិនទាន់ឆ្លើយតបគ្នាទៅវិញទៅមកនៅឡើយទេ។ នៅក្នុងនោះ ទាំង គណៈគ្រប់គ្រង គ្រូ និង សាលារៀនត្រូវ ពង្រឹងបន្ថែមទៀតទាំង ចំណេះដឹង សម្ភារ និងប្រភពធនធាន ICT ជាច្រើនទៀតដើម្បីឲ្យការគ្រប់គ្រង និងការបង្រៀន កាន់តែមានប្រសិទ្ធិភាពដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង។

**សំណួរស្រាវជ្រាវទី២**

នៅក្នុងសំណួរស្រាវជ្រាវទី២ អ្នកស្រាវជ្រាវបាន សិក្សាទៅលើបញ្ហាប្រឈមដែលកើតមានឡើងលើការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគនាគមន៍ក្នុងការបង្រៀន និងរៀន នៅតាមវិទ្យាល័យក្នុងខេត្ត

រតនគិរី។ ក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវបានរកឃើញនូវបញ្ហាប្រឈមជាច្រើន ដែលកើតឡើងលើគ្រូសិស្ស និងងសាលារៀន ចំពោះការប្រើប្រាស់ ICT។ អ្នកស្រាវជ្រាវបានសរុបរួមទៅលើ ៤ ចំណុចសំខាន់ៗ ដូចដែលបានសរសេររៀបរាប់នៅក្នុង បញ្ហាប្រឈមក្នុងការប្រើប្រាស់ ICT នៅចំណុចខាងលើ។ ចំណុចទាំង ៤ រួមមាន កត្តាប្រព័ន្ធអ៊ិនធឺណេត កត្តាកង្វះការយល់ដឹងផ្នែកICT កត្តាអាកាសធាតុ និងកត្តាកង្វះគ្រូបង្គោលផ្នែកICT ។ បើប្រៀបធៀបទៅនឹងរបាយការណ៍របស់ ផែនការមេរបស់ ICT សម្រាប់ការអប់រំក្នុងឆ្នាំ ២០០៩-២០១៣ នៃក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា គ្រូដែលចេញចាប់ពីឆ្នាំសិក្សា ២០០៩ - ២០១០ ត្រូវបានបណ្ដុះបណ្ដាល ផ្នែក ICT ដើម្បីឲ្យពួកគាត់បានយកទៅប្រើប្រាស់នៅក្នុងសាលារៀន របស់ពួកគាត់មានប្រហែល ៤០ភាគរយ។ នៅក្នុងផែនការមួយនេះក៏បានលើកឡើងពីការបណ្ដុះបណ្ដាលគ្រូ និងសិស្សនៅតាមសាលារៀន និងនៅក្នុង មជ្ឈមណ្ឌលគរុកោសល្យអំពី ICT និងសិស្សចាប់ពីថ្នាក់ទី ១០ ឡើងទៅផងដែរ នៅក្នុងឆ្នាំសិក្សា ២០០៩-២០១០ មក។ ប៉ុន្តែបើតាមទិន្នន័យដែលបានទទួលពីការស្រាវជ្រាវ បានបង្ហាញថា កត្តាកង្វះការយល់ដឹងផ្នែកICT ជាមូលហេតុដែលនាំឲ្យគ្រូ និងសិស្សនៅតាមសាលាភាគច្រើននៅមិនមានប្រសិទ្ធិភាពក្នុងការយល់ដឹងពីការប្រើប្រាស់ដែលស្របតាមផែនការរបស់ក្រសួងនៅឡើយ ជាពិសេសវាកបង្ករផលលំបាកដល់ការគ្រប់គ្រងរបស់គណៈគ្រប់គ្រងផងដែរ។ កត្តាប្រឈមលើអាកាសធាតុនៅតែជាកត្តាប្រឈមដ៏ដែល ដូចបានលើកឡើងនៅក្នុងការរំឮកទ្រឹស្តីត្រង់ចំណុច ករប្រើប្រាស់ ICT នៅក្នុងប្រទេសកម្ពុជា ជាណិសេស សម្រាប់សាលារៀនសារធារណៈ ដែលវាអាចមានផលវិខានដល់ដំណើរការរៀន និងបង្រៀន របស់គ្រូ និងសិស្សផងដែរ។ ចំណែកឯប្រព័ន្ធអ៊ិនធឺណេតក៏ជាកត្តាប្រឈមមួយ ខ្លាំងបំផុតដែរ ដូចបានលើកឡើងក្នុងចំណុចដូចគ្នាដែរនៅជំពូករំឮកទ្រឹស្តីថា៥០ភាគរយ នៃប្រជាជនជាង ១៦លាននាក់ គឺស្មើនឹងជាង ៨លាននាក់ ដែលមានមូលដ្ឋានគ្រឹះផ្នែក ICT ហើយអាចមានការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេត។ ដោយឡែកកត្តាខ្វះគ្រូបង្គោលលើមុខវិជ្ជាICT ក៏នៅតែជាបញ្ហាបម្បងមួយផងដែរដែលពិតជាមានផលលំបាក់ដល់ដំណើរការ គ្រប់គ្រង បង្រៀន និងរៀន ដោយហេតុថាបើមិនមានគ្រូបង្គោលផ្នែកបច្ចេកទេសក្នុងការបង្ហាត់បង្ហាញទេនោះសិស្សច្បាស់ជាមិនទទួលបាននូវចំណេះច្បាស់លាស់នោះទេ ដែលជាហេតុបង្ករឲ្យមានផលវិខានផ្សេងៗដល់ការសិក្សា។

សរុបមក កត្តាប្រឈមបានកើតឡើងជាច្រើន ដែលអ្នកស្រាវជ្រាវបានរកឃើញនៅក្នុងការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។ នៅក្នុងនោះអ្នកស្រាវជ្រាវបានបញ្ចូលជា ៤ ចំណុច សំខាន់ៗ គឺ៖ **កត្តាប្រព័ន្ធអ៊ិនធឺណេត កត្តាកង្វះការយល់ដឹងផ្នែកICT កត្តាអាកាសធាតុ និងកត្តាកង្វះគ្រូបង្គោលផ្នែកICT** ។ កត្តាប្រឈមទាំងនេះត្រូវបានរាំងស្ទះដល់ដំណើរការនៃ ការគ្រប់គ្រង ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស ក៏ដូចជាធ្វើឲ្យគោលនយោបាយ និងយុទ្ធសាស្ត្រស្តីអំពីការប្រើប្រាស់ICT

ក្នុងប្រព័ន្ធអប់រំ មិនមានភាពឆ្ពោះទៅមុខដោយរលូន ដែលជះឥទ្ធិពលយ៉ាងច្រើនដល់ការអភិវឌ្ឍវិស័យអប់រំ និងប្រទេសជាតិនាសម័យឌីជីថលនោះ។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងអង្កេតនៅតាមសាលារៀន លើនប្រធានបទ "ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្ត រតនគិរី" អ្នកសិក្សាស្រាវជ្រាចអាចធ្វើការសន្និដ្ឋានជារួមបានថា ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមសាលាកម្រិត មធ្យមសិក្សា ទុតិយភូមិ នៅមិនទាន់មានការប្រើប្រាស់ក្នុងកម្រិតមួយដែលអាច មានការប្រគួតប្រជែងនៅក្នុង ការគ្រប់គ្រង ការបង្រៀន និង ការសិក្សានាសតវត្សទី២១នេះទេ។ ការប្រើប្រាស់នេះនៅមានក្រិតនៅឡើយ ។ ទាំងគណៈគ្រប់គ្រង ទាំងគ្រូ សិស្ស និងសាលា នៅមានកត្តាប្រឈមច្រើនទាំងចំណេះដឹង គ្រូបង្គោល ប្រព័ន្ធប្រើប្រាស់អ៊ិនធឺណេត និងអាកាសធាតុ។

យោងទៅលើលទ្ធផលនៃការស្រាវជ្រាវបានឃើញថា គ្រូនិងសិស្សគឺស្ថិតនៅក្នុងភាគរយខ្សោយទៅលើបញ្ហា **ចំណេះដឹងនៃការប្រើប្រាស់ ICT** ដែលវាជះឥទ្ធិពលខ្លាំងដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់នាយក។ ចំណេះដឹងគឺជាចំណុចដ៏សំខាន់ បំផុតមួយនៃការប្រើប្រាស់។ វាអាចនាំអោយសិស្ស និងគ្រូអាចសិក្សាស្រាវជ្រាវ និងនាំយកនូវអត្ថប្រយោជន៍ជាច្រើនពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការជួយជ្រោមជ្រែងដល់ការសិក្សារបស់ពួកគេ មិនថាការបង្រៀន ឬការសិក្សានោះទេ។ បើទោះបីជាសិស្សភាគច្រើនគាត់បានប្រើប្រាស់ ទូរស័ព្ទដៃក្នុងការសិក្សា ICT ប៉ុន្តែក៏មិនអាចគាំទ្រទៅ លើការប្រើប្រាស់កម្មវិធី និងការស្រាវជ្រាវមួយចំនួននៃការសិក្សាបានទេ ។ អាកាសធាតុក៏ជាបញ្ហាចម្បងមួយដែលជាការរាំងស្ទះដល់ការ បង្រៀន និងរៀនរបស់គ្រូនិងសិស្ស ដែលជាហេតុនាំឲ្យការផ្តល់ និងទទួលចំណេះដឹងមិនមានប្រសិទ្ធភាពគ្រប់គ្រាន់ស្របតាមកម្មវិធីសិក្សារបស់ក្រសួង។ យោងតាមករណីនេះ គ្រូនិងសិស្សពិតជាលំបាក និងអាចឈានដល់ភាព ប្រសើរនៃការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍បានទេ។

នៅក្នុងការសិក្សា នេះដែរក៏មានចំណុច មួយផ្សេងទៀតដែលដើរតួយ៉ាងសំខាន់ផងដែរគឺ **ប្រព័ន្ធអ៊ិនធឺណេត**។ វាពិតជា ពិបាកនៅពេលអ្នកមានចំណេះដឹង មានឧបករណ៍ ហើយគ្មានប្រព័ន្ធអ៊ិនធឺណេតក្នុងការស្រាវជ្រាវ ឬ ប្រើប្រាស់កម្មវិធីណាមួយនាពេលបច្ចុប្បន្ននេះ។ គ្រូនិងសិស្សត្រូវការ ការស្រាវជ្រាវដែលឯកសារជាច្រើននៅក្នុង Google និង Youtube ហើយពួកគេត្រូវការទំនាក់ទំនង សិស្សតាមអនឡាញដែលប្រើកម្មវិធីដូចជា Email Telegram Zoom Google Meet និង Google classroom ជាដើមផងដែរ។

អ្វីដែលចោទជាបញ្ហាសំខាន់មួយទៀតនោះគឺ កង្វះគ្រូបង្គោលផ្នែកICT ដែលនេះក៏ជាបញ្ហាចម្បងមួយផងដែរ ដែលពាក់ព័ន្ធដល់សមត្ថភាពនៃការប្រើប្រាស់ICT របស់សិស្ស។ កង្វះគ្រូបង្គោលផ្នែកICT ពិតជាជះឥទ្ធិពលខ្លាំងដល់ការអភិវឌ្ឍចំណេះដឹងរបស់សិស្ស ធ្វើអោយសិស្សមិនមានការយល់ដឹងត្រឹមត្រូវច្បាស់លាស់ នាំឲ្យមានការរំខានដល់ការអភិវឌ្ឍវិស័យអប់រំ និងមិនអាចឈានដល់ភាព ប្រសើរនៃការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងមិនអាចឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំបានល្អនោះទេ។

សរុបមកអ្នកសិក្សាស្រាវជ្រាវបានរកឃើញថា ស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ ក្នុងការបង្រៀននិងរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្នុងកម្រិតក្រោមមធ្យមនៅឡើង និងពិតជាតម្រូវឲ្យមានការជួយជ្រោមជ្រែងឲ្យកាន់តែខ្លាំងពីអ្នកពាក់ព័ន្ធលើករណីនេះ។ លើសពីនោះ ICT ក៏មានបញ្ហាប្រឈមជាច្រើនដែលគណៈគ្រប់គ្រង គ្រូនិងសិស្សបានជួបប្រទះ។ ការជ្រោមជ្រែងពីដៃគូរពាក់ព័ន្ធ និងក្រសួង អប់រំ យុវជននិងកីឡា ទៅលើការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់គណៈគ្រប់គ្រង គ្រូ និងសិស្ស ពិតជាចំណុចមួយដែលមិនអាចខ្វះបាន នៅក្នុងរដ្ឋបាលគ្រប់គ្រង ការបង្រៀនក្នុងសតវត្សទី២១ នេះដើម្បីឈានដល់ការប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់ និងពិភពទាំងមូល ។

## ៥.២. សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ យើងបានរកឃើញថាស្ថានភាពនៃការប្រើប្រាស់ នេះនៅមានកម្រិត និងមានបញ្ហាប្រឈមធំៗ ក្នុងការដំណើរការគ្រប់គ្រង និងការបង្រៀន តាមថ្នាក់មធ្យមសិក្សា ទាំងកត្តាប្រព័ន្ធអ៊ិនធឺណេត កត្តាកង្វះការយល់ដឹងផ្នែកICT កត្តាអាកាសធាតុ និងកត្តាកង្វះគ្រូបង្គោលផ្នែកICT។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវគំនិតមួយចំនួន រួមចំណែក ដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញ និងដើម្បីពង្រឹងគោលការណ៍នេះ ឲ្យកាន់តែមានប្រសិទ្ធភាពប្រសើរឡើង។

### ៥.២.១. ក្រសួងអប់រំ យុវជន និងកីឡា

- គួររៀបចំនិងពង្រឹងកម្មវិធីសិក្សាទៅលើបច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ឲ្យកាន់តែទូលំទូលាយនៅក្នុង ការសិក្សារបស់សិស្សដោយ បញ្ចូលកម្មវិធី ICT ជាកម្មវិធីសំខាន់មួយនៃ មុខវិជ្ជាសិក្សាគោលចាប់ពីកម្រិតអនុវិទ្យាល័យ រហូតដល់កម្រិតវិទ្យាល័យ។
- គួរមានការជ្រើសរើសគ្រូដែលមានឯកទេស ICT ឲ្យមាននូវចំនួនសមាមាត្រទៅនឹងចំនួនវិទ្យាល័យ សាលាសារធារណៈទូទាំងប្រទេស ក្នុងន័យបង្កើនប្រសិទ្ធភាពការបង្ហាត់បង្រៀន ដែលអាចផ្តល់ចំណេះដឹងច្បាស់លាស់ដល់សិស្ស។

### ៥.២.២.មន្ទីរអប់រំ យុវជន និងកីឡា

- គួររៀបចំផែនការបណ្តុះបណ្តាលគ្រូបង្រៀនអំពីបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍តាមវិទ្យាល័យនានា។
- គួរតាមដាននិងចុះអធិការកិច្ចជាប្រចាំ នូវដំណើរការនៃការអនុវត្តកម្មវិធីសិក្សានៃទៅលើបច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដើម្បីជួយកែលម្អបន្ថែម ទៅលើចំណុចខ្វះខាត់ផ្សេងៗ។
- គួរគៀងគរមូនិធិពីអង្គការដៃគូនានាក្នុងការផ្តល់នូវសម្ភារបរិក្ខាផ្នែកICTដល់សាលាដែលមានការខ្វះខាតឧបការណ៍បច្ចេកវិទ្យា ជាពិសេសសាលានៅតំបន់ដាច់ស្រយាល ដើម្បីជួយឲ្យសិស្ស និងគ្រូមានឧបករណ៍ប្រើប្រាស់សមរម្យតាមភាពជាក់ស្តែង។

### ៥.២.៣. នាយកសាលា និងប្រធានក្រុមបច្ចេកទេស

- គួរពង្រឹងដោយមានការចង់ក្រងក្រុមបច្ចេកទេស ផ្នែក ICT នៅក្នុងសាលា ដើម្បីរួមសហការគ្នាក្នុងការកែសម្រួលការប្រើប្រាស់ ICT ។
- គួរលើទឹកចិត្តអោយគ្រូ សិស្ស មានការចូលរួមសិក្ខាសាលាផ្សេងៗអំពីបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ដោយជួយជាថវិកា ឬការឧបថមត្ថម្ភផ្សេងដល់សិក្សាកាម។
- គួរជំរុញលើកទឹកចិត្តគ្រូ និងសិស្សឲ្យប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសាគមនាគមន៍ក្នុងការបង្រៀន និងសិក្សាឲ្យបានទូលំទូលាយស្របតាមគោលនយោបាយសាលា។
- គួរស្នើសុំឲ្យមានប្រព័ន្ធអ៊ិនធឺណេតក្នុងសាលា ដោយមានការកំណត់វិន័យច្បាស់លាស់។

### ៥.២.៤. គ្រូបង្រៀន

- គួរបន្តពង្រឹងសមត្ថភាពរបស់ខ្លួន ផ្នែក ICT និងផ្នែកគរុកោសល្យឲ្យមានភាពទូលំទូលាយ និងចែករំលែកដល់មិត្តរួមអង្គភាព។
- គួរព្យាយាមចូលរួមសិក្ខាសាលា និងប្រើប្រាស់កម្មវិធី ICT ឲ្យបានច្រើនតាមដែលអាចធ្វើបាន និងណែនាំដល់សិស្សបន្ត។

### ៥.២.៥. សិស្សានុសិស្ស

- គួរពង្រឹងការសិក្សាពីគ្រូ និងស្វ័យសិក្សាតាមរយៈបណ្តាញសង្គមផ្សេងៗ។
- គួរប្រើប្រាស់ឧបករណ៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឲ្យបានត្រឹមត្រូវក្នុងការសិក្សា ដោយមិនគួរចំណាយពេលក្នុងភាពគ្មានប្រយោជន៍ ។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និកីឡា (២០១៨) សៀវភៅគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៤) សៀវភៅគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងវិស័យអប់រំ។

Cambodia ICT Masterplan (2020): Educational Program Development in Cambodia.

World Bank Education and COVID-19: (April, 30,2020).

UNESSCO Asia and Pacific Regional Bureau for Education (2004) in the case study of six Asian countries, found that the use of ICT tools.

Byrom, E., & Bingham, M. (2001). Factors influencing the effective use of technology for teaching and learning: Lessons learnt from the SEIR*TEC intensive site schools (2nd Ed.). Greensboro, NC: University of North Carolina.

Schiller, J. (2003). The elementary school principal as a change facilitator in ICT integration.

Wilmore, D. & Betz, M. (2000). Information technology and schools: The principal's role. Education-al Technology & Society, 3(4). Retrieved May 29, 2011

Kennewell,S. & Beauchamp, G. (2007). The features of interactive whiteboards and their influence on learning, Media and Technology, 32(3), 227-241

http://world-breaking-news.blogspot.com/2011/03/ict.html, Tuesday, March 29, 2011

Adi Suryani.2010. ICT IN EDUCATION: ITS BENEFITS, DIFFICULTIES, AND ORGANIZATIONAL DEVELOPMENT ISSUES

Chapman, D., and Mählck, L. (Eds). 2004. *Adapting technology for school improvement: a global perspective.* Paris: International Institute for Educational Planning.

Deuze, M. 2006. 'Participation Remediation Bricolage - Considering Principal Components of a Digital Culture.' *The Information Society*. *22*.

Dunleavy, M., Dextert, S. and Heinecke, W.F. 2007. ‘What added value does a 1:1 student to laptop ratio bring to technology-supported teaching and learning?’ *Journal of Computer Assisted Learning*. *23*.

Enyedy, N. 2014. *Personalized Instruction: New Interest, Old Rhetoric, Limited Results, and the Need for a New Direction for Computer-Mediated Learning*. Boulder, CO: National Education Policy Center.

Smeets, E. 2005. ‘Does ICT contribute to powerful learning environments in primary education?’ *Computers and Education. 44*.

Voogt, J., Knezek, G., Cox, M., Knezek, D. and ten Brummelhuis, A. 2013. ‘Under which conditions does ICT have a positive effect on teaching and learning? A call to action.’ *Journal of Computer Assisted Learning. 29*(1).

https://learningportal.iiep.unesco.org/en/issue-briefs/improve-learning/curriculum-and-materials/curriculum-and-expected-learning-outcomes

Altun, M. (2015). The integration of technology into foreign language teaching.

InternationalJournal on New Trends in Edıcation and Their Implications. 6(1). 22-27.

Houcine, S. (2011). The effects of ICT on learning/teaching in a foreign language Retrieved from http://www.pixel- online.net/ICT4LL2011/common/download/Paper_pdf/IBL69-437-FP-HoucineICT4LL2011.pdf [5]

# ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្រាវជ្រាវ

## កម្រងសំណួរ
## សម្រាប់គណៈគ្រប់គ្រងសាលា

ខ្ញុំបាទឈ្មោះ**លាស់ សាឡុន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ «**ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី**»។

នៅក្នុងការស្រាវជ្រាវនេះខ្ញុំបាទមានវត្ថុបំណងសិក្សាស្វែងរកឲ្យឃើញស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀន និងការគ្រប់គ្រងនៅកម្រិតវិទ្យាល័យ ក៏ដូចជាកត្តាប្រឈមនានាផងដែរ ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។

រាល់ទិន្នន័យដែលប្រមូលបាន គឺយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ យកមកសិក្សាវិភាគដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើ។ ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ ដោយមិនត្រូវបានប្រើក្នុងគោលបំណងផ្សេងទៀតឡើយ។ ចម្លើយរបស់លោក-លោកស្រីមិនមានខុសនោះឡើយគ្រាន់តែលោក-លោកស្រីមេត្តាឆ្លើយឲ្យបានច្បាស់លាស់តាមតែអាចធ្វើទៅបាន។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-លោកស្រី សម្រាប់ការចូលរួមផ្តល់ព័ត៌មាន។

## ផ្នែកទីI៖ ព័ត៌មានផ្ទាល់ខ្លួន

**សូមគូសសញ្ញា ✓ សម្រាប់ចម្លើយរបស់អ្នក( សំណួរខ្លះអ្នកអាចសរសេរជាចម្លើយបាន )**

១.តើលោក - លោកស្រីស្ថិតក្នុងតួនាទីអ្វីដែរ?

ក.នាយក ☐ ខ.នាយិកា ☐ គ.នាយករង ☐ ឃ.នាយិការង ☐

២. អាយុ ក. ២៥-៣០ ឆ្នាំ ☐ ខ. ៣១-៣៥ឆ្នាំ ☐ គ. ៣៦-៤០ឆ្នាំ ☐ ឃ. លើសពី ៤០ឆ្នាំ ☐

៣. តើលោក លោកស្រីកំពុងគ្រប់គ្រងនៅសាលាមួយណា?

| លរ | ឈ្មោះវិទ្យាល័យ | សូមគូសសញ្ញា ✓ |
|---|---|---|
| ១ | វិទ្យាល័យ សម្តេចឪ សម្តេចម៉ែ | |
| ២ | វិទ្យាល័យ អន្តេវាសិកដ្ឋានក្រុងបានលុង | |
| ៣ | វិទ្យាល័យ ប៊ូថងអូរជុំ | |
| ៤ | វិទ្យាល័យ បរកែវ | |
| ៥ | វិទ្យាល័យ សោមធំ | |
| ៦ | វិទ្យាល័យ លំផាត់ | |

| | | |
|---|---|---|
| ៧ | វិទ្យាល័យ អណ្ដូងមាស | |
| ៨ | វិទ្យាល័យ វីរៈជ័យ | |
| ៩ | វិទ្យាល័យ ត្រពាំងក្រហម | |
| ១០ | វិទ្យាល័យ ហ៊ុនសែនភូមិថ្មី | |

**៤**. សូមប្រាប់ពីស្ថានភាពទីតាំងសាលារបស់អ្នក?

ក. ទីក្រុង □ ខ. ទីប្រជុំជន □ គ. តំបន់ដាច់ស្រយាល □ ឃ. ផ្សេងៗ សូមបញ្ជាក់......................)

**៥**. តើលោក - លោកស្រីបានបម្រើការក្នុងវិស័យអប់រំប៉ុន្មានឆ្នាំមកហើយ ?

ក.៥-១៥ □ ខ.១៦-២៥ □ គ.២៦-៣៥ □ ឃ. ផ្សេងៗ ( សូមបញ្ជាក់.........................)

**៦**.តើលោក - លោកស្រីស្ថិតនៅប្រភេទក្រខណ្ឌមួយណា ?

ក.គ្រូកម្រិតឧត្តម □ ខ.គ្រូកម្រិតមូលដ្ឋាន □ គ.ផ្សេង...................

**៧**.កម្រិតសញ្ញាបត្រ

ក.បណ្ឌិត □ ខ.អនុបណ្ឌិត□ គ.បិញ្ញាបត្រ □ ឃ.បរិញ្ញាបត្ររង □ ង.បាកឌុប □

**៨**.តើលោក - លោកស្រី បានគ្រប់គ្រងនៅទីនេះប៉ុន្មានឆ្នាំហើយគិតមកដល់ពេលបច្ចុប្បន្ន ?

ក.១-៥ □ ខ.៦-១០ □ គ.១១-១៥ □ ឃ.១៦-២០ □ ង.លើសពី២០ឆ្នាំ□

## ផ្នែកទីII៖ ស្ថានភាពនៃការប្រើប្រាស់ ICT សម្រាប់ការគ្រប់គ្រង និងការបង្រៀន

**ការណែនាំ៖** សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងពីស្ថានភាពនៃការប្រើប្រាស់ICTសម្រាប់ការគ្រប់គ្រង និងការបង្រៀន ។ សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ រួចគូសសញ្ញា (✓) ទៅតាម កម្រិតនីមួយៗ៖

## ក. កម្រិតនៃការយល់ដឹងរបស់អ្នកក្នុងការប្រើប្រាស់ ICT។ សូមគូសសញ្ញា( ✓ )

| ល.រ | កម្រិតនៃការប្រើប្រាស់ឧបករណ៍ | ប្រើមិនបាន | ប្រើបានតិចតួច | ប្រើបានល្មម | ប្រើបានខ្លាំង | ស្ទាត់ជំនាញ |
|---|---|---|---|---|---|---|
| ១ | ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | | | | | |
| ២ | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | | | | | |
| ៣ | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save.) | | | | | |
| ៤ | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point) | | | | | |
| ៥ | ការធ្វើបទបង្ហាញដោយប្រើ Projector | | | | | |
| ៦ | ការស្វែងរកឯកសារពាក់ពន្ធ័នានាតាមអ៊ិនធឺណេត | | | | | |
| ៧ | ការកែរូបភាព ឬវីដេអូផ្សេងៗ | | | | | |
| ៨ | ទាញយកឯកសារពីអ៊ិនធឺណេត | | | | | |
| ៩ | ប្រើប្រាស់សារអេឡិចត្រូនិច Email | | | | | |
| ១០ | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | | | | | |
| ១១ | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | | | | | |
| ១២ | ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) | | | | | |
| ១៣ | ការប្រជុំ ឬបង្រៀនតាមវិដេអូ Zoom Meeting | | | | | |
| ១៤ | ការប្រជុំ ឬបង្រៀនតាមវិដេអូ Google Meet | | | | | |
| ១៥ | ការចែករំលែកឯកសារនានាដល់បុគ្គលិកពីអ៊ិនធឺណេត | | | | | |

## ខ. ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង និងការបង្រៀន។ សូមគូសសញ្ញា( ✓ )

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT | មិនមាន | មានតិចតួច | មានមធ្យម | មានច្រើន | មានគ្រប់គ្រាន់ |
|---|---|---|---|---|---|---|
| ១ | តើនៅសាលារបស់អ្នក មានបន្ទប់ធនធានសម្រាប់សិក្សាកម្មវិធី ICT ដែរឬទេ? | | | | | |
| ២ | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍សម្រាប់គ្រូ និងសិស្សដែរឬទេ? | | | | | |
| ៣ | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ។ | | | | | |
| ៤ | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ? | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | តើនៅសាលារបស់អ្នកមានការជួយជ្រោមជ្រែងពីអង្គការដៃគូណាទេសម្រាប់ការបង្រៀនពី ICT ? | | | | | |
| ៦ | តើសាលារបស់អ្នកមានចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ ? | | | | | |
| ៧ | តើអង្គភាពរបស់អ្នកបានផ្តល់សម្ភារៈ ICT ដល់ឲ្យគ្រូដែរឬទេ ? | | | | | |
| ៨ | តើអង្គភាពរបស់អ្នកមានគ្រូបច្ចេកទេសផ្នែកបច្ចេកវិទ្យាដែរឬទេ ? | | | | | |
| ៩ | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ICTទៅដល់សិស្សដែឬទេ ? | | | | | |
| ១០ | តើសាលារបស់អ្នកមានគេហទំព័ផ្លូវកាសម្រាប់សាលាដែរឬទេ ? | | | | | |
| ១១ | តើសាលារបស់អ្នកមានFacebook pageផ្លូវកាសម្រាបសាលាដែរឬទេ ? | | | | | |
| ១២ | តើក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗនៅសាលារបស់អ្នកមាន Facebook page ប្រចាំមុខវិជ្ជាដែរឬទេ ? | | | | | |
| ១៣ | តើបុគ្គលិកនៅសាលារបស់អ្នកមានឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមាន៍ដែរឬទេ ? | | | | | |
| ១៤ | តើគ្រូបង្រៀនគាត់មានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន  ក្នុងការបង្រៀនសិស្សដែរឬទេ ? | | | | | |
| ១៥ | តើគ្រូបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀនឬស្វែងរកឯកសារដែរឬទេ ? | | | | | |
| ១៦ | តើបុគ្គលិករបស់អ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិកដែរឬទេ ? | | | | | |
| ១៧ | តើពួកគាត់បានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងសិស្សានុសិស្ស និងមាតាបិតាសិស្សដែរឬទេ ? | | | | | |
| ១៨ | តើសិស្ស មានបានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការសិក្សាដែរឬទេ ? | | | | | |
| ១៩ | តើសិស្សបានប្រើប្រាស់ ICT សម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬស្វែង<br>រកឯកសារឬទេ ? | | | | | |
| ២០ | តើអ្នកគិតថាការគ្រប់គ្រងដោយប្រើ កម្មវិធី (ICT) ជាការគ្រប់គ្រងដែលមានប្រសិទ្ធភាពដែរឬទេ ? | | | | | |

គ. ស្ថានភាពនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង។ សូមគូសសញ្ញា( ✓ )

| | ស្ថានភាពនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| ១ | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការងារតាមកម្មវិធីមួយណាដែរ ? | | | | | | |
| ២ | តើអ្នកធ្វើការទំនាក់ទំនងជាមួយបុគ្គលិកដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៣ | តើអ្នករៀបចំការប្រជុំនានាជាមួយបុគ្គលិករបស់អ្នកដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៤ | តើអ្នកផ្តល់ព័ត៌មានអំពីការប្រជុំនានាដល់បុគ្គលិក ដោយមធ្យោបាយណា ? | | | | | | |
| ៥ | តើអ្នកបញ្ជូនរបាយការផ្សេងៗទៅថ្នាក់មន្ទីរ ដោយមធ្យោបាយណា ? | | | | | | |
| ៦ | តើអ្នកចូលរួមប្រជុំ ជាមួយថ្នាក់ក្រសួង មន្ទីរដោយមធ្យោបាយណា ? | | | | | | |
| ៧ | តើអ្នកធ្វើការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សដោយប្រើប្រាស់មធ្យោបាយ ? | | | | | | |
| ៨ | តើអ្នកធ្វើការទំនាក់ទំនងជាមួយសិស្សដោយប្រើប្រាស់មធ្យោបាយមួយណា ? | | | | | | |
| ៩ | ប្រសិនបើមានការប្រឡងពីចម្ងាយ តើកម្មវិធីអ្វីដែលបុគ្គលិករបស់អ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ ? | | | | | | |
| ១០ | តើកម្មវិធីណាមួយដែលគ្រូបានប្រើក្នុងការបង្រៀនតាមអនឡាញនេះ ? | | | | | | |
| ១១ | តើអ្នកគ្រប់គ្រងវត្តមានបុគ្គលិករបស់អ្នកដោយមធ្យោបាយណា ? | | | | | | |
| ១២ | តើអ្នកប្រមូលវិញ្ញាសាប្រឡងប្រចាំខែ ឬឆមាសដោយមធ្យោបាយណា ? | | | | | | |
| ១៣ | តើអ្នកប្រមូលលទ្ធផលប្រចាំខែ ឬឆមាសដោយមធ្យោបាយណា ? | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៤ | តើអ្នកចូលរួមក្នុងវេទិកាពិភាក្សា ឬសិក្ខាសាលាផ្សេងៗតាមកម្មវិធីមួយណា? | | | | | | |
| ១៥ | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង? | | | | | | |

**ផ្នែកទីIII៖ បញ្ហាប្រឈមនៅលើការប្រើប្រាស់** ICT

១.សូមលោក - លោកស្រីមេត្តាជ្រើសរើសកម្រិតបញ្ហាប្រឈមជាក់ស្តែងដែលធ្លាប់បានជួបប្រទះអំពីការប្រើប្រាស់ ICTដូចខាងក្រោម។ សូមគូសសញ្ញា( ✓ )

| ល.រ | បញ្ហាប្រឈមជាក់ស្តែង | លំបាកខ្លាំង | លំបាក | ងាយស្រួល | ងាយស្រួលមធ្យម | ងាយស្រួលខ្លាំង |
|---|---|---|---|---|---|---|
| 1 | តើឧបករណ៍ ICTដែលអ្នកកំពុងប្រើប្រាស់មានភាពលំបាកសម្រាប់អ្នកដែរឬទេ? | | | | | |
| 2 | តើអ្នកមានការលំបាកទេ ក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន យកមកប្រើប្រាស់? | | | | | |
| 3 | តើអ្នកមានការលំបាកក្នុងការទាញយកកម្មវិធីណាមួយពីអីនធឺណេតមកប្រើប្រាស់ដែរឬទេ? | | | | | |
| 4 | តើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ? | | | | | |
| 5 | តើការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ? | | | | | |
| 6 | តើភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT? | | | | | |
| 7 | តើអ្នកលំបាកក្នុងការស្វែងរកឯកសារពាក់ពន្ធ័ការងារផ្សេងៗដែរឬទេ? | | | | | |
| 8 | តើបញ្ហាកង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT? | | | | | |
| 9 | តើបញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់ ICT? | | | | | |
| 10 | តើបញ្ហាអាកាសធាតុបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT? | | | | | |

**មតិយោបល់បន្ថែម៖**

១. ប្រសិនបើមានការប្រឈមក្នុងការប្រើប្រាស់ ICT ផ្សេងទៀត សម្រាប់ការគ្រប់គ្រង និងការបង្រៀន តើមានកត្តាអ្វីខ្លះ?

ចូរជ្រើសរើសកត្តាប្រឈមសំខាន់ៗបំផុតចំនួន៣ និងដាក់តាមលំដាប់អាទិភាព៖

ក. ..........................................................................................................................

ខ. ..........................................................................................................................

គ. ..........................................................................................................................

# សម្រាប់លោកគ្រូ អ្នកគ្រូ

ខ្ញុំបាទឈ្មោះ**លាស់ សាឡុន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ «**ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី**»។ នៅក្នុងការស្រាវជ្រាវនេះខ្ញុំបាទមានវត្ថុបំណងសិក្សាស្វែងរកឲ្យឃើញស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀន និងការគ្រប់គ្រងនៅកម្រិតវិទ្យាល័យ ក៏ដូចជាកត្តាប្រឈមនានាផងដែរដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ រាល់ទិន្នន័យដែលប្រមូលបានគឺយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ យកមកសិក្សាវិភាគដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើ។ ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ ដោយមិនត្រូវបានប្រើក្នុងគោលបំណងផ្សេងទៀតឡើយ។ ចម្លើយរបស់លោក-លោកស្រីមិនមានខុសនោះឡើយគ្រាន់តែលោក-លោកស្រីមេត្តាឆ្លើយឲ្យបានច្បាស់លាស់តាមតែអាចធ្វើទៅបាន។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-លោកស្រី សម្រាប់ការចូលរួមផ្តល់ព័ត៌មាន។

## ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន

**សូមគូសសញ្ញា ✓ សម្រាប់ចម្លើយរបស់អ្នក( សំណួរខ្លះអ្នកអាចសរសេរជាចម្លើយបាន )**

១. តើអ្នកកំពុងបង្រៀននៅវិទ្យាល័យមួយណានៃវិទ្យាល័យខាងក្រោម?

| លរ | ឈ្មោះវិទ្យាល័យ | សូមគូសសញ្ញា ✓ |
|---|---|---|
| ១ | វិទ្យាល័យ សម្តេចឪ សម្តេចម៉ែ | |
| ២ | វិទ្យាល័យ អន្តេវាសិកដ្ឋានក្រុងបានលុង | |
| ៣ | វិទ្យាល័យ ប៊ូថងអូរជុំ | |
| ៤ | វិទ្យាល័យ បរកែវ | |
| ៥ | វិទ្យាល័យ សោមធំ | |
| ៦ | វិទ្យាល័យ លំផាត់ | |
| ៧ | វិទ្យាល័យ អណ្តូងមាស | |
| ៨ | វិទ្យាល័យ វីរៈជ័យ | |
| ៩ | វិទ្យាល័យ ត្រពាំងក្រហម | |
| ១០ | វិទ្យាល័យ ហ៊ុនសែនភូមិថ្មី | |

២. សូមគូស ✓ ក្នុងប្រអប់ខាងក្រោមសម្រាប់ភេទរបស់អ្នក។

ក. ភេទប្រុស ☐ ខ. ភេទស្រី ☐

៣. តើលោក-លោកស្រី មានតួនាទីអ្វីដែរ?

ក. គ្រូបង្រៀន ☐ ខ. បុគ្គលិកការិយាល័យ ☐ គ. គ្រូផ្នែកICT ☐ ឃ. ផ្សេងៗ ( សូមបញ្ជាក់.............)

៤. តើលោក-លោកស្រីកំពុងបង្រៀនមុខវិជ្ជាអ្វីដែរនាពេលបច្ចុប្បន្ន?

……………………………………………………………………………………………..

៥. តើលោក-លោកស្រីកំពុងបង្រៀននៅថ្នាក់ទីប៉ុន្មាន?

ក. ថ្នាក់ទី១០ ☐ ខ. ថ្នាក់ទី១១ ☐ គ. ថ្នាក់ទី១២ ☐ ផ្សេងៗ( សូមបញ្ជាក់..............................)

៦. តើលោក-លោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

ក. ២០-៣០ ☐ ខ. ៣១-៤០ ☐ គ. ៤១-៥០ ☐ ឃ. ៥១-៦០ ☐

៧. តើលោក-លោកស្រី បង្រៀនបានប៉ុន្មានឆ្នាំហើយ?

ក. ១-៥ឆ្នាំ ☐ ខ. ៦-១០ឆ្នាំ ☐ គ. ១១-១៥ឆ្នាំ ☐ ឃ. ១៦ឆ្នាំឡើងទៅ ☐

៨. តើលោក-លោកស្រីស្ថិតនៅប្រភេទក្រខណ្ឌមួយណា?

ក.គ្រូកម្រិតឧត្តម ☐ ខ.គ្រូកម្រិតមូលដ្ឋាន ☐ គ.ផ្សេង...................

៩.កម្រិតសញ្ញាបត្រៈ

ក.បណ្ឌិត ☐ ខ.អនុបណ្ឌិត☐ គ.បរិញ្ញាបត្រ ☐ ឃ.បរិញ្ញាបត្ររង ☐ ង.បាកឌុប ☐

## ផ្នែកទី២៖ ស្ថានភាពនៃការប្រើប្រាស់ ICT សម្រាប់ការគ្រប់គ្រង និងការបង្រៀន

**ការណែនាំ៖** សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងពីស្ថានភាពនៃការប្រើប្រាស់ ICTសម្រាប់ការគ្រប់គ្រង និងការបង្រៀន។ សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ រួចគូសសញ្ញា (✓) ទៅតាម កម្រិតនៃការពេញប្រើប្រាស់របស់អ្នក៖

## ក. កម្រិតនៃការយល់ដឹងរបស់អ្នកក្នុងការប្រើប្រាស់ ICT។ សូមគូសសញ្ញា( ✓ )លើចម្លើយតែមួយគត់

| ល.រ | កម្រិតនៃការប្រើប្រាស់ឧបករណ៍ | ប្រើមិនបាន | ប្រើបានតិចតួច | ប្រើបានល្មម | ប្រើបានខ្លាំង | ស្ទាត់ជំនាញ |
|---|---|---|---|---|---|---|
| ១ | ការប្រើប្រាស់ក្ដារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | | | | | |
| ២ | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | | | | | |
| ៣ | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save. ) | | | | | |
| ៤ | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point ) | | | | | |
| ៥ | ការធ្វើបទបង្ហាញដោយប្រើ Projector | | | | | |
| ៦ | ការស្វែងរកឯកសារពាក់ពន្ធ័មេរៀនតាមអ៊ិនធឺណេត | | | | | |
| ៧ | ការកែរូបភាព ឬវីដេអូផ្សេងៗ សម្រាប់បង្រៀនសិស្ស | | | | | |
| ៨ | ទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការបង្រៀន | | | | | |
| ៩ | ប្រើប្រាស់សារអេឡិចត្រូនិច Email | | | | | |
| ១០ | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | | | | | |
| ១១ | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | | | | | |
| ១២ | ការប្រើប្រាស់កម្មវិធីរបស់Google ( Classroom, Forms….. ) | | | | | |
| ១៣ | ការប្រជុំ ឬបង្រៀនតាមវិដេអូ Zoom Meeting | | | | | |
| ១៤ | ការប្រជុំ ឬបង្រៀនតាមវិដេអូ Google Meet | | | | | |
| ១៥ | ការចែករំលែកឯកសារមេរៀនដល់សិស្សពីអ៊ិនធឺណេត | | | | | |

## ខ. ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង និងការបង្រៀន។ សូមគូសសញ្ញា( ✓ )

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT | មិនមាន | មានតិចតួច | មានមធ្យម | មានច្រើន | មានគ្រប់គ្រាន់ |
|---|---|---|---|---|---|---|
| ១ | តើនៅសាលារបស់អ្នក មានបន្ទប់ធនធានសម្រាប់សិក្សាកម្មវិធី ICT ដែរឬទេ ? | | | | | |
| ២ | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍សម្រាប់គ្រូ និងសិស្សដែរឬទេ ? | | | | | |
| ៣ | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ។ | | | | | |
| ៤ | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ ? | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | តើនៅសាលារបស់អ្នកមានការជួយជ្រោមជ្រែងពីអង្គការដៃគូណាទេសម្រាប់ការបង្រៀនពី ICT ? | | | | | |
| ៦ | តើសាលារបស់អ្នកមានចងក្រងក្រុមការងារតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ ? | | | | | |
| ៧ | តើអង្គភាពរបស់អ្នកបានផ្តល់សម្ភារៈ ICT ដល់ឲ្យគ្រូដែរឬទេ ? | | | | | |
| ៨ | តើអង្គភាពរបស់អ្នកមានជំនួយការបច្ចេកទេសផ្នែកបច្ចេកវិទ្យា ដែរឬទេ ? | | | | | |
| ៩ | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ICTទៅដល់សិស្សដែឬទេ ? | | | | | |
| ១០ | តើសាលារបស់លោក - លោកស្រីមាន គេហទំព័ផ្លូវកាសម្រាប់សាលាដែរឬទេ ? | | | | | |
| ១១ | តើសាលារបស់លោក លោកស្រីមានFacebook pageផ្លូវកាសម្រាប់សាលាដែរឬទេ ? | | | | | |
| ១២ | តើក្រុមបច្ចេកទេសនៃមុខវិជ្ជានីមួយៗនៅសាលារបស់អ្នកមាន Facebook page ប្រចាំមុខវិជ្ជាដែរឬទេ ? | | | | | |
| ១៣ | តើអ្នកមានឧបករណ៍បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមាន៍ដែរឬទេ ? | | | | | |
| ១៤ | តើអ្នកមានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន  ក្នុងការបង្រៀនសិស្សដែរឬទេ ? | | | | | |
| ១៥ | តើអ្នកបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀន ឬស្វែងរកឯកសារដែរឬទេ ? | | | | | |
| ១៦ | តើអ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងរវាងបុគ្គលិក និងបុគ្គលិកដែរឬទេ ? | | | | | |
| ១៧ | តើអ្នកបានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងសិស្សានុសិស្ស និងមាតាបិតាសិស្សដែរឬទេ ? | | | | | |
| ១៨ | តើសិស្ស មានបានប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការសិក្សាដែរឬទេ ? | | | | | |
| ១៩ | តើសិស្សបានប្រើប្រាស់ ICT សម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀនឬស្វែរកឯកសារឬទេ ? | | | | | |
| ២០ | តើអ្នកគិតថាការគ្រប់គ្រងដោយប្រើ កម្មវិធី (ICT) ជាការគ្រប់គ្រងដែលមានប្រសិទ្ធភាពដែរឬទេ ? | | | | | |

គ. ស្ថានភាពនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង។ សូមគូសសញ្ញា( ✓ )

| | ស្ថានភាពនៃការប្រើប្រាស់ICTក្នុងការគ្រប់គ្រង | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| ១ | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការងារតាមកម្មវិធីមួយណាដែរ ? | | | | | | |
| ២ | តើអ្នកធ្វើការទំនាក់ទំនងជាមួយគណៈគ្រប់គ្រងដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៣ | តើអ្នកចូលរួមការប្រជុំនានាជាមួយគណៈគ្រប់គ្រងរបស់អ្នកដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៤ | តើអ្នកទទួលព័ត៌មានអំពីការប្រជុំនានាដោយមធ្យោបាយណា ? | | | | | | |
| ៥ | តើនាយកបញ្ជូនរបាយការផ្សេងៗទៅថ្នាក់មន្ទីរ ដោយមធ្យោបាយណា ? | | | | | | |
| ៦ | តើអ្នកចូលរួមប្រជុំ ជាមួយថ្នាក់ក្រសួង មន្ទីរដោយមធ្យោបាយណា ? | | | | | | |
| ៧ | តើអ្នកធ្វើការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៨ | តើអ្នកធ្វើការទំនាក់ទំនងជាមួយសិស្សដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៩ | ប្រសិនបើប្រឡងពីចម្ងាយ តើកម្មវិធីអ្វីដែលអ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ ? | | | | | | |
| ១០ | តើកម្មវិធីណាមួយដែលអ្នកបានប្រើក្នុងការបង្រៀនតាមអនឡាញនេះ ? | | | | | | |
| ១១ | តើអ្នកចុះវត្តមានរបស់អ្នកដោយមធ្យោបាយណា ? | | | | | | |
| ១២ | តើអ្នកផ្ញើវិញ្ញាសាប្រឡងប្រចាំខែឬឆមាសជូនគណៈគ្រប់គ្រងដោយមធ្យោបាយណា ? | | | | | | |
| ១៣ | តើអ្នកបញ្ជូនលទ្ធផលប្រចាំខែ ឬឆមាសជូនគណៈគ្រប់គ្រងដោយមធ្យោបាយណា ? | | | | | | |
| ១៤ | តើអ្នកចូលរួមក្នុងវេទិកាពិភាក្សា ឬសិក្ខាសាលាផ្សេងៗតាមកម្មវិធីមួយណា ? | | | | | | |
| ១៥ | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង ? | | | | | | |

### ផ្នែកទី៣៖ បញ្ហាប្រឈមនៅលើការប្រើប្រាស់ ICT

១.សូមលោក - លោកស្រីមេត្តាជ្រើសរើសកម្រិតបញ្ហាប្រឈមជាក់ស្តែងដែលធ្លាប់បានជួបប្រទះអំពីការប្រើប្រាស់ ICTដូចខាងក្រោម។ សូមគូសសញ្ញា( ✓ )

| ល.រ | កម្រិតបញ្ហាប្រឈមជាក់ស្តែង | លំបាកខ្លាំង | លំបាក | ងាយស្រួល | ងាយស្រួលមធ្យម | ងាយស្រួលខ្លាំង |
|---|---|---|---|---|---|---|
| 1 | តើឧបករណ៍ ICTដែលអ្នកកំពុងប្រើប្រាស់មានភាពលំបាកសម្រាប់អ្នកដែរឬទេ? | | | | | |
| 2 | តើអ្នកមានការលំបាកទេ ក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន យកមកប្រើប្រាស់? | | | | | |
| 3 | តើអ្នកមានភាពលំបាកក្នុងការទាញយកកម្មវិធីណាមួយនៃបច្ចេកវិទ្យាព័ត៌មាវិទ្យានិងសារមគនាគមន៍យកមកប្រើប្រាស់ដែរឬទេ? | | | | | |
| 4 | តើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ? | | | | | |
| 5 | តើការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ? | | | | | |
| 6 | តើភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT? | | | | | |
| 7 | តើអ្នកលំបាកក្នុងការស្វែងរកឯកសារពាក់ពន្ធ័មេរៀននៃមុខវិជ្ជារបស់អ្នកដែទេ? | | | | | |
| 8 | តើបញ្ហាកង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT? | | | | | |
| 9 | តើបញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT? | | | | | |
| 10 | តើបញ្ហាអាកាសធាតុបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT? | | | | | |

**មតិយោបល់បន្ថែម៖**

១. ប្រសិនបើមានការប្រឈមក្នុងការប្រើប្រាស់ ICT ផ្សេងទៀត សម្រាប់ការបង្រៀន និងរៀន។ តើមានកត្តាអ្វីខ្លះ?

ចូរជ្រើសរើសកត្តាប្រឈមសំខាន់ៗបំផុតចំនួន៣ និងដាក់តាមលំដាប់អាទិភាព៖

ក. ..........................................................................................................................................

ខ. ..........................................................................................................................................

គ. ..........................................................................................................................................

# <u>សម្រាប់សិស្ស</u>

ខ្ញុំបាទឈ្មោះ **លាស់ សាឡុន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៅវិទ្យាស្ថានជាអប់រំ នឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ « **ស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តរតនគិរី** ដើម្បីបញ្ចប់ការសិក្សា។

ការស្រាវជ្រាវនេះ ខ្ញុំបាទមានវត្ថុបំណង សិក្សាស្វែងរកឲ្យឃើញ នូវស្ថានភាពនៃការប្រើប្រាស់បច្ចេកវិទ្យា ICTក្នុងការគ្រប់គ្រង និងការបង្រៀន នៅកម្រិតវិទ្យាល័យ ក៏ដូចជាកត្តាប្រឈមផ្សេងៗផងដែរ។ ចម្លើយរបស់ប្អូនមិនមាន
ខុសនោះឡើយ គ្រាន់តែប្អូនឆ្លើយឲ្យបានច្បាស់លាស់តាមតែអាចធ្វើទៅបាន។ រាល់ចម្លើយរបស់ប្អូន គឺប្រើសម្រាប់
ការស្រាវជ្រាវតែប៉ុណ្ណោះគឺមិនត្រូវបានប្រើក្នុងគោលបំណងផ្សេងឡើយ។ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់ប្អូន សូមផ្តល់ចម្លើយចំពោះសំណួរខាងក្រោម
ដោយយកចិត្តទុកដាក់។

## ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន

**សូមគូសសញ្ញា ✓ សម្រាប់ចម្លើយរបស់អ្នក( សំណួរខ្លះអ្នកអាចសរសេរជាចម្លើយបាន )**

១. តើប្អូនកំពុងសិក្សានៅវិទ្យាល័យមួយណាក្នុងចំណោមសាលាខាងក្រោម?

| លរ | ឈ្មោះវិទ្យាល័យ | សូមគូសសញ្ញា ✓ |
|---|---|---|
| ១ | វិទ្យាល័យ សម្តេចឪ សម្តេចម៉ែ | |
| ២ | វិទ្យាល័យ អន្តេវាសិកដ្ឋានក្រុងបានលុង | |
| ៣ | វិទ្យាល័យ ប៊ូថងអូរជុំ | |
| ៤ | វិទ្យាល័យ បរកែវ | |
| ៥ | វិទ្យាល័យ សោមធំ | |
| ៦ | វិទ្យាល័យ លំផាត់ | |
| ៧ | វិទ្យាល័យ អណ្តូងមាស | |
| ៨ | វិទ្យាល័យ វីរៈជ័យ | |
| ៩ | វិទ្យាល័យ ត្រពាំងក្រហម | |
| ១០ | វិទ្យាល័យ ហ៊ុនសែនភូមិថ្មី | |

២. សូមមេត្តាជួយប្រាប់ពីភេទរបស់អ្នក។

ក. ភេទប្រុស ☐ ខ. ភេទស្រី ☐

៣. តើអ្នករៀននៅថ្នាក់ទីប៉ុន្មាន?

ក. ១០ ☐ ខ. ១១ ☐ គ. ១២ ☐

៤. ប្រសិនបើអ្នកមិនយល់ទាស់ទេ សូមបញ្ជាក់ពីកម្រិតជីវភាពនៃគ្រួសាររបស់អ្នកក្នុងប្រអប់ខាងក្រោមៈ

ក. កម្រិតទាប ☐ ខ. កម្រិតមធ្យម ☐ គ. កម្រិតល្អបង្គួរ ☐ ឃ. កម្រិតខ្ពស់ ☐

## ផ្នែកទី២៖ ស្ថានភាពនៃការប្រើប្រាស់ ICT សម្រាប់ការបង្រៀន និងរៀន

**ការណែនាំ៖** សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងពីស្ថានភាពនៃការប្រើប្រាស់ ICT សម្រាប់ការបង្រៀន និងរៀន។ សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ រួចគូសសញ្ញា (✓) ទៅតាម កម្រិតនៃការប្រើប្រាស់របស់អ្នកៈ

ក. កម្រិតនៃការយល់ដឹងរបស់អ្នកក្នុងការប្រើប្រាស់ ICT។ (សូមគូសសញ្ញា ✓)

| ល.រ | កម្រិតនៃការប្រើប្រាស់ឧបករណ៍ | ប្រើមិនបាន | ប្រើបានតិចតួច | ប្រើបានល្អ | ប្រើបានខ្លាំង | ស្ទាត់ជំនាញ |
|---|---|---|---|---|---|---|
| ១ | ការប្រើប្រាស់ក្តារចុច ឧបករណ៍ចង្អុល ប៊ូតុង លើកុំព្យូទ័រ | | | | | |
| ២ | ការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត ឬថេប្លេត | | | | | |
| ៣ | ការគ្រប់គ្រងទិន្នន័យក្នុងកុំព្យូទ័រ ឬទូរស័ព្ទ( Delete, move, save.) | | | | | |
| ៤ | ប្រើប្រាស់កម្មវិធីរដ្ឋបាលផ្សេងៗ ( Word, Excel, power point) | | | | | |
| ៥ | ការធ្វើបទបង្ហាញដោយប្រើ Projector | | | | | |
| ៦ | ការស្វែងរកឯកសារពាក់ពន្ធ័មេរៀនតាមអ៊ិនធឺណេត | | | | | |
| ៧ | ការកែរូបភាព ឬវីដេអូផ្សេងៗ | | | | | |
| ៨ | ទាញយកឯកសារពីអ៊ិនធឺណេតដើម្បីជំនួយក្នុងការរៀន | | | | | |
| ៩ | ប្រើប្រាស់សារអេឡិចត្រូនិច Email | | | | | |
| ១០ | ប្រើប្រាស់សារអេឡិចត្រូនិច Messenger | | | | | |
| ១១ | ប្រើប្រាស់សារអេឡិចត្រូនិច Telegram | | | | | |
| ១២ | ការប្រើប្រាស់កម្មវិធីរបស់Google (Classroom, Forms…..) | | | | | |
| ១៣ | ការប្រើប្រាស់កម្មវិធី Zoom Meeting | | | | | |
| ១៤ | ការប្រើប្រាស់កម្មវិធី Google Meet | | | | | |
| ១៥ | ការចែករំលែកឯកសារមេរៀនដល់មិត្តភក្តិពីអ៊ិនធឺណេត | | | | | |

## ខ. ស្ថានភាពទូទៅនៃការប្រើប្រាស់ICTក្នុងការបង្រៀន និងការរៀន។ ( សូមគូសសញ្ញា ✓)

| ល.រ | ស្ថានភាពទូទៅនៃការប្រើប្រាស់ICT | មិនមាន | មានតិចតួច | មានមធ្យម | មានច្រើន | មានគ្រប់គ្រាន់ |
|---|---|---|---|---|---|---|
| ១ | តើនៅសាលារបស់អ្នកមានបន្ទប់កុំព្យូទ័រសម្រាប់សិក្សាកម្មវិធី ICT ដែរឬទេ ? | | | | | |
| ២ | តើនៅសាលារបស់អ្នកមានកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍ដែរឬទេ ? | | | | | |
| ៣ | តើនៅសាលារបស់អ្នកមានម៉ោងសិក្សាមុខវិជ្ជា ICT ដែរឬទេ។ | | | | | |
| ៤ | តើនៅសាលារបស់អ្នកមានប្រព័ន្ធអ៊ិនធឺណេតប្រើប្រាស់ដែរឬទេ ? | | | | | |
| ៥ | តើអ្នកមានចងក្រងក្រុមសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកដែរឬទេ | | | | | |
| ៦ | តើសាលារបស់អ្នកធ្លាប់ផ្ដល់សម្ភារៈ ICT ដល់អ្នកដែរឬទេ ? | | | | | |
| ៧ | តើសាលារបស់អ្នកមានគ្រូបង្រៀនកុំព្យូទ័ដែរឬទេ ? | | | | | |
| ៨ | នៅសាលារបស់អ្នកមានការបង្រៀនវគ្គខ្លី ពីICTទៅដល់អ្នកដឬទេ ? | | | | | |
| ៩ | តើសាលារបស់អ្នកមានFacebook pageផ្សព្វផ្សាយសម្រាប់សាលដែរឬទេ ? | | | | | |
| ១០ | តើអ្នកមានទូរសព្ទ័ដៃ ឬកុំព្យូទ័ដែរឬទេ ? | | | | | |
| ១១ | តើអ្នកបានប្រើប្រាស់ ICTសម្រាប់ជួយក្នុងការស្រាវជ្រាវមេរៀនដែរឬទេ ? | | | | | |
| ១២ | តើអ្នកបានប្រើប្រាស់ ICT ក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិដែរឬទេ ? | | | | | |
| ១៣ | តើអ្នកបានប្រើប្រាស់ ICT សម្រាប់ទំនាក់ទំនងគ្រូ ឬនាយកសាលាដែរឬទេ ? | | | | | |
| ១៤ | តើអ្នកមានបានប្រើប្រាស់កុំព្យូទ័រ ឬទូរសព្ទ័ក្នុងការសិក្សាដែរឬទេ ? | | | | | |

គ. ស្ថានភាពនៃការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា។ (សូមគូសសញ្ញា ✓)

| | ស្ថានភាពនៃការប្រើប្រាស់កម្មវិធី ICT ក្នុងការសិក្សា | Telegram | Messenger | Google meet | Zoom | Google Forms | Phone call |
|---|---|---|---|---|---|---|---|
| ១ | តើសាលារបស់អ្នកមានក្រុមទំនាក់ទំនងការសិក្សាតាមកម្មវិធីមួយណាដែរ ? | | | | | | |
| ២ | តើអ្នកធ្វើការទំនាក់ទំនងជាមួយនាយកដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៣ | តើអ្នកចូលរួមការប្រជុំនានាជាមួយគ្រូ ឬនាយកដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៤ | តើអ្នកទទួលព័ត៌មានអំពីការប្រជុំនានាដោយមធ្យោបាយណា ? | | | | | | |
| ៥ | តើអ្នកធ្វើការទំនាក់ទំនងជាមួយមិត្តភក្តិដោយប្រើប្រាស់កម្មវិធីមួយណា ? | | | | | | |
| ៦ | ប្រសិនបើមានការប្រឡងពីចម្ងាយ តើកម្មវិធីអ្វីដែលគ្រូរបស់អ្នកបានប្រើនៅក្នុងដំណើរការប្រឡងទាំងនេះ ? | | | | | | |
| ៧ | តើអ្នកផ្ញើវិញ្ញាសាប្រឡងជូនគ្រូរបស់អ្នកដោយមធ្យោបាយណា ? | | | | | | |
| ៨ | តើកម្មវិធីណាមួយដែលអ្នកបានប្រើក្នុងការរៀនតាមអនឡាញនេះ? | | | | | | |
| ៩ | តើអ្នកចុះវត្តមានរបស់អ្នកដោយមធ្យោបាយណា ? | | | | | | |
| ១០ | តើអ្នកចូលរួមក្នុងវេទិកាពិភាក្សា ឬសិក្ខាសាលាផ្សេងៗតាមកម្មវិធីមួយណា ? | | | | | | |
| ១១ | តើកម្មវិធីណាដែលងាយស្រួលក្នុងការទំនាក់ទំនង ? | | | | | | |

**ផ្នែកទី៣៖ បញ្ហាប្រឈមទៅលើការប្រើប្រាស់** ICT

១.សូមប្អូនៗជ្រើសរើសបញ្ហាប្រឈមមួយចំនួនដែលប្រឈមដល់ការប្រើប្រាស់ ICT ទៅលើការសិក្សា ដូចក្រោម៖

| ល.រ | បញ្ហាប្រឈម | លំបាកខ្លាំ | លំបាក | ងាយស្រួល | មធ្យម | ងាយស្រួលខ្លាំង |
|---|---|---|---|---|---|---|
| 1 | តើឧបករណ៍ ICTដែលអ្នកកំពុងប្រើប្រាស់មានភាពលំបាកសម្រាប់អ្នកដែរឬទេ ? | | | | | |
| 2 | តើអ្នកមានការលំបាកទេ ក្នុងការទិញឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន   យកមកប្រើប្រាស់ ? | | | | | |
| 3 | តើអ្នកមានការលំបាកក្នុងការទាញយកកម្មវិធីណាមួយ   មកប្រើប្រាស់ដែរឬទេ ? | | | | | |
| 4 | តើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ ? | | | | | |
| 5 | តើការចំណាយទៅលើប្រព័ន្ធអ៊ិនធឺណេត បង្កជាបញ្ហាដល់អ្នកដែរឬទេ ? | | | | | |
| 6 | តើភាសាបរទេសជាឧបសគ្គទេក្នុងការប្រើប្រាស់ ICT ? | | | | | |
| 7 | តើអ្នកលំបាកក្នុងការស្វែងរកឯកសារពាក់ពន្ធ័មេរៀននៃមុខវិជ្ជារបស់អ្នកដែរទេ ? | | | | | |
| 8 | តើបញ្ហាកង្វះអគ្គីសនីបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT ? | | | | | |
| 9 | តើបញ្ហាកង្វះគ្រូបង្គោលផ្នែកICT បង្កជាផលលំបាកទេចំពោះការប្រើប្រាស់ ICT ? | | | | | |
| 10 | តើបញ្ហាអាកាសធាតុបង្កជាផលលំបាកទេចំពោះការប្រើប្រាស់ICT ? | | | | | |

**សូមអរគុណ !**

# ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាម គ្រូដឹកនាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១៤៣៤ អយក.ឧទន

## លិខិតឧទ្ទេសនាម

យោង ៖ - លិខិតលេខ៣៣៦២ អយក.វជអ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩។
- បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥
- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា២០១៩-២០២១ដែលបានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គ្រូដឹកនាំបង្គោល | គ្រូដឹកនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | និស្សិត |
|---|---|---|---|---|
| ១ | លោក សៀង វាសនា | លោកបណ្ឌិត អាន វ៉ូប្រាវ | ទស្សនៈរបស់បុគ្គលិកអប់រំចំពោះការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សនៅមធ្យមសិក្សាទុតិយភូមិ ឆ្លើយតបទៅនឹងគោលនយោបាយអប់រំ ២០១៨-២០២៣ នៅក្នុងរាជធានីភ្នំពេញ | ល.ស គីម ដាវី |
| ២ | លោកបណ្ឌិត ម៉ម ចាន់សៀន | លោកស្រី ប៊ុន សុផានី | ប្រសិទ្ធភាពនៃការចូលរួមរបស់សហគមន៍ទៅលើការពង្រឹងការអនុវត្តការគ្រប់គ្រងសាលារៀនអនុវិទ្យាល័យ(ករណីសិក្សាស្រុកទ្រាំង ខេត្តតាកែវ) | ល. ជី ចាន់ |
| ៣ | ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម | លោក ម៉ន មុនិន្ទ | ទស្សនៈរបស់គ្រូបង្រៀនលើការអនុវត្តភាពជាអ្នកដឹកនាំរបស់នាយកសាលាកម្រិតវិទ្យាល័យក្នុងខេត្តរតនគិរី | ល. ឈុន សុគន្ធា |
| ៤ | លោកបណ្ឌិត នី វដ្ឋា | លោក លឹម វ៉ាន់ | ស្ថានភាពនៃការបង្រៀន និងរៀនលើមុខវិជ្ជា ICT នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង | ល. ប៉ាវ សេងហួ |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៥ | លោកបណ្ឌិត<br>នី រដ្ឋា | លោក<br>ឌី បុណ្ណា | ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងទី៧ លើមុខវិជ្ជាភាសាខ្មែរ និង គណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំហៅថា (SEIP)ករណីសិក្សា ខេត្តព្រះសីហនុ | ល. ឈួក ជន |
| ៦ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ថៃ ហេង | យុទ្ធសាស្ត្រនៃការដោះស្រាយបញ្ហាខ្វះគ្រូ និងលើសគ្រូ ក្នុងខេត្តកំពង់ធំ | កញ្ញា នេត សីមា |
| ៧ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ឡុច ចាន់ថន | យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ | ល. ប៊ិន តុលា |
| ៨ | លោកស្រី<br>នូ ចន្ទី | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | ទស្សនៈគ្រូឧទ្ទេសលើការដឹកនាំ និងគ្រប់គ្រងការបង្រៀន និងរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | ល. ប៉ែន ដាលី |
| ៩ | ឯកឧត្តម<br>នៀ សុផន | លោកបណ្ឌិត<br>កាង ស៊ិងឆាង | ស្ថានភាពនៃការបែងចែកផែនការគ្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ប្រចាំឆ្នាំ ២០១៩ ករណីសិក្សាខេត្តកណ្តាល | ល. ផាន់ សារ៉ាវុឌ្ឍ |
| ១០ | លោកបណ្ឌិត<br>ឈាង សង្វាត | លោក<br>ថៃ ហេង | ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តរតនគិរី | ល. ព្រិញ ចាន់ហួរ |
| ១១ | ឯកឧត្តមបណ្ឌិត<br>ជ័យ សារិន | លោក<br>ម៉ន មុនិន្ទ | ស្ថានភាពនៃការអនុវត្តប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង ក្នុងការធ្វើស្វ័យវាយតម្លៃសាលារៀន «ករណីសិក្សា ស្រុករំដួលខេត្តស្វាយរៀង» | ល. ព្រុំ រចនា |
| ១២ | លោកស្រី<br>ខែក សំណាង | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | ការសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាអក្សរសាស្ត្រខ្មែរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ«ករណីសិក្សាក្នុងខេត្តព្រៃវែង» | ល. ភ័ណ សុភា |
| ១៣ | លោក<br>ចាប រតនា | លោកបណ្ឌិត<br>ឈាង សង្វាត | ការបំពេញការងាររបស់នាយកសាលាមធ្យមសិក្សាធនធាននិងសាលាបណ្តាញក្នុងខេត្តកំពង់ស្ពឺធៀបនឹងគោលនយោបាយសាលាមធ្យមសិក្សាធនធាន | ល. មុន សុខកែវ |

| | | | | |
|---|---|---|---|---|
| ១៤ | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | លោកស្រី<br>នូ ចន្ធី | ទស្សនរបស់គ្រូបង្រៀន និងនាយកសាលាលើការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយស្តីគ្រូបង្រៀននៅមធ្យមសិក្សាទុតិភូមិក្នុងរាជធានីភ្នំពេញ | ល. យ៉ាង ច័ន្ទរស្មី |
| ១៥ | លោកបណ្ឌិត<br>សំអោ អង្គារតន៍ | លោកស្រី<br>សុខ វណ្ណា | ទស្សនៈគ្រូបង្រៀនទៅលើប្រសិទ្ធភាពនៃការបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិកនិងការបង្រៀននិងរៀននៅក្នុងថ្នាក់ផ្ទាល់នៅកម្រិតមធ្យមសិក្សា | ល. យឹម រស្មី |
| ១៦ | លោក<br>ម៉ន មុនិន្ទ | លោកបណ្ឌិត<br>នូវ វីរ៉ា | ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ លើការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅខេត្តឧត្តរមានជ័យ | ល. រស់ សុកាន់ |
| ១៧ | លោក<br>ម៉ៅ សារឿន | ឯកឧត្តមបណ្ឌិត<br>ម៉ុក សារ៉ុម | ស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី | ល. លាស់ សាឡន |
| ១៨ | លោក<br>ថៃ ហេង | លោកបណ្ឌិត<br>ម៉ម ចាន់សៀន | ការសិក្សាស្វែងយល់អំពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី-ខេត្ត | ល. ស៊ន់ កុសល |
| ១៩ | លោក<br>លឹម វ៉ាន់ | លោកបណ្ឌិត<br>នូវ វីរ៉ា | ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញករណីសិក្សានៅខេត្តតាកែវ | ល. ស៊ុំ សុខឿន |
| ២០ | លោកបណ្ឌិត<br>នូវ វីរ៉ា | លោក<br>ចាប រតនា | ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ក្នុងខេត្តកំពង់ឆ្នាំង | ល. អ៊ុង សុផល |

**ឯកឧត្តម លោក លោកស្រី** ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ " ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន " ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ រដែអ

# ឧបសម្ព័ន្ធទី៣៖ លិខិតចុះប្រមូលទិន្នន័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៤០៩ អយក.វិដ១៧

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

## ឧបសម្ព័ន្ធទី៤៖ លិខិតអញ្ជើញធ្វើបទបង្ហាញសាកល្បង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :.......√............ វជអ.

### លិខិតអញ្ជើញ

| | | |
|---|---|---|
| សូមអញ្ជើញ | ៖ | និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ |
| ដើម្បីចូលរួម | ៖ | ធ្វើបទបង្ហាញសាកល្បងការពារនិក្ខេបបទបញ្ចប់វគ្គសិក្សា |
| កាលបរិច្ឆេទ | ៖ | ថ្ងៃចន្ទ-អង្គារ ៤-៥រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៥-២៦ ខែ តុលា ឆ្នាំ២០២១ |
| ពេលវេលា | ៖ | ម៉ោង៧:៣០ ដល់ម៉ោង១៧:៣០នាទី |
| ទីកន្លែង | ៖ | មជ្ឈមណ្ឌលវប្បធម៌សម្តេច ហ៊ុន សែន និងលោកជំទាវ នៅវិទ្យាស្ថានជាតិអប់រំ |

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១
នាយកវិទ្យាស្ថានជាតិអប់រំ

បណ្ឌិត.សៀង សុវណ្ណា

អាសយដ្ឋានលេខ ១២៣ ម៉ហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ www.nie.edu.kh

## ឧបសម្ព័ន្ធទី៥៖ កាលបរិច្ឆេទទទួលនិក្ខេបបទ និងការការពារបញ្ចប់វគ្គសិក្សា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :........✓..........វជអ.

**កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨**
**កាលបរិច្ឆេទទទួលនិក្ខេបបទ និងការការពារបញ្ចប់វគ្គសិក្សា**

| ល.រ | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | ការទទួលនិក្ខេបបទ | ចាប់ពីថ្ងៃទី១៨-៣០ ខែតុលា ឆ្នាំ២០២១ (ពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ វេលាម៉ោង៨:០០ ដល់១៧:00នាទី) | ៣០ តុលា ២០២១ (ម៉ោង១៧:00នាទី) |
| ២ | បទបង្ហាញសាកល្បងការពារនិក្ខេបបទ | ចាប់ពីថ្ងៃទី២៥-៣០ ខែតុលា ឆ្នាំ២០២១ (ពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ វេលាម៉ោង៨:០០ ដល់១៧:00នាទី) | |
| ៣ | ការការពារនិក្ខេបបទបញ្ចប់វគ្គសិក្សា | ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ (ពីម៉ោង៧:៣០ ដល់១៧:00នាទី) | |

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវ សូមទាក់ទងផ្នែកបណ្តុះបណ្តាលក្រោយឧត្តមសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំរបស់វិទ្យាស្ថានជាតិអប់រំ។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា